# វគ្គទី ៩
# ដំណើរតាមផ្លូវបត់បែនទៅរកសន្តិភាព
# (ទសវត្សរ៍ឆ្នាំ ១៩៨០-១៩៩០)

តាំងពីរ.ជ.រ.ប.ខ.ត្រូវបានប្រកាសឡើងនៅថ្ងៃទី ៩ តុលា ១៩៧៩ តរៀងមក ខ្ញុំតែងចងចាំជានិច្ចថាកងទ័ពនៃរណសិរ្សនេះ គ្រាន់តែជាវត្ថុធាតុមួយក្នុងចំណោមវត្ថុធាតុឯទៀតនៃយុទ្ធសាស្ត្ររួម ដើម្បីបញ្ចប់ជម្លោះនៅកម្ពុជា ។ កងទ័ពជាតិរំដោះប្រជាពលរដ្ឋខ្មែរ ឬ ក.ជ.រ.ប.ខ.មានរូបរាងឡើង ដើម្បីជាសញ្ញាបង្ហាញថា ក្រុមយើងប្ដេជ្ញាធ្វើការតស៊ូរំដោះប្រទេសឲ្យមានអធិបតេយ្យភាពឡើងវិញ និង ទប់ទល់កុំឲ្យរបបប្រល័យពូជសាសន៍វិលត្រឡប់មកកាន់អំណាចបាន ។ តែតាមពិតទៅ យើងក៏ដឹងដែរថាកម្លាំងទ័ពរបស់ពួកយើង មិនអាចមានសមត្ថភាពវាយរុញច្រានកងទ័ពវៀតណាមឲ្យចេញពីទឹកដីយើង តាមកម្លាំងយោធាបានទេ ។ អ្វីដែលពួកយើងអាចនឹកសង្ឃឹមបាននោះគឺ ដំណោះស្រាយបញ្ហាកម្ពុជាតាមការចរចា ដោះស្រាយតាមផ្លូវនយោបាយ តាមរយៈអន្តរាគមន៍របស់សហគមន៍អន្តរជាតិ ជាពិសេសអន្តរាគមន៍របស់អង្គការសហប្រជាជាតិតែប៉ុណ្ណោះ ។

ផ្ទុយទៅវិញ កងទ័ពខ្មែរក្រហម ដែលបានទទួលការទំនុកបំរុងយ៉ាងពេញទំហឹងពីប្រទេសចិន និង ថៃផង បានខំពង្រឹងកម្លាំងឡើងវិញ ក្រោយពីត្រូវទទួលការខូចខាតបាក់បែកជាដំណំ ក្រោមការវាយប្រហាររបស់កងទ័ពវៀតណាម និង កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។ តាមរយៈការពង្រឹងកម្លាំងទ័ព និង ការបង្កើនឧត្តមភាពយោធានៅក្នុងសមរភូមិលើដៃគូពីរទៀត នៅក្នុងរដ្ឋាភិបាលចម្រុះរបស់ខ្មែរក្រហម បានធ្វើឲ្យពួកយើងប្រមើលមើលឃើញថា ខ្មែរក្រហមជ្រើស

រើសយកដំណោះស្រាយយោធាដើម្បីបញ្ចប់សង្គ្រាមនៅកម្ពុជា ។ បើពួកគេមិនទាន់អាចវាយផ្តួលរំលំរដ្ឋាភិបាលភ្នំពេញ និង បណ្តេញកងទ័ពវៀតណាមចេញបានភ្លាមៗ ពួកខ្មែរក្រហមអាចបន្តធ្វើសង្គ្រាមពង្រិចពង្រិលយូរអង្វែង ដែលគ្មានអ្វីក្រៅពីបន្តទុក្ខវេទនាដល់ប្រជាពលរដ្ឋខ្មែរ ឲ្យរឹតតែយូរវែងឆ្ងាយតទៅទៀតមិនខានឡើយ ។ ចំណែកឯកងទ័ពវៀតណាម និង កងកម្លាំងរដ្ឋាភិបាលក្រុងភ្នំពេញនាសម័យនោះ បន្ទាប់ពីបានវាយបណ្តេញ ប៉ុល ពត ចេញពីអំណាចរួចមក ក៏ប្រឹងប្រែងវាយកំទេចឲ្យអស់នូវអង្គការចាត់តាំងទាំងនយោបាយ ទាំងយោធារបស់ ប៉ុល ពត ជាមួយនឹងការស្វែងរកវិធីពង្រឹងរដ្ឋអំណាចរបស់រដ្ឋាភិបាលក្រុងភ្នំពេញ រួមទាំងការទទួលបាននូវការទទួលស្គាល់ពីសហគមន៍អន្តរជាតិផង ។

នៅសម័យនោះ ខ្ញុំមើលឃើញថាដំណោះស្រាយតាមកម្លាំងយោធាហាក់ដូចជាមានអាទិភាពខ្ពស់ជាងគេ ដើម្បីបញ្ចប់ជម្លោះរវាងកងទ័ពវៀតណាម និង កងទ័ពខ្មែរក្រហម ។ ក៏ប៉ុន្តែ ជាមួយគ្នានោះ ក៏មានចលនាស្វែងរកការជួបគ្នារវាងសម្តេច សីហនុ ជាមួយថ្នាក់ដឹកនាំរដ្ឋាភិបាលក្រុងភ្នំពេញដែរ ទោះបីព្រះអង្គបានចូលរួមក្នុងរដ្ឋាភិបាលចម្រុះត្រីភាគីក៏ដោយ ។ រាល់ការជួបចរចាណាមួយលើឆាកអន្តរជាតិ អាចចាត់ទុកជាការចាប់ផ្តើមទទួលស្គាល់ខ្លះៗដល់រដ្ឋាភិបាលនៅភ្នំពេញរួចទៅហើយ ។

# ទិដ្ឋភាពពីរនៃបញ្ហាកម្ពុជាពិតជាត្រឹមត្រូវ

នៅសម័យនោះ មានការបកស្រាយថាជម្លោះនៅកម្ពុជាមានទិដ្ឋភាពពីរគឺៈ ទីមួយ ទិដ្ឋភាពអន្តរជាតិដែលពាក់ព័ន្ធដល់វត្តមាន និង ការដកកងទ័ពវៀតណាមចេញពីកម្ពុជា និង ទីពីរ ទិដ្ឋភាពជាតិ ដែលទាក់ទងដល់ការផ្សះផ្សារសម្រុះសម្រួលគ្នារវាងភាគីខ្មែរបដិបក្ខ ។ ជំនួប សីហនុ-ហ៊ុន សែន នៅចុងឆ្នាំ ១៩៨៧ បានចាប់

ផ្តើមធ្វើឲ្យមានបរិយាកាសអនុគ្រោះ ដល់ដំណោះស្រាយផ្នែកទិដ្ឋភាពជាតិនៃជម្លោះនៅកម្ពុជា ។

នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ នោះ ពួកក្រុមយើងនៅក្នុងចលនាតស៊ូមិនសូវមានការពេញចិត្តចំពោះការផ្លាស់ប្តូរគោលជំហរនយោបាយរបស់សម្តេច សីហនុ ប៉ុន្មានទេ ។ ពួកយើងក្រោមការដឹកនាំរបស់លោកតា សឺន សាន តែងតែយល់ថា ព្រះអង្គផ្លាស់ប្តូរញឹកញាប់ពេក ។ ជាពិសេស នៅពេលដែលពួកយើងកំពុងរៀបចំទ័ព និង បង្កើតរណសិរ្ស ដើម្បីតបតជាមួយកងទ័ពវៀតណាម សម្តេចទ្រង់គង់នៅសៀម និង ថែមទាំងចង់ទៅចរចាជាមួយមេដឹកនាំទីក្រុងហាណូយទៀតផង ។ តាមលោកតា សឺន សាន រ.ជ.រ.ប.ខ.បានត្រូវរៀបចំឡើង ដើម្បីថ្វាយព្រះអង្គដឹកនាំ ព្រោះថាកាលពីដើមឆ្នាំ ១៩៧៩ នៅទីក្រុងញីវយ៉ក ទោះបីជាលោកតាមិនបានចូលគាល់សម្តេចផ្ទាល់ក៏ដោយ លោកតាក៏បានទូរស័ព្ទទូលពីបំណងបង្កើតចលនាតស៊ូមិនមែនកុម្មុយនីស្តមួយ ដែលអាចឲ្យប្រជាពលរដ្ឋខ្មែរទទួលយកបាន ។

តាមពិតទៅ នៅសម័យនោះ អ្វីដែលលោកតាមានប្រសាសន៍ ពួកយើងក្មេងៗតែងជឿទាំងអស់ ។ ក៏ប៉ុន្តែ តាមការវិភាគក្រោយៗមក ខ្ញុំក៏យល់ដឹងថា សម្តេច សីហនុ មិនចូលរួមជាមួយលោកតា សឺន សាន ក៏ដោយសារព្រះអង្គមានហេតុផលរបស់ព្រះអង្គដែរ ។ ក្រោយដែលសម្តេចទ្រង់បានទទួលសេរីភាពចេញពីក្រុម ប៉ុល ពត រួចហើយ ព្រះអង្គអាចប្រកាន់គោលជំហរថា ក្នុងឋានៈជាអតីតព្រះមហាក្សត្រដែលជាទីគោរពសក្ការៈរបស់ប្រជាពលរដ្ឋខ្មែរ ព្រះអង្គត្រូវតែគង់នៅក្នុងស្ថានភាពមួយ ដែលអាចឲ្យព្រះអង្គចាប់ដៃនិយាយជាមួយអ្នកណាក៏បាន ។ម្យ៉ាងទៀត ព្រះអង្គក៏អាចស្គាល់លោកតា សឺន សាន ច្បាស់លាស់ជាងនរណាទាំងអស់ ព្រោះថាលោកតា សឺន សាន ធ្លាប់ជាសហការី ឬ ទីប្រឹក្សារបស់សម្តេចអស់ពេលជាច្រើនឆ្នាំ កាលព្រះអង្គគង់នៅក្នុងអំណាចនៅឡើយ ។ សម្តេច សីហនុ

ក៏អាចស្គាល់លោកតា សឺន សាន ថាជាអ្នកនយោបាយជើងចាស់មួយរូបដែរ ។ ព្រះអង្គអាចទតឃើញថា អ្នកនយោបាយជួនកាលគេឲ្យអ្វីមួយដែលយើងមិនអាចទទួលយកបាន ។ យ៉ាងណាមិញ ក្នុងករណីដែលលោកតាថាថ្វាយសម្តេច សីហនុ ដឹកនាំរ.ជ.រ.ប.ខ.នោះ ព្រះអង្គក៏ប្រាកដជាពិបាកនឹងទទួលណាស់ ព្រោះថាអ្នកដឹកនាំសំខាន់ៗមួយចំនួនធំនៃរ.ជ.រ.ប.ខ. សុទ្ធតែជាអ្នកសាធារណរដ្ឋ ដែលបានផ្តួលរំលំរបបរាជានិយមរបស់ព្រះអង្គរួចម្តងទៅហើយៗនៅតែបន្តអរិភាព ចំពោះព្រះអង្គផង ។ ខ្ញុំនៅចាំបានថា នៅខែ កក្កដា ១៩៨២ នៅឱកាសដែលសម្តេច សីហនុ យាងទៅធ្វើទស្សនកិច្ចជាលើកទីមួយនៅជំរុំអំពិល មេដឹកនាំជំរុំអំពិលមានជាអាទិ៍ លោកឧត្តមសេនីយ ដៀន ដែល និង លោក ហ៊ីង គន្ថុន មិនមានបំណងចេញមកទទួលព្រះអង្គ និង ព្រះជាយាទេ ។ ដូចខ្ញុំបានសរសេរ នៅវគ្គមុនៗរួចហើយថានៅទីបំផុតនៅឆ្នាំ ១៩៨១ សម្តេច សីហនុ ក៏ទ្រង់បង្កើតចលនានយោបាយរបស់ព្រះអង្គដែលមានឈ្មោះថា ហ្វ៊ុន ស៊ិន ប៉ិច ។ យ៉ាងដូច្នេះហើយ ទើបចលនាតស៊ូមិនមែនកុម្មុយនីស្តបានត្រូវបង្កើតឡើងពីរផ្សេងគ្នា មួយដឹកនាំដោយលោកតា សឺន សាន និង មួយទៀតដឹកនាំដោយសម្តេច សីហនុ ។ ចលនាមួយចេញដំណើរពីធំមកតូច ចលនាមួយទៀតចេញពីតូចមកធំ ។ មិនតែប៉ុណ្ណោះ ការប្រណាំងប្រជែងគ្នារវាងចលនាតស៊ូមិនមែនកុម្មុយនីស្តទាំងពីរនោះ ក៏បានផ្តល់លទ្ធភាពឲ្យក្រុមខ្មែរក្រហមរៀបចំអង្គការចាត់តាំងនយោបាយ និង យោធាបានមួយរយៈ មុននឹងត្រូវដួលរលំទាំងស្រុងនៅចុងឆ្នាំ ១៩៩៨ ដោយសារនយោបាយឈ្នះ/ឈ្នះរបស់សម្តេចតេជោ ហ៊ុន សែន ។

ចាប់តាំងពីថ្ងៃ ៧ មករា ១៩៧៩ រៀងមក ទាំងខ្មែរក្រហម ទាំងក្រុមខ្មែរមិនមែនកុម្មុយនីស្ត រួមទាំងប្រទេសដែលគាំទ្រផង មិនបានញែកបញ្ហាកម្ពុជាជាពីរទិដ្ឋភាពដូចខាងលើទេគឺ គេចាត់ទុកការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត

ជាអំពើឈ្លានពានរបស់វៀតណាមមកលើអធិបតេយ្យភាពនៃកម្ពុជា ។ តាមយុទ្ធសាស្ត្រនេះ បញ្ហាកម្ពុជាមានតែមួយគត់គឺការដកកងទ័ពវៀតណាមចេញពីកម្ពុជា ។ រ.ជ.រ.ប.ខ.ប្រកាន់គោលជំហរធ្វើការប្រយុទ្ធប្រឆាំងបរទេសឈ្លានពានតាមដំណោះស្រាយមួយ ដែលមានអង្គការសហប្រជាជាតិមកត្រួតពិនិត្យការដកថយនៃកងទ័ពបរទេសនេះ និង បន្ទាប់មក រៀបចំការបោះឆ្នោតដោយសេរីត្រឹមត្រូវ ដើម្បីជ្រើសរើសរបប និង អ្នកដឹកនាំរដ្ឋតាមឆន្ទៈរបស់ប្រជារាស្ត្រខ្មែរ ។ នៅក្នុងអន្តរកាលរ.ជ.រ.ប.ខ.សុំឲ្យមានការចាត់តាំងរដ្ឋាភិបាលចតុភាគីមួយ ដែលមានការចូលរួមពីភាគីខ្មែរទាំងអស់រួមទាំងភាគីរដ្ឋាភិបាលក្រុងភ្នំពេញផង ។

## រ.ជ.រ.ប.ខ. ប្រកាន់គោលជំហរដូចខ្មែរក្រហម

គួរចាប់អារម្មណ៍ថាមុនពេលចូលរួមក្នុងរដ្ឋាភិបាលចម្រុះត្រីភាគី រ.ជ.រ.ប.ខ. ជាអ្នកប្រឆាំងខ្មែរក្រហមយ៉ាងស្លាប់រស់ ក៏ប៉ុន្តែនៅក្នុងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ(ត្រីភាគី) រ.ជ.រ.ប.ខ. ក៏ក្លាយទៅជាមេធាវីការពារយ៉ាងរឹងមាំនូវគោលជំហររបស់រដ្ឋាភិបាលនេះ ដែលជាទូទៅស្ថិតនៅក្រោមឥទ្ធិពលដ៏ខ្លាំងក្លារបស់ខ្មែរក្រហម ។ រ.ជ.រ.ប.ខ.ប្រកាន់គោលជំហរដូចខ្មែរក្រហមដែរគឺ ដាច់ណាត់មិនចរចាជាមួយរដ្ឋាភិបាលក្រុងភ្នំពេញទេ ។ បើត្រូវចរចាគឺ ចរចាតែជាមួយរដ្ឋាភិបាលក្រុងហាណូយតែប៉ុណ្ណោះ ។ គោលជំហរបែបនេះ ក៏មិនខុសពីគោលជំហរដ៏រឹងត្អឹងរបស់ខ្មែរក្រហមឡើយ ។ ចំណែកសម្តេច សីហនុ ទោះជាព្រះអង្គចូលមកគង់ជាប្រធានកម្ពុជាប្រជាធិបតេយ្យ ឬ ជាថ្នាក់ដឹកនាំកំពូលនៃរដ្ឋាភិបាលចម្រុះត្រីភាគីយ៉ាងណាក៏ដោយ ក៏ព្រះអង្គតែងតែរិះរកមធ្យោបាយ ឲ្យមានការជួបចរចាគ្នាជាមួយរដ្ឋាភិបាលក្រុងហាណូយក៏បាន ជាមួយរដ្ឋាភិបាលក្រុងភ្នំពេញក៏បាន ។ ដូចយើងបានឃើញនៅវគ្គមុនៗរួចហើយ សម្តេច សីហនុ បានសាកល្បងរក្សាឯករាជភាពរបស់

ព្រះអង្គពីខ្មែរក្រហមណាស់ដែរ ក៏ប៉ុន្តែដោយសារព្រះអង្គត្រូវការជំនួយសម្រាប់ចលនារបស់ព្រះអង្គ ជាពិសេសជំនួយឃោធាសម្រាប់ហ៊្វុន ស៊ិន ប៉ិច ទើបព្រះអង្គចូលរួមជាមួយខ្មែរក្រហម និង ជាមួយលោកតា សឺន សាន នៅក្នុងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ តាមពិតទៅ បើព្រះអង្គមានមធ្យោបាយផ្ទាល់ព្រះអង្គដើម្បីធ្វើសកម្មភាពនយោបាយដោយព្រះអង្គឯង ឬ ប្រសិនបើមានមហាអំណាចណាមួយនៃលោកខាងលិច ឬ មហាអំណាចណាក្រៅពីចិនផ្តល់មធ្យោបាយថ្វាយព្រះអង្គ សម្តេចប្រាកដជាគេចចេញពីខ្មែរក្រហមមិនខានឡើយ ។ សម្តេចធ្លាប់បានសម្រេចព្រះទ័យសុំការអនុញ្ញាតពីរដ្ឋាភិបាលស.រ.អា និង បារាំងទៅគង់កៀសព្រះអង្គនៅប្រទេសទាំងពីរនេះ ក៏ប៉ុន្តែ ដោយមិនបានទទួលចម្លើយតាមសំណើរបស់ព្រះអង្គ ពីប្រទេសមហាអំណាចខាងលិចទាំងពីរនេះ និង ដោយមានការទទូចសុំពីមេដឹកនាំចិន តេង ស៊ាវពីង កាលពីខែ មករា ១៩៧៩ ទើបព្រះអង្គវិលត្រឡប់ទៅគង់នៅប្រទេសចិនវិញ ហើយនៅទីបំផុតក៏ចូលរួមជាមេដឹកនាំរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យតមកទៀត ។

គួរបញ្ជាក់ថាជាមួយនោះ ព្រះអង្គក៏សាកល្បងទាក់ទងជាមួយមេដឹកនាំក្រុងហាណូយ ដើម្បីរកវិធីដោះស្រាយបញ្ហាកម្ពុជាតាមការចរចាគ្នា ដែលធ្វើឲ្យមានការរិះគន់ព្រះអង្គយ៉ាងខ្លាំងពីក្រុមខ្មែរក្រហម និង ពីក្រុមលោកតា សឺន សាន ។ ក្រៅពីនេះ តាមរយៈខ្សែរយៈទំនាក់ទំនងដ៏ធំទូលាយលើឆាកអន្តរជាតិរបស់ព្រះអង្គសម្តេច ក៏ព្យាយាមជួបចរចាជាមួយថ្នាក់ដឹកនាំរដ្ឋាភិបាលក្រុងភ្នំពេញដែរ ។ តាមសម្តេចតេជោ ហ៊ុន សែន ជំនួប សីហនុ-ហ៊ុន សែន លើកដំបូង គ្រោងធ្វើឡើងនៅប្រទេសបារាំងក្នុងឆ្នាំ ១៩៨៤ ។ ជំនួបនោះគ្រោងរៀបចំឡើងដោយប្រទេសបារាំង ក៏ប៉ុន្តែ ត្រូវអាក់ខានវិញ ដោយសារសភាពការណ៍នៅពេលនោះនៅមិនទាន់អនុគ្រោះ ។ នៅសម័យនោះ ទាំងចិនទាំងប្រទេសអាស៊ាន សុទ្ធតែប្រកាន់គោលជំហរ

ឲ្យដកកងទ័ពវៀតណាមចេញជាមុនសិន ទើបឲ្យមានការជួបចរចាគ្នា ។

## ក្រុមលោកតា សឺន សាន រិះគន់សម្តេច សីហនុ

នៅឆ្នាំ ១៩៨៤ នោះ អ្នកគាំទ្រលោកតា សឺន សាន និង រ.ជ.រ.ប.ខ.បាន ធ្វើការវាយប្រហារសម្តេច សីហនុ យ៉ាងខ្លាំងតាមការរិះគន់ជាសាធារណៈ និង តាមផ្លូវឯកជនជាច្រើនថា សម្តេចជាអ្នកទទួលខុសត្រូវ ចំពោះការឡើងកាន់អំណាចនៃខ្មែរក្រហមក្នុងឆ្នាំ ១៩៧៥ ហើយថា ព្រះអង្គកំពុងបំរើនយោបាយរបស់ចិនកុម្មុយនីស្ត និង ខ្មែរក្រហមតទៅទៀត ។ ដើម្បីឆ្លើយតបទៅនឹងការរិះគន់របស់ក្រុមលោកតា សឺន សាន នេះ សម្តេច សីហនុ បានចេញផ្សាយឯកសារសំណួរចម្លើយចុះថ្ងៃទី ១០ វិច្ឆិកា ១៩៨៤ និង អនុស្សរណៈចុះថ្ងៃទី ១៥ វិច្ឆិកា ១៩៨៤ វាយបកទៅវិញ ថាប្រសិនបើលោកតា សឺន សាន និង រ.ជ.រ.ប.ខ.ស្អប់ខ្ពើមខ្មែរក្រហមមែន ហេតុដូចម្តេចបានជាសុខចិត្តចូលរួមក្នុងរដ្ឋាភិបាលចម្រុះត្រីភាគីជាមួយពួកនេះ ហើយហេតុអ្វីបានជាលោកតា សឺន សាន សុខចិត្តធ្វើជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ? នៅក្នុងឯកសាររបស់ព្រះអង្គនេះ សម្តេច សីហនុ ក៏បានឲ្យដឹងដែរថា ព្រះអង្គបានសុំលាឈប់ពីតំណែងប្រធានកម្ពុជាប្រជាធិបតេយ្យជាច្រើនខែមកហើយ តែទាំងក្រុមប្រទេសអាស៊ាន ទាំងប្រទេសចិន និង ដៃគូឯទៀតនៅក្នុងរដ្ឋាភិបាលចម្រុះ បានសុំឲ្យព្រះអង្គនៅបន្តតំណែងនេះតទៅទៀត ។ សម្តេចសំដែងមតិថា ព្រះអង្គរង់ចាំតែសញ្ញាភ្លើងខៀវពីអ្នកទាំងនោះទេ ដើម្បីលាចេញពីតំណែង ។ សម្តេចបានបន្ទោសក្រុមលោកតា សឺន សាន ថារំលោភលើកិច្ចព្រមព្រៀងត្រីភាគីកូឡាឡាំពួ[200] ដោយធ្វើការវាយប្រហារព្រះអង្គនៅចំពោះមុខសារព័ត៌មានអន្តរជាតិ តាមពាក្យសំដីដ៏សាហាវ និង ដោយប្រមាថជាទីបំផុត ។ ព្រះអង្គ

[200] Norodom Sihanouk, Memorandum, New York, November 15, 1984.

សំដៅចំពោះក្រុមរ.ជ.រ.ប.ខ. នៅប្រទេសបារាំង និង ស.រ.អា ជាពិសេសអ្នកស្រី សួន កាសេត លោកបណ្ឌិត ឆាយ ហាន់ចេង (កូនប្រសារលោកតា សឺន សាន) និង ក្រុមខ្មែរគាំទ្ររ.ជ.រ.ប.ខ. នៅរដ្ឋមីនីសូតា (Minnesota) ស.រ.អាជាដើម[201] ។

ក្រុមរ.ជ.រ.ប.ខ. មានការខកចិត្ត ចំពោះគោលជំហររបស់ប្រទេសបារាំង ដែលប៉ុនប៉ងរៀបចំជំនួប សីហនុ-ហ៊ុន សែន នាឆ្នាំ ១៩៨៤ នោះ ។ ពួករ.ជ.រ.ប.ខ. មើលឃើញលោករដ្ឋមន្ត្រីការបរទេសបារាំង ក្លូត ឆេសសុង (Claude Cheysson) ហាក់ដូចជាលំអៀងខ្លាំងទៅខាងវៀតណាម និង រដ្ឋាភិបាលក្រុងភ្នំពេញ ។ គួរកត់សម្គាល់ថា រាល់ៗពេលដែលសម្តេច សីហនុ ត្រៀមជួបចរចាជាមួយមេដឹកនាំរដ្ឋាភិបាលក្រុងភ្នំពេញ ព្រះអង្គតែងអាងហេតុផលជាលេស ដើម្បីសុំលាឈប់ពីតំណែងប្រធានកម្ពុជាប្រជាធិបតេយ្យនេះ ។

នៅខែ កក្កដា ១៩៨៤ សម្តេច សីហនុ បានប្រកាសជាសាធារណៈថាកងទ័ពខ្មែរក្រហមវាយប្រហារមកលើកងទ័ពរបស់ព្រះអង្គ ។ សម្តេចគំរាមថានឹងលាលែងពីតំណែង ឬ យាងចេញពីសម្ព័ន្ធភាពត្រីភាគី ។ សេចក្តីប្រកាសជាសាធារណៈរបស់ព្រះអង្គជា "ព្រួញមួយបាញ់បានសត្វពីរ" គឺមួយជាសញ្ញាប្រាប់ដៃគូនៅក្នុងរដ្ឋាភិបាលត្រីភាគីរបស់ព្រះអង្គឲ្យដឹងថា បើមានការគាបសង្កត់ទៅលើសម្តេច ដោយកម្លាំងយោធាក្តី ដោយការវាយប្រហារតាមពាក្យសំដីក្តី ព្រះអង្គមិនខ្លាចនឹងដកព្រះអង្គចេញពីដៃគូទាំងនោះឡើយ ។ ឯមួយទៀតក៏ជាសញ្ញាដល់វៀតណាម និង រដ្ឋាភិបាលក្រុងភ្នំពេញថា ព្រះអង្គរក្សាលទ្ធភាពអាចចេញមកចរចាជាមួយពួកគេបានគ្រប់ពេលវេលា ។ គួរកត់សម្គាល់ម្យ៉ាងទៀតថា ចាប់តាំងពីលោកប្រធានាធិបតីថ្មីនៃប្រទេសបារាំងគឺលោក ហ្វ្រង់ស្វ័រ មីតេរ៉ង់ (François Mitterand) នៃគណបក្សសង្គមនិយមបារាំងឡើងកាន់អំណាចនាឆ្នាំ ១៩៨១ មក ប្រទេសបារាំងបានខិតខំ

---

[201] Norodom Sihanouk's Replies to SonSannian Accusations and Questions in Minneapolis, November 10, 1984.

លើកទឹកចិត្តឲ្យមានការជួបចរចាគ្នាផ្ទាល់រវាងគូបដិបក្ខខ្មែរទាំងពីរ គឺរវាងរដ្ឋាភិបាលចម្រុះត្រីភាគី និង រដ្ឋាភិបាលក្រុងភ្នំពេញ ។

គួររំលឹកដែរថាចាប់តាំងពីឆ្នាំ ១៩៨២ ដល់ឆ្នាំ ១៩៨៥ គឺ ចាប់តាំងពីការបង្កើតរដ្ឋាភិបាលចម្រុះត្រីភាគីមក កងទ័ពនៃភាគីទាំងបីក្នុងរដ្ឋាភិបាលនេះ បានបង្កើនការវាយប្រហារតាមផ្លូវយោធាមកលើកងទ័ពវៀតណាម និង កងទ័ពរដ្ឋាភិបាល ហេង សំរិន ជាប់ជាប្រចាំ ។ ក៏ប៉ុន្តែចាប់ពីឆ្នាំ ១៩៨៥ មក កងទ័ពវៀតណាម និង កងទ័ព ហេង សំរិន បានវាយបកត្រឡប់វិញយ៉ាងខ្លាំងក្លា ។ នៅទីបំផុត កងទ័ពទាំងនេះ បានទទួលជោគជ័យក្នុងការវាយបណ្តេញកងទ័ពត្រីភាគីឲ្យបោះបង់ចោលទីតាំងយោធា ដែលនៅលើទឹកដីខ្មែរ តាមបណ្តោយព្រំដែនខ្មែរ-ថៃ ។ បន្ទាប់ពីការបាក់បែកនេះមក មេទ័ពត្រីភាគីជាពិសេសអតីតឧត្តមសេនីយនៃរបបសាធារណរដ្ឋដូចជាលោកឧត្តមសេនីយ សក់ ស៊ុតសាខន នៃក.ជ.រ.ប.ខ.ជាដើម បានប្រកាសជាសាធារណៈថា ពួកលោកឧត្តមសេនីយបានផ្លាស់ប្តូរកលយុទ្ធពីធ្វើសង្គ្រាមតាមរបៀបទ័ពស្រុក មកធ្វើតាមរបៀបទ័ពព្រៃម្តងវិញ ដូច្នេះមិនចាំបាច់មាន ទីតាំងយោធានៅនឹងកន្លែងឡើយ ។

## សហគមន៍អន្តរជាតិទទួលយកសីលធម៌សកលថ្មី

ការវាយប្រហារគ្នាតាមផ្លូវយោធា ដែលចេះតែរីកទ្រង់ទ្រាយធំឡើងៗបានបង្កើតឲ្យមានមហន្តរាយខាងផ្នែកមនុស្សធម៌ដ៏ធំធេង ។ ប្រជាពលរដ្ឋខ្មែរ ដែលទទួលរងគ្រោះដោយសាររបបប្រល័យពូជសាសន៍ ដែលមិនធ្លាប់ឃើញសោះនៅក្នុងប្រវត្តិសាស្ត្រខ្មែរ បានទទួលរងថែមទៀតនូវផលប៉ះពាល់ដោយសារសង្គ្រាម ។ ដើម្បីគេចចេញពីភ្លើងសង្គ្រាម ជនភៀសខ្លួនខ្មែររាប់សែននាក់ បានរត់មកជ្រកនៅតាមតំបន់ជាយដែន ។ មួយភាគធំបានឆ្លងចូលមករកទីជម្រកនៅប្រទេសថៃ ។

ជនភៀសខ្លួនទាំងនោះ បានទទួលការជួយឧបត្ថម្ភម្ហូបអាហារ ទីជម្រក និង ការការពារពីអង្គការសហប្រជាជាតិ ។ ពួកគេក៏នាំមកជាមួយនូវរឿងរ៉ាវផ្ទាល់ខ្លួនរបស់គេម្នាក់ៗស្តីពីឧក្រិដ្ឋកម្មយង់ឃ្នងរបស់ពួក ប៉ុល ពត ក្នុងពេលដែលពួកនេះកាន់អំណាច ។ ពិភពលោកទាំងមូលក៏កាន់តែយល់ដឹងច្បាស់ឡើងនូវជាតុពិតនៃរបបប្រល័យពូជសាសន៍ ។ ជាមួយនឹងវិបត្តិជនភៀសខ្លួនខ្មែរ សហគមន៍អន្តរជាតិហាក់ដូចជាទទួលយកនូវសតិសម្បជញ្ញៈ និង សីលធម៌សកលមួយថ្មីគឺ ការស្វែងរកនូវការបញ្ចប់ទុក្ខវេទនារបស់ប្រជាពលរដ្ឋខ្មែរជាបន្ទាន់ ។ មហាអំណាចចម្បងៗ ហាក់ដូចជាសម្លឹងឃើញថា ត្រូវដោះស្រាយជម្លោះកម្ពុជាដោយសន្តិវិធី ដែលនៅក្នុងដំណោះស្រាយនោះ រួមមានការទប់ស្កាត់របបខ្មែរក្រហម ប៉ុល ពត មិនឲ្យត្រឡប់មកកាន់អំណាចវិញ និង ការគោរពជាដាច់ខាតនូវសិទ្ធិមនុស្សនៅកម្ពុជា ។

ចរន្តអន្តរជាតិនេះ រឹតតែធ្វើឲ្យពួកខ្មែរក្រហមយល់ថា អនាគតរបស់ពួកគេនឹងត្រូវរលត់រលាយ ប្រសិនបើពួកគេមិនពង្រឹងកម្លាំងយោធានៅលើសមរភូមិឲ្យបានរឹងមាំទេ ។ អនាគតរបស់ខ្មែរក្រហមនោះ ពិតជាស្ថិតនៅលើឧត្តមភាពយោធាតែមួយគត់របស់ពួកគេ ។ ដូច្នេះកលយុទ្ធសំខាន់ទីមួយ និង ងាយស្រួលជាងគេគឺបង្កើនឧត្តមភាពខាងផ្នែកយោធា ទៅលើដៃគូមិនមែនកុម្មុយនីស្តពីរទៀត ទាំងទៅលើរ.ជ.រ.ប.ខ. ទាំងទៅលើ ហ៊្សុន ស៊ិន ប៉ិច ។ ខ្មែរក្រហមរក្សាសម្ព័ន្ធភាពតែខាងផ្លូវនយោបាយតែប៉ុណ្ណោះ ។ ពួកគេមិនខ្លាចនឹងវាយប្រហារដៃគូពីរទៀតតាមកម្លាំងយោធានោះឡើយ ។ ដូចនេះការវាយប្រហារប្រយុទ្ធគ្នា ក៏កើតឡើងរវាងកងទ័ពខ្មែរក្រហម និង កងទ័ពនៃចលនាមិនមែនកុម្មុយនីស្ត ។ នៅសម័យនោះ ចំពោះខ្មែរក្រហម មានតែកម្លាំងយោធាមួយគត់ ដែលអាចធានាអាយុជីវិតឲ្យពួកគេ និង អាចឲ្យគេមានមុខនៅតុចរចានាពេលណាមួយខាងមុខ ។

# ភាគីនីមួយៗ និង គោលជំហរក្នុងការធ្វើសង្គ្រាម

គួររំលឹកទៀតថា វៀតណាមក៏ទទួលការគាបសង្កត់កាន់តែខ្លាំងឡើងពីសហគមន៍អន្តរជាតិឲ្យដកកងទ័ពចេញពីកម្ពុជា ។ ជាមួយគ្នានោះ ការផ្សះផ្សាជាតិរវាងភាគីខ្មែរ ក៏ក្លាយទៅជាគន្លឹះនៃដំណោះស្រាយនយោបាយផងដែរ ។ ថ្នាក់ដឹកនាំវៀតណាមធ្លាប់បានប្រកាសថា ប្រសិនបើភាគីខ្មែរទាំងអស់ ក្រោយដែលបានជានាផ្សះផ្សាគ្នា និង រួបរួមគ្នារួចហើយៗស្នើឲ្យវៀតណាមដកទ័ពចេញពីកម្ពុជា វៀតណាមនឹងដកទ័ពចេញពីកម្ពុជាភ្លាម ។ នៅសម័យនោះ ភាគីខ្មែរនៅមិនទាន់អាចជានាផ្សះផ្សាគ្នាបាននៅឡើយទេ ។ ជាពិសេស ភាគីធំៗពីរគឺ ភាគីរដ្ឋាភិបាលក្រុងភ្នំពេញ និង ភាគីខ្មែរក្រហម ។ ភាគីរដ្ឋាភិបាលភ្នំពេញ ឈរលើគោលជំហរថាធ្វើសង្គ្រាម ដើម្បីរំដោះប្រជាពលរដ្ឋខ្មែរពីរបបប្រល័យពូជសាសន៍ ។ ឯវត្តមានកងទ័ពវៀតណាមនៅកម្ពុជាជាការចាំបាច់ ដើម្បីជួយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត ផង និង ដើម្បីជួយទប់ស្កាត់កុំឲ្យរបបសាហាវយង់ឃ្នងនេះ វិលមកកាប់សម្លាប់ប្រជាពលរដ្ឋខ្មែរវិញផង ។ ដូច្នេះកងទ័ពវៀតណាម ជាកងទ័ពសម្ព័ន្ធមិត្តមកជួយការពារប្រជាពលរដ្ឋខ្មែរ មិនមែនជាកងទ័ពបរទេសមកឈ្លានពានកម្ពុជាទេ ។ ភាគីខ្មែរក្រហម និង ដៃគូពីរទៀតប្រកាន់គោលជំហរថា គេធ្វើសង្គ្រាមដើម្បីរំដោះប្រទេសកម្ពុជាពីកងទ័ពវៀតណាមឈ្លានពាន ។ ឈរលើគោលជំហរផ្ទុយគ្នានេះ ការផ្សះផ្សាជានាគ្នាប្រាកដជាមានការលំបាកក្រៃលែង ។ តែទោះជាយ៉ាងណាក៏ដោយ ក៏គំនិតផ្សះផ្សាភាគីខ្មែរនេះ ត្រូវបានលើកឡើងជាបន្តបន្ទាប់ក្នុងបណ្តាប្រទេស ដែលចង់ជួយរកដំណោះស្រាយក្នុងបញ្ហាកម្ពុជា ។

# សេអូសេស្គូ ណែនាំឲ្យ ខៀវ សំផន ជានាជាមួយ ហេង សំរិន

នៅខែ សីហា ១៩៨២ សម្តេច សីហនុ និង លោក ខៀវ សំផន បានទៅបំពេញទស្សនកិច្ចនៅប្រទេសរូម៉ានី ដែលនៅសម័យនោះ ជាប្រទេសកុម្មុយនីស្តក៏ប៉ុន្តែមានទំនាក់ទំនងល្អជាមួយប្រទេសវៀតណាមផង និង ទំនាក់ទំនងល្អជាមួយរដ្ឋាភិបាលចម្រុះត្រីភាគីកម្ពុជាប្រជាធិបតេយ្យផង ។ នៅក្នុងជំនួបជាមួយលោកប្រធានាធិបតី សេអូសេស្គូ (Ceausescu) លោកប្រធានាធិបតីរូបនេះបានផ្តល់មតិដល់លោក ខៀវ សំផន ឲ្យធ្វើការផ្សះផ្សាជានាគ្នាជាមួយភាគី ហេង សំរិន ព្រោះថា បើគ្មានការជានាផ្សះផ្សាគ្នាជាមួយភាគីនេះទេ បញ្ហាកម្ពុជាមិនអាចដោះស្រាយបានឡើយ ។ លោកប្រធានាធិបតីរូម៉ានី គ្មានជំនឿថា ខ្មែរក្រហមអាចដណ្តើមជ័យជំនះតាមកម្លាំងយោធានោះទេ ។ ចំពោះមតិណែនាំនេះ ខ្មែរក្រហមពុំអាចទទួលយកបានឡើយ ព្រោះថាគោលជំហររបស់ពួកគេគឺបង្ខំឲ្យកងទ័ពវៀតណាមដកទ័ពចេញពីកម្ពុជាជាមុន ។ ខ្មែរក្រហមយល់ថា បើគ្មានកងទ័ពវៀតណាមទេនោះ របប ហេង សំរិន ក៏នឹងដួលរំលំមិនខានឡើយ[202] ។ ខ្មែរក្រហមជឿជាក់ទៀតថា ការដកកងទ័ពវៀតណាមចេញពីកម្ពុជា នឹងបើកផ្លូវឲ្យពួកគេវិលត្រឡប់មកកាន់អំណាចវិញ ។

តាមពិតទៅ ខ្មែរក្រហមគ្រាន់តែដើរតាមយុទ្ធសាស្ត្ររបស់ចិនតែប៉ុណ្ណោះ។ ចិនធ្លាប់ទាមទារឲ្យវៀតណាមដកកងទ័ពចេញពីកម្ពុជាជាមុនសិន មុននឹងមានសន្និសីទអន្តរជាតិមួយស្តីពីកម្ពុជា ។ គួរកត់សម្គាល់ថា ចាប់ពីខែ តុលា ឆ្នាំ ១៩៨២ ចិន និង សូវៀត ចាប់ផ្តើមធ្វើការចរចាគ្នា ដើម្បីឲ្យមានប្រក្រតីភាពក្នុងទំនាក់ទំនងគ្នាឡើងវិញ ។ ការចរចា ចិន និង សូវៀត បើកឲ្យមានទស្សនវិស័យថ្មីនៃការទូត

---

[202] Résumé des Paroles du Président Nicolae Ceausescu de Roumanie Prononcées lors de Son Entrevue avec Norodom Sihanouk et Khieu Samphan, A Bucarest, en Août 1982.

អន្តរជាតិ ក៏ប៉ុន្តែការចរចាគ្នានេះ បានឲ្យយើងនៅក្នុងជួរ.ស.ជ.រ.ប.ខ. មានការបារម្ភខ្លះដែរ ។ ដោយសារយើងមានការទន់ខ្សោយខាងផ្នែកយោធា យើងក៏មានការព្រួយបារម្ភអំពីដំណោះស្រាយក្រហម ចំពោះបញ្ហាកម្ពុជាគឺថា ប្រសិនបើមហាយក្សកុម្មុយនីស្តចិន-សូវៀតជានាត្រូវរ៉ូវគ្នា គេអាចបែងចែកផលប្រយោជន៍ ដោយច្រានចោលពួកមិនមែនកុម្មុយនីស្តចេញពីឆាកនយោបាយកម្ពុជា ។ ជាមួយនឹងការព្រួយបារម្ភនេះ យើងក៏យកដំណោះស្រាយក្រហមនៅកម្ពុជានេះ ជាប្រធានបទសម្រាប់ការឃោសនានយោបាយ និង ជាលេសស្វែងរកការគាំទ្របន្ថែមពីលោកខាងលិចថែមទៀតផង ។

## ហ៊ុន សែន ថា៖ "វាយផង ចរចាផង"

នៅឆ្នាំ ១៩៨៥ លោកឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ហ៊ុន សែន បានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រី ។ ភ្លាមៗនោះ លោកនាយករដ្ឋមន្ត្រីរូបនេះបានបង្ហាញលក្ខខណ្ឌនៃការបញ្ចប់ជម្លោះនៅកម្ពុជា ដោយសង្កត់ធ្ងន់ទៅលើការវាយរំលំអង្គការចាត់តាំងនយោបាយ និង យោធារបស់ ប៉ុល ពត និង ការផ្សះផ្សាជានាគ្នាជាមួយក្រុម ឬ បុគ្គលដែលទទួលយកក្របខណ្ឌនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន (កាលនោះ លោកមានអាយុ ៣៣ ឆ្នាំ) ប្រាកដជាមើលឃើញថាសត្រូវដ៏ធំនៃរបបរបស់លោកគឺខ្មែរក្រហម ។ ប្រសិនបើខ្មែរក្រហមត្រូវបានវាយកំទេច ក្រុមប្រឆាំងឯទៀតមុខជាងាយផ្តួល ឬ ក៏អាចងាយនឹងផ្សះផ្សាគ្នាបាន ។ មេដឹកនាំខ្មែររូបនេះយល់ច្បាស់ទៀតថា ឧបសគ្គដ៏ធំដែលរារាំងសាធារណរដ្ឋប្រជាមានិតកម្ពុជាមិនឲ្យបានទទួលនូវការទទួលស្គាល់ពីសហគមន៍អន្តរជាតិ គឺវត្តមាននៃកងទ័ពវៀតណាមនៅកម្ពុជា ។ ក៏ប៉ុន្តែលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាន់

គោលជំហរដ៏មុឺងម៉ាត់ថា ប៉ុល ពត បានប្រព្រឹត្តិអំពើប្រល័យពូជសាសន៍មកលើប្រជារាស្ត្រខ្មែរ បើគ្មានអំពើប្រល័យពូជសាសន៍ទេ ក៏គ្មានការរើបំរះក្រោកឈរឡើងប្រឆាំង ប៉ុល ពត ដោយប្រជារាស្ត្រខ្មែរដែរ ។ ឯកងទ័ពវៀតណាមមិនមែនមកឈ្លានពានកម្ពុជានោះទេ តែជាកងទ័ពស្ម័គ្រចិត្តដែលមកជួយប្រជារាស្ត្រខ្មែរដើម្បីផ្តួលរំលំរបបប្រល័យពូជសាសន៍តែប៉ុណ្ណោះ ។ បើគ្មានរបបប្រល័យពូជសាសន៍ ក៏គ្មានវត្តមាននៃកងទ័ពវៀតណាមនេះដែរ ។

គួរកត់សម្គាល់ថា ប្រសិនបើការប្រើកម្លាំងយោធាទៅកាន់កាប់ប្រទេសមួយជាការបំពានលើច្បាប់អន្តរជាតិ អំពើប្រល័យពូជសាសន៍ ក៏ជាអំពើឧក្រិដ្ឋមួយមិនតូចជាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ ។ ដូច្នេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រើយុទ្ធសាស្ត្រវាយដណ្តើមការទទួលស្គាល់អន្តរជាតិ ដោយឈរយ៉ាងមាំលើគោលជំហរដ៏ស្របច្បាប់ប្រឆាំងប្រល័យពូជសាសន៍ ។ ជាមួយគ្នានោះ លោកនាយករដ្ឋមន្ត្រីខ្មែរនៃរដ្ឋាភិបាលភ្នំពេញរូបនេះ បានចងភ្ជាប់ការដកកងទ័ពវៀតណាមជាមួយនឹងការផ្តួលរំលំជាស្ថាពរនៃពួកខ្មែរក្រហម ប៉ុល ពត ។ ព្រមគ្នានឹងការប្រើកម្លាំងយោធា ដើម្បីវាយប្រហារ ប៉ុល ពត រដ្ឋាភិបាលភ្នំពេញក៏បើកយុទ្ធនាការស្វែងរកការចរចាតាមរបៀបដែលហៅថា៖ "វាយផង ចរចាផង" (Fight, fight, talk, talk) – គឺ វាយទប់ទល់ ឬ វាយកំទេចខ្មែរក្រហមផង ឯចរចាគឺ ចរចា ដើម្បីទទួលបាននូវការទទួលស្គាល់ផង ។ នៅសម័យនោះ រដ្ឋាភិបាលក្រុងភ្នំពេញប្រាកដជាភាគីតែមួយគត់ ដែលអាចទទួលផលច្រើនជាងគេពីរាល់កិច្ចចរចានានា ។

## វៀតណាមមិនយកយូអិន តែសុខចិត្តចរចាជាមួយអាស៊ាន

ចាប់តាំងពីឆ្នាំ ១៩៧៩ មក វៀតណាមប្រកែកពុំព្រមទទួលអនុវត្តតាមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ នៅរាល់មហាសន្និបាតប្រចាំឆ្នាំ ។ ក៏

ប៉ុន្តែ ប្រទេសនេះ បានជ្រើសយកវេទិកាតំបន់ ដើម្បីចរចាបញ្ចប់ជម្លោះ ។ ក្រុងហាណូយ ស្នើឲ្យក្រុមប្រទេសអាស៊ានចរចាជាមួយក្រុមប្រទេសឥណ្ឌូចិន (កម្ពុជា នៃរដ្ឋាភិបាល ហ៊ុន សែន - លាវ និង វៀតណាម) ។ ក្រុមប្រទេសអាស៊ានមិនបានទទួលយកសំណើនេះទេ ព្រោះគេជៀសវាងទទួលស្គាល់រដ្ឋាភិបាល ហ៊ុន សែន ។ ជាទូទៅអាស៊ានសង្កត់ធ្ងន់ទៅលើសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ដែលបង្ខំឲ្យមានការដកកងទ័ពបរទេសចេញពីកម្ពុជា ក៏ប៉ុន្តែអាស៊ានក៏មិនបានបិទទ្វារទាំងស្រុងចំពោះការចរចាគ្នានោះទេ ។ អាស៊ានបានទុកឲ្យសមាជិករបស់គេមួយ គឺប្រទេសឥណ្ឌូណេស៊ី ជាអ្នកចរចាផ្ទាល់ជាមួយវៀតណាម ។ នៅក្នុងសម័យនោះ ប្រទេសឥណ្ឌូណេស៊ី បានដើរតួនាទីយ៉ាងសកម្ម ដើម្បីស្វែងរកសន្តិភាព និងស្ថេរភាពនៅក្នុងតំបន់ ។

គួររំលឹកដែរថាចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៦០ មក ប្រទេសឥណ្ឌូណេស៊ីមានការមិនទុកចិត្តចំពោះប្រទេសចិន ក្រោយពេលដែលលោកប្រធានាធិបតី ស៊ូហារតូ ឡើងមកកាន់អំណាច បន្ទាប់ពីបានគាស់រំលើងបណ្តាញចិនកុម្មុយនីស្តចេញពីប្រទេសនេះ ។ តាំងពីពេលនោះមក ឥណ្ឌូណេស៊ីតែងស្វែងរកយ៉ាងប្រយ័ត្នប្រយែងនូវកម្លាំងទប់ចំពោះឥទ្ធិពលចិននៅក្នុងតំបន់ ។ សកម្មភាពរបស់ឥណ្ឌូណេស៊ី ដែលទាក់ទងជាញឹកញាប់ជាមួយវៀតណាម បានធ្វើឲ្យពួកយើងនៅក្នុងជួរ ស.ជ.រ.ប.ខ.ជាដំបូងមានការព្រួយបារម្ភ ហើយបាននាំគ្នាគិតថាគំនិតផ្តួចផ្តើមរបស់ឥណ្ឌូណេស៊ី ហាក់ដូចជាលំអៀងទៅរកវៀតណាម ។ ដូច្នេះ ចំពោះរាល់ការចរចារវាងឥណ្ឌូណេស៊ី និង វៀតណាម រ.ជ.រ.ប.ខ. យើងតែងប្រុងប្រយ័ត្នជានិច្ច ។

តាមធម្មតា រាល់ការជួបចរចាគ្នាតែងតែជាឱកាស នាំឲ្យមានសង្ឃឹមចំពោះសន្តិភាព ក៏ប៉ុន្តែភាគីនិមួយៗ ក៏តែងឆ្លៀតប្រើយុទ្ធសាស្ត្ររបស់គេ ដើម្បីដណ្តើមប្រៀប ឬ ឧត្តមភាពជានិច្ចនៅរាល់ជំនួប ។ ចំពោះរដ្ឋាភិបាល ហ៊ុន សែន គោលដៅ

ចម្បងគឺ ដណ្តើមឲ្យបាននូវការទទួលស្គាល់អន្តរជាតិ ព្រោះថារដ្ឋាភិបាលនេះមានជើងជាន់ជាប់លើទឹកដីខ្មែររួចទៅហើយ អ្វីដែលនៅខ្វះខាតនោះគឺ ការទទួលស្គាល់ជាសកលពីសហគមន៍អន្តរជាតិតែប៉ុណ្ណោះ ។ ការទទួលស្គាល់នេះ ជាការចាំបាច់ដើម្បីបញ្ចប់នូវការឡោមព័ទ្ធខាងផ្នែកការទូត និង សេដ្ឋកិច្ច ។ ចំណែកឯក្រុមប្រឆាំង ជាពិសេសក្រុមលោកតា សឺន សាន និង ខ្មែរក្រហមវិញ ពួកនេះប្រកាន់ឥរិយាបថរឹងត្អឹងគឺ ប្រកែកមិនចរចាជាមួយរដ្ឋាភិបាល ហ៊ុន សែន ដោយប្រកាន់ថា បញ្ហាកម្ពុជា កើតឡើងដោយអំពើឈ្លានពានរបស់វៀតណាម ។ ដូច្នេះបញ្ហាសង្គ្រាមនៅកម្ពុជាជាសង្គ្រាមឈ្លានពានរវាងវៀតណាម និង កម្ពុជាប្រជាធិបតេយ្យ មិនមែនជាសង្គ្រាមស៊ីវិលរវាងខ្មែរ និង ខ្មែរនោះទេ ។ ក្រុមប្រឆាំងយល់ថា បើនិយាយចរចាជាមួយរដ្ឋាភិបាល ហ៊ុន សែន បានន័យថានៅកម្ពុជាមានរដ្ឋាភិបាលពីរគឺ រដ្ឋាភិបាលចម្រុះត្រីភាគីមួយ និង រដ្ឋាភិបាល ហ៊ុន សែន នៅភ្នំពេញមួយ ដែលអាចនាំទៅរកការបែងចែកទឹកដីខ្មែរជាពីរយ៉ាងដូច្នោះដែរ ។ ដូច្នេះហើយ ទើបរដ្ឋាភិបាលចម្រុះត្រីភាគីទាមទារចរចាផ្ទាល់ជាមួយវៀតណាម ។ ក៏ប៉ុន្តែវៀតណាមក៏ប្រាកដជាមិនអាចមកអង្គុយនិយាយជាមួយរដ្ឋាភិបាលចម្រុះត្រីភាគីបានដែរ ព្រោះថាបើមកអង្គុយចរចា គេនឹងត្រូវទទួលស្គាល់ថា ខ្លួនគេជាអ្នកឈ្លានពានកម្ពុជា មិនមែនមកជួយផ្តួលរំលំរបបប្រល័យពូជសាសន៍ តាមសំណូមពររបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានោះឡើយ ។ គោលជំហរទាំងសងខាងនេះមានលក្ខណៈផ្ទុយគ្នាទាំងស្រុង ដែលពិបាកនឹងកែសម្រួលណាស់ ។

គួររំលឹកថា ចាប់ពីចុងឆ្នាំ ១៩៨៥ មក រ.ជ.រ.ប.ខ. បានត្រូវជាប់ជំពាក់ក្នុងបញ្ហាបែកបាក់ផ្ទៃក្នុងយ៉ាងខ្លាំងក្លា ដែលធ្វើឲ្យចលនានេះអស់លទ្ធភាពផ្តួចផ្តើមគំនិតនយោបាយអ្វីមួយបានឡើយ ។ លោកតា សឺន សាន ចំណាយពេលវេលា និង ឋាមពលជាច្រើន ដើម្បីវាយបកទៅក្រុមឧត្តមសេនីយ សក់ ស៊ុតសាខន និង ដៀន

ដែល ក្នុងការដណ្តើមយកអំណាចដឹកនាំរ.ជ.រ.ប.ខ.មកវិញ ។ សូមរំលឹកដែរថា ពួកឧត្តមសេនីយបានចោទប្រកាន់លោកតា សឺន សាន ថា ធ្វើការដឹកនាំតាមបែបផ្តាច់ការ និង គ្រួសារនិយម ព្រមទាំងនៅអល់អែកក្នុងការចូលរួមជាមួយចលនារបស់សម្តេច សីហនុ ។ ចំណែកឯខ្លួនខ្ញុំផ្ទាល់ (អៀង មូលី) ក៏បានចំណាយពេលវេលាជាអតិបរមា ដើម្បីជួយពង្រឹងឥទ្ធិពល និង ការដឹកនាំរបស់លោកតា សឺន សាន ក្នុងការរៀបចំបណ្តាញទំនាក់ទំនងផ្ទាល់ជាមួយមេបញ្ជាការយោធា និង មេជំរុំជនភៀសខ្លួនឲ្យគាំទ្រលោកតាប្រធាន ។ និយាយជារួម រ.ជ.រ.ប.ខ.ស្ទើរបាត់ម្ចាស់ការអស់ទៅហើយ ។ នៅពេលជួបអ្នកតំណាងប្រទេសផ្តល់ជំនួយម្តងៗ លោកតា សឺន សាន គ្មានបានផ្តល់គំនិតអ្វីក្រៅពីសុំអង្វរករម្ចាស់ជំនួយឲ្យជួយផ្តល់អំណាចយោធាមកលោកតាវិញតែប៉ុណ្ណោះ ។

មែនទែន ទាំងប្រទេសឥណ្ឌូចិន (វៀតណាម - លាវ - កម្ពុជានៃរដ្ឋាភិបាល ហ៊ុន សែន) តាមរយៈសន្និសីទនៃរដ្ឋមន្ត្រីការបរទេស ទាំងក្រុមប្រទេសអាស៊ាន សុទ្ធតែបានបង្ហាញនូវសំណើដំណោះស្រាយសន្តិភាពរៀងៗខ្លួន ។ ចាប់ពីថ្ងៃទី ២៣ ទៅ ២៤ មករា ១៩៨៦ នៅទីក្រុងវៀងច័ន្ទនៃប្រទេសលាវ សន្និសីទលើកទី ១២ នៃរដ្ឋមន្ត្រីការបរទេសនៃក្រុមប្រទេសឥណ្ឌូចិន បានគូសបញ្ជាក់នូវទិដ្ឋភាពពីរនៃបញ្ហាកម្ពុជា[203]គឺ៖ ទិដ្ឋភាពផ្ទៃក្នុងតម្រូវឲ្យមានការចរចាផ្ទាល់រវាងភាគីខ្មែរដែលមានមូលដ្ឋានលើការផ្តួលរំលំបនប្រល័យពូជសាសន៍ ប៉ុល ពត ដោយគ្មានការលូកដៃពីប្រទេសដទៃ ដើម្បីសម្រេចទៅរកការព្រមព្រៀងបោះឆ្នោតជាទូទៅមួយបន្ទាប់ពីមានការដកកងទ័ពវៀតណាម និង ទិដ្ឋភាពផ្នែកខាងក្រៅតម្រូវឲ្យមានការដកកងទ័ពវៀតណាមចេញ ដែលត្រូវចងភ្ជាប់ជាមួយការកាត់ផ្តាច់ជំនួយក្រៅប្រទេសដល់ភាគីខ្មែរទាំងអស់ ។ ក្រុមប្រទេសឥណ្ឌូចិនស្វាគមន៍ការបន្តការចរចាគ្នា

[203] Douzième Conférence des Ministres des Affaires Etrangères du Cambodge, du Laos et du Vietnam tenue à Vientiane, Laos, du 23 au 24 Janvier 1986, Points à retenir.

តទៅទៀតរវាងវៀតណាម និង ឥណ្ឌូណេស៊ី ក៏ប៉ុន្តែ ក្រុមប្រទេសឥណ្ឌូចិនទាំងបី ធ្វើសំណូមពរថា រាល់ការចរចាខាងមុខគួរឲ្យមានការចរចារវាងក្រុមឥណ្ឌូចិនផ្ទាល់ ជាមួយក្រុមអាស៊ាន ។ ក្រុមប្រទេសទាំងបី ធ្លាប់បានប្រកាសប្រាប់ពិភពលោកថា វៀតណាម នឹងដកកងទ័ពចេញពីកម្ពុជាឲ្យអស់នៅឆ្នាំ ១៩៩០ ។ ដោយសារបញ្ហា កម្ពុជាត្រូវបានបំបែកចេញជាពីរពីទិដ្ឋភាពយ៉ាងនេះ ទើបលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានលទ្ធភាពដោះស្រាយទិដ្ឋភាពនីមួយៗនៃបញ្ហាកម្ពុជាទីទៃពីគ្នា ដោយមិន ឲ្យទិដ្ឋភាពមួយមកជាប់ជំពាក់ទិដ្ឋភាពមួយទៀតធ្វើជាឧបសគ្គ ដែលអាចនាំឲ្យរាំង ស្ទះដល់ដំណោះស្រាយទាំងមូល ។ ម្យ៉ាងទៀត ដោយបានចង្អុលបង្ហាញពីរយៈ ពេលវេលាច្បាស់លាស់នៃការដកកងទ័ពវៀតណាមចេញពីកម្ពុជា (ចាប់ផ្តើមពីឆ្នាំ ១៩៨៦ និង អស់ទាំងស្រុងនៅឆ្នាំ ១៩៩០) ក្រុមប្រទេសឥណ្ឌូចិនបានធ្វើឲ្យ ដង្កាប់នៃការគាបសង្កត់របស់សហគមន៍អន្តរជាតិបានត្រូវបន្ធូរបន្ថយទៀតផង ។

ចំណែកក្រុមប្រទេសអាស៊ានក៏បានស្នើឡើងនូវបែបបទបញ្ចប់ជម្លោះដែរ ។ ជាទូទៅ បែបបទបញ្ឈប់ជម្លោះនៃក្រុមប្រទេសទាំងនេះ គាំទ្រគោលការណ៍ទាំង ឡាយ ដែលមានចែងក្នុងសេចក្តីថ្លែងការណ៍របស់សន្និសីទអន្តរជាតិស្តីពីកម្ពុជា (ICK)ដែលមានចំណុចសំខាន់ៗគឺ៖ ការឈប់បាញ់គ្នាដើម្បីឲ្យកងទ័ពបរទេសដក ចេញពីកម្ពុជា ក្រោមការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ដោយអង្គការសហប្រជាជាតិ- ការរៀបចំបោះឆ្នោតដោយសេរី ឬ ការប្រើសិទ្ធិស្វ័យសម្រេចក្រោមការត្រួតពិនិត្យ របស់អង្គការសហប្រជាជាតិ- ការស្តាបនាឡើងវិញ និង ការគោរពឯករាជ្យ បូរណ ភាពទឹកដី អធិបតេយ្យ និង អព្យាក្រឹតភាពជាតិរបស់កម្ពុជា - កម្មវិធីជួយកសាង ឡើងវិញនូវសេដ្ឋកិច្ចជាតិកម្ពុជា និង ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមនៃប្រទេស នៅក្នុងតំបន់ ។

# អាស៊ានឲ្យត្រីភាគីពង្រឹងឯកភាព និង សាមគ្គីភាព

នៅសម័យនោះ ក្រុមប្រទេសអាស៊ានបានផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលចម្រុះត្រីភាគីឲ្យខិតខំពង្រឹងសមត្ថភាពយោធា ជៀសវាងការប៉ះទង្គិចផ្ទៃក្នុង បង្កើនការពិភាក្សាពិគ្រោះយោបល់គ្នា ពង្រីកសហប្រតិបត្តិការគ្រប់វិស័យ សម្របសម្រួលសកម្មភាពនៅលើសមរភូមិ ជាពិសេសពង្រីកសកម្មភាពសង្គ្រាមចិត្តសាស្ត្រឲ្យធំទូលាយទៀត ។ ក្រុមប្រទេសអាស៊ាន ប្រមើលមើលថា ក្នុងរយៈពេល ១៨ ខែ គិតតាំងពីដើមឆ្នាំ ១៩៨៦ នេះទៅ ប្រសិនបើកងទ័ពត្រីភាគីអាចទប់ទល់បាន ឬអាចវាយបកទៅលើកងទ័ពវៀតណាម និង ទៅលើកងទ័ពរដ្ឋាភិបាល ហ៊ុន សែន បាននោះ គេអាចសន្មត់ថាវៀតណាមប្រាកដជាសុខចិត្តចូលមកចរចា ដើម្បីដកកងទ័ពចេញពីកម្ពុជាមិនខានឡើយ ។ គោលជំហរអាស៊ាននៅពេលនោះ មានសភាពទន់ភ្លន់ជាងគោលជំហរខ្មែរក្រហម និង គោលជំហរចិន ព្រោះក្រុមអាស៊ានមិនទាមទារឲ្យកងទ័ពវៀតណាមចេញទាំងអស់ មុននឹងមានការចរចាគ្នានោះឡើយ ។

ចំណុចសំខាន់ៗនៃបែបបទរបស់អាស៊ាននាពេលនោះ មានដូចតទៅៈ -ការដកកងទ័ពវៀតណាមជាតំណាក់ៗ ព្រមជាមួយនឹងការឈប់បាញ់គ្នា ដែលចាប់ផ្តើមចេញពីតំបន់ទល់ដែនថៃ-កម្ពុជា -ជាមួយនឹងការដកកងទ័ពទាំងស្រុង កងកម្លាំងកម្ពុជាទាំងអស់ត្រូវទំលាក់អាវុធ -ត្រូវបង្កើតជាតំបន់សុវត្ថិភាពនៅទីណាដែលមានការដកកងទ័ព -ធ្វើមាតុភូមិនិវត្តន៍ជនភៀសខ្លួនកម្ពុជាក្រោមការត្រួតពិនិត្យរបស់ឧត្តមស្នងការសហប្រជាជាតិខាងជនភៀសខ្លួន(UNHCR) -បង្កើតតំបន់អត់មានយោធា (Dimilitarised Zone) នៅលើទល់ដែនខាងទឹកដីកម្ពុជានៅចន្លោះប្រទេសជិតខាង និង នៅតាមមាត់សមុទ្រ -បង្កើតគណៈកម្មការត្រួតពិនិត្យអន្តរជាតិ ដើម្បីត្រួតពិនិត្យរាល់ទិដ្ឋភាពនៃការអនុវត្តដំណោះស្រាយនយោ

បាយ ។ នៅក្នុងរយៈពេលឆ្លងកាត់ ឬ អន្តរកាល ក្រុមប្រទេសអាស៊ានស្នើឲ្យបង្កើតរដ្ឋាភិបាលផ្សះផ្សាជាតិបណ្តោះអាសន្នមួយ[204] ដែលស្ថិតនៅក្រោមការដឹកនាំរបស់សម្តេច សីហនុ ។ រដ្ឋាភិបាលបណ្តោះអាសន្ននេះ នឹងធ្វើជារដ្ឋបាលបណ្តោះអាសន្នជំនួសឲ្យរដ្ឋបាលរបស់រដ្ឋាភិបាលចម្រុះត្រីភាគីផង និង រដ្ឋបាលនៃរដ្ឋាភិបាល ហ៊ុន សែន នៅភ្នំពេញផង ។ ក្នុងរដ្ឋាភិបាលនេះ សមាសភាពចូលរួមមានចំនួនស្មើគ្នានៃភាគីនីមួយៗក្នុងរដ្ឋាភិបាលត្រីភាគី និង ភាគី ហេង សំរិន/ហ៊ុន សែន ។

តាមសំណើនេះ អាស៊ានបានទទួលយករដ្ឋាភិបាលភ្នំពេញថាជាភាគីមួយស្រេចទៅហើយ ក្នុងការចរចាស្វែងរកសន្តិភាពសម្រាប់កម្ពុជា ។ គួរឲ្យកត់សម្គាល់ដែរថា ក្រុមប្រទេសអាស៊ានមិនបាននិយាយឲ្យចំថារដ្ឋាភិបាលបណ្តោះអាសន្ននេះជារដ្ឋាភិបាលចតុភាគីទេ តែថាជារដ្ឋាភិបាលជាតិបណ្តោះអាសន្ន ។ បានន័យថាបើសិនជាមានការព្រមព្រៀងគ្នារវាងភាគីខ្មែរ រដ្ឋាភិបាលនេះមិនបាច់មានខ្មែរក្រហមក៏បានដែរ ។

នៅពេលដែលក្រុមប្រទេសអាស៊ាន ស្នើឲ្យមានការពង្រឹងឯកភាព សាមគ្គីភាពក្នុងជួររដ្ឋាភិបាលចម្រុះត្រីភាគីនោះ រដ្ឋាភិបាលនេះត្រូវបានទទួលរងនូវការបែកបាក់យ៉ាងខ្លាំង ទាំងដោយសារការដណ្តើមឧត្តមភាពខាងផ្នែកយោធាពីសំណាក់ខ្មែរក្រហមលើដៃគូពីរទៀតរបស់ខ្លួនផង ទាំងការបែកបាក់ផ្ទៃក្នុងនៃរណសិរ្សមិនមែនកុម្មុយនីស្តទាំងពីរផង ។ នៅថ្ងៃទី ៦ កុម្ភៈ ១៩៨៦ លោកអនុរដ្ឋមន្ត្រីក្រសួងការបរទេសថៃ អារុណ ផានុពង្ស[205] ដោយមានលោកឯកអគ្គរាជទូតថៃឈ្មោះឆាវ៉ាត់ អមផង បានជួបប្រជុំជាមួយតំណាងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យដែលមានជាអាទិ៖ លោក ខៀវ សំផន លោក សុន សេន (តំណាងខ្មែរក្រហម)

---

[204] ឯកសារសម្ងាត់ Asean Suggested Modalities for Political Settlement of the Kampuchean Problem, February 3, 1986.

[205] ឯកសារសម្ងាត់ រ.ជ.រ.ប.ខ. Compte-rendu de la Réunion au Ministère des Affaires Étrangères, Bangkok, le 6 Février 1986.

លោក នាង ជិនហន លោក ប៊ុន សាយ លោក សឺន ស៊ូប៉ែរ្ត៍ (តំណាង រ.ជ.រ.ប.ខ) និង លោក ចក់ សារិ លោក ប៉ែន ដារ៉េត (តំណាង ហ៊្វុន ស៊ិន ប៉ិច) ដើម្បីសុំឲ្យភាគីខ្មែរទទួលយកបែបបទដំណោះស្រាយរបស់អាស៊ានមកពិនិត្យ និង ផ្តល់មតិមុនអាស៊ានលើកឡើងជាស្ថាពរ ។ នៅក្នុងជំនួបនោះ មន្ត្រីការទូតជាន់ខ្ពស់ថៃ ឆាវ៉ាត់ បានសុំឲ្យទាំងរ.ជ.រ.ប.ខ. ទាំងហ៊្វុន ស៊ិន ប៉ិច ខិតខំបញ្ចប់ជម្លោះផ្ទៃក្នុងឲ្យបានឆាប់ ព្រោះជៀសវាងកុំឲ្យមជ្ឈដ្ឋានខាងក្រៅយល់ថា ការតស៊ូរបស់យើងទាំងអស់គ្នាជាការឥតប្រយោជន៍ ។

មែនទែនកាលនោះ ខ្ញុំមិនបានយល់ដឹងឲ្យស៊ីជម្រៅ ពីជម្លោះផ្ទៃក្នុងនៅក្នុងជួរហ៊្វុន ស៊ិន ប៉ិចទេ ខ្ញុំដឹងតែបញ្ហារវាងលោកតា សឺន សាន និង ក្រុមឧត្តមសេនីយ សក់ ស៊ុតសាខន ក្នុងជួរ រ.ជ.រ.ប.ខ.តែប៉ុណ្ណោះ ។ ក៏ប៉ុន្តែ តាមរយៈសារព័ត៌មាន ខ្ញុំអាចកាត់ស្មានថាមានការខ្វែងគំនិតគ្នារវាងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ព្រះរាជបុត្ររបស់សម្តេច សីហនុ ដែលជាឧត្តមមេបញ្ជាការ និង លោកឧត្តមសេនីយ ទៀប បែន ដែលជាអគ្គមេបញ្ជាការនៃកងទ័ពសីហនុនិយម (ANS) ។ ពួកយើងដែលនៅជុំវិញលោកតា សឺន សាន បានគិតថាបញ្ហានៅក្នុង ហ៊្វុន ស៊ិន ប៉ិច ក៏មិនខុសពីទំនាស់ផ្ទៃក្នុងរបស់រ.ជ.រ.ប.ខ.ឡើយ ។ យើងយល់ថា ក្រុមឧត្តមសេនីយថៃមានផែនការកាត់ផ្តាច់បញ្ជាការរបស់កងទ័ពសីហនុនិយម ឲ្យមកស្ថិតនៅតែក្រោមឧត្តមសេនីយ ទៀប បែន ដើម្បីឲ្យមេដឹកនាំយោធាថៃអាចប្រើប្រាស់កងទ័ពនេះបានដោយស្រួល ។ ដោយសារធ្លាប់មានជម្លោះផ្ទៃក្នុងជាមួយលោកឧត្តមសេនីយ សក់ ស៊ុតសាខន ដែលប៉ុនប៉ងកាត់ផ្តាច់កងទ័ពរ.ជ.រ.ប.ខ ឲ្យផុតពីការដឹកនាំរបស់លោកតាៗប្រធាន សឺន សាន បានផ្ញើសារទូរលេខមួយច្បាប់ចុះថ្ងៃទី ៨ កុម្ភៈ

១៩៨៦[206] ទៅថ្វាយសម្តេច សីហនុ អំពីបទពិសោធន៍មិនល្អនៅក្នុងជួរ រ.ជ.រ.ប.ខ. និង អំពីជំនឿរបស់លោកតាប្រធានថា សម្តេចអាចដោះស្រាយបញ្ហាផ្ទៃក្នុងនៃកងទ័ពសីហនុនិយមនេះបាន ។ ជាមួយនោះ លោកតា សឺន សាន ក៏សូមថ្លែងថ្វាយនូវការដឹងគុណចំពោះព្រះអង្គដែលបានគាំទ្រលោកតាដែរ នៅក្នុងជម្លោះផ្ទៃក្នុងៗជួរ រ.ជ.រ.ប.ខ. ។

នៅថ្ងៃទី ១២ កុម្ភៈ ១៩៨៦ ទំនងជាចង់ឆ្លើយតបទៅក្រុមប្រទេសអាស៊ានថា រដ្ឋាភិបាលចម្រុះត្រីភាគីមានសាមគ្គីភាពល្អរវាងគ្នា និង គ្នា លោក ខៀវ សំផន និង សុន សេន ក្នុងនាមកម្ពុជាប្រជាធិបតេយ្យ បានចេញសេចក្តីថ្លែងការណ៍មួយដើម្បីគាំទ្រសម្តេច សីហនុ និង មួយទៀត ដើម្បីគាំទ្រលោក តា សឺន សាន ដែលកំពុងប្រឈមមុខចំពោះជម្លោះផ្ទៃក្នុង ។ ទាក់ទងនឹងហ្ស៊ុន ស៊ិន ប៉ិច[207] ខ្មែរក្រហមប្រកាសថា នៅពេលបច្ចុប្បន្នពួកគេទទួលស្គាល់សម្តេច នរោត្តម សីហនុ ជាប្រធានកម្ពុជាប្រជាធិបតេយ្យ និង នៅពេលខាងមុខក៏ពួកគេនឹងទទួលស្គាល់សម្តេចជាប្រធាននៃកម្ពុជា ។ ម្យ៉ាងទៀត នៅក្នុងសេចក្តីថ្លែងការណ៍នោះ ខ្មែរក្រហមក៏បានបញ្ជាក់នៅចំពោះមតិជាតិ និង អន្តរជាតិថាកម្ពុជាប្រជាធិបតេយ្យ នឹងខិតខំសម្រេចឲ្យបាននូវមហាសាមគ្គីភាពជាតិ នៅក្នុងក្របខ័ណ្ឌនៃរបបមូលធននិយម និង សភានិយម ដែលផ្ទុយស្រឡះពីរបបប្រល័យពូជសាសន៍ កាលពីពេលពួកនេះកាន់អំណាចពីឆ្នាំ ១៩៧៥ ទៅ ១៩៧៩ ។

ចំពោះការគាំទ្រដល់លោកតា សឺន សាន និង រ.ជ.រ.ប.ខ.វិញ ពួកខ្មែរ

[206] Son Sann, Télégramme à Son Altesse Royale Samdech Preah Norodom Sihanouk, le 8 Février 1986.
[207] Khieu Samphan, Son Sen, Statement By The Democratic Kampuchea Party concerning its Position vis-à-vis the Present and Future Role of Samdech Norodom Sihanouk and The National United Front For an Independent Neutral Peaceful and Cooperative Cambodia (FUNCINPEC), Democratic Kampuchea, February 12, 1986.

ក្រហមតាមរយៈលោក ខៀវ សំផន និង សុន សេន បានថ្លែងយ៉ាងខ្លីថាៈ[208] "ភាគីកម្ពុជាប្រជាធិបតេយ្យ ចាត់ទុករណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ និង ប្រធានរបស់ខ្លួន ជាកម្លាំងនយោបាយរបស់ជាតិមួយ ទាំងបច្ចុប្បន្ន ទាំងអនាគត" ។ បើប្រៀបធៀបការគាំទ្ររបស់ខ្មែរក្រហមចំពោះសម្តេច សីហនុ ការគាំទ្ររបស់ខ្មែរក្រហម ចំពោះលោកតា សឺន សាន មិនបានបញ្ចេញឲ្យបានច្បាស់លាស់ប៉ុន្មានទេ ។ ពួកគេគាំទ្ររ.ជ.រ.ប.ខ. និង ប្រធានរបស់ខ្លួនគឺ គេមិនបានបញ្ជាក់ថានរណាជាប្រធានរ.ជ.រ.ប.ខ.ទេ នៅពេលដែលលោកឧត្តមសេនីយ សក់ ស៊ុតសាខន កំពុងទាមទារអំណាចដឹកនាំរ.ជ.រ.ប.ខ.ជំនួសលោកតា សឺន សាន ។ ពួកគេអាចគាំទ្រលោក សក់ ស៊ុតសាខន ជាប្រធានក៏បាន លោកតា សឺន សាន ជាប្រធានក៏បាន ។ ទាំងនេះ ក៏ប្រហែលជាពួកខ្មែរក្រហម មិនចង់ឲ្យមានការប៉ះទង្គិចជាមួយក្រុមឧត្តមសេនីយថៃផង ឬ ក៏ចង់បំពេញចិត្តមេទ័ពថៃផងក៏ថាបាន ។ នៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្មែរក្រហមនោះ ពួកគេមិនបានចែងគាំទ្រលោកតា សឺន សាន ក្នុងឋានៈជារដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យនោះទេ ឬ សំដែងមតិចំពោះតួនាទីរបស់លោកតា សឺន សាន នាពេលអនាគតឡើយ ។

នៅបន្ទាត់ជាបន្តបន្ទាប់នេះ ខ្ញុំសូមបកមកក្រោយបន្តិចដើម្បីលើកយកបញ្ហាផ្ទៃក្នុង និង ការពាក់ព័ន្ធនយោបាយមកអធិប្បាយ ។ បញ្ហាផ្ទៃក្នុងរបស់ រ.ជ.រ.ប.ខ.មានការស្មុគ្រស្មាញជាងបញ្ហានៅក្នុងជួរ ហ៊្វុន ស៊ិន ប៉ិច ដោយហេតុថា នៅក្នុងជួរហ៊្វុន ស៊ិន ប៉ិច គ្មានបុគ្គលណា ឬ ក្រុមណាហ៊ានបំពាន ឬ រំលោភលើការដឹកនាំរបស់សម្តេច សីហនុ ជាដាច់ខាត ។ ផ្ទុយទៅវិញ នៅក្នុងជួររ.ជ.រ.ប.ខ. ក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន ហ៊ានចេញមុខប្រឆាំងនឹងការដឹកនាំ

---

[208] ខៀវ សំផន, សុន សេន, សេចក្តីថ្លែងការណ៍របស់ភាគីកម្ពុជាប្រជាធិបតេយ្យចំពោះតួនាទីបច្ចុប្បន្ន និង អនាគតរបស់រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរនិងប្រធានរបស់ខ្លួន, កម្ពុជាប្រជាធិបតេយ្យថ្ងៃទី ១២ កុម្ភៈ ១៩៨៦ ។

របស់លោកតា សឺន សាន រួចទាមទារឲ្យលោកតាដើរតួនាទីត្រឹមតែប្រធានកិត្តិយសតែប៉ុណ្ណោះ ។ ប្រការដែលពិបាកដោះស្រាយនោះគឺ ទោះបីជាលោកតា សឺន សាន បានបញ្ឈប់លោកឧត្តមសេនីយ សក់ ស៊ុតសាខន ពីមុខតំណែងអគ្គមេបញ្ជាការនៃ ក.ជ.រ.ប.ខ.ក៏ដោយ ក៏ក្រុមប្រទេសអាស៊ាន ជាពិសេស ប្រទេសថៃនៅតែទទួលស្គាល់លោកឧត្តមសេនីយ សក់ ស៊ុតសាខន ថាជាមេដឹកនាំកំពូលមួយរូបនៃរ.ជ.រ.ប.ខ.ក្នុងផ្នែកយោធាដដែល ។

នៅថ្ងៃទី ១២ កុម្ភៈ ១៩៨៦ លោកតា សឺន សាន អមដោយលោក ប៊ុន សាយ លោក នាង ជិនហន និង លោក សឺន ស៊ូបែរ្ត៍ បានជួបសន្ទនាការងារជាមួយលោក អារុណ ផានុពង្ស អនុរដ្ឋមន្ត្រីក្រសួងការបរទេសថៃ ដើម្បីប្តូរយោបល់គ្នាលើសំណើបែបបទដំណោះស្រាយរបស់អាស៊ាន[209] ។ នៅក្នុងជំនួបនោះ ជាដំបូងលោកតា សឺន សាន បានសំដែងមតិថាវៀតណាមមិនចង់ចរចាទេ ដូច្នេះលោកតាយល់ថា មិត្តភក្តិកំពុងស្វែងរកកលយុទ្ធ ដើម្បីបង្ខំវៀតណាមឲ្យមកកាន់តុចរចា ។ បន្ទាប់មក លោកតាឆ្លៀតសុំទាមទារអំណាចយោធា ។ លោកតាប្រធាន រ.ជ.រ.ប.ខ. បានថ្លែងថារយៈពេល ១៨ ខែ ជារយៈពេលខ្លីណាស់ នៅពេលដែលពួកយើងកំពុងខាតពេលវេលាដ៏មានតម្លៃដោយសារវិបត្តិផ្ទៃក្នុង ។ លោកតា សឺន សាន បានជម្រាបដៃគូសន្ទនាថា លោកតាបើកទ្វារចំហរជានិច្ចសម្រាប់ដំណោះស្រាយផ្ទៃក្នុងណាមួយ ដោយបានទាមទារថាក្នុងឋានៈជាប្រធានរ.ជ.រ.ប.ខ. លោកតាត្រូវតែមានសិទ្ធិលើកិច្ចការនយោបាយ ការទូត កិច្ចការស៊ីវិល និង ហិរញ្ញវត្ថុ ។ ម្យ៉ាងទៀតចាប់តាំងពីថ្ងៃ ១ កុម្ភៈ ១៩៨៦ រហូតមក លោកតាបានចេញសេចក្តីសម្រេចថា គណៈកម្មាធិការបណ្តោះអាសន្នដែលហៅថា ភីស៊ីស៊ីអេស របស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអង្គការចាត់តាំងខុសច្បាប់ ។ ឆ្លើយតបទៅលោកតា សឺន សាន

[209] ឯកសារសម្ងាត់ រ.ជ.រ.ប.ខ. Meeting at the Thai Ministry of Foreign Affairs, Bangkok, February 12, 1986.

អ្នកការទូតជាន់ខ្ពស់ថៃគ្រាន់តែឆ្លើយថា ពួកគេជាមិត្តតែគេមិនអាចជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់មិត្តទេ ។ រាល់ជំនួបនៅពេលក្រោយៗទៀតជាមួយប្រទេសផ្តល់ជំនួយ លោកតា សឺន សាន តែងយកវេទិកានៃជំនួបនោះ ដើម្បីសុំឲ្យគេជួយផ្តល់អំណាចបញ្ជាលើកងកម្លាំងយោធារបស់ រ.ជ.រ.ប.ខ. មកឲ្យលោកតាវិញ មិនដែលខានឡើយ ។

នៅថ្ងៃទី ១៧ កុម្ភៈ ១៩៨៦ ក្រុមប្រទេសអាស៊ានបានជួបជាមួយតំណាងរដ្ឋាភិបាលចម្រុះត្រីភាគីម្តងទៀត ដើម្បីចង់បានប្រតិកម្មអំពីសំណើបែបបទដំណោះស្រាយកម្ពុជា[210] ។ ខាងកម្ពុជាប្រជាធិបតេយ្យមានលោក ខៀវ សំផន លោក សុន សេន ខាង ហ្វ៊ុន ស៊ិន ប៉ិច មានព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ចំណែកឯខាង រ.ជ.រ.ប.ខ. មានលោក នាង ជិនហន លោក ប៊ុន សាយ និង លោក សឺន ស៊ូប៉ែរ្ត ជាតំណាងចូលរួម គ្មានខាងលោក សក់ ស៊ុតសាខន ឬ តំណាងចូលរួមទេ ។ ឆ្លើយតបទៅសំណួររបស់អាស៊ាន លោក ខៀវ សំផន ឆ្លើយថាពុំទាន់អាចមានចម្លើយជាស្ថាពរទេ ដោយហេតុអវត្តមានរបស់សម្តេច សីហនុ និង លោករដ្ឋមន្ត្រីទី១ សឺន សាន ។ ក៏ប៉ុន្តែជាជំហររបស់កម្ពុជាប្រជាធិបតេយ្យ រាល់ការចរចាណាមួយ ត្រូវធ្វើឡើងរវាងអ្នកឈ្លានពាន គឺវៀតណាមផ្ទាល់ជាមួយអ្នករងគ្រោះ គឺកម្ពុជាប្រជាធិបតេយ្យ ។ ខ្មែរក្រហមចង់និយាយផ្ទាល់ជាមួយវៀតណាម ។ គេយល់ថាវិធីគាបសង្កត់វៀតណាមឲ្យចូលមកចរចា ត្រូវធ្វើតាមរយៈ ការបង្កើនសកម្មភាពយោធា ដោយសហការយ៉ាងជិតស្និទ្ធជាមួយដៃគូពីរទៀតនៅក្នុងរដ្ឋាភិបាលចម្រុះត្រីភាគី ។ ចំណែកឯខាង រ.ជ.រ.ប.ខ.វិញ បានប្រកាសចូលរួមជាមួយអាស៊ានក្នុង

[210] Khmer People's National Liberation Front, Compte-rendu de la Réunion entre les parties du CGDK et les "Senior Officials" des Pays de l'ASEAN, Hotel Ambassador, Bangkok, le 17 Février 1986.

ការស្វែងរកដំណោះស្រាយបញ្ចប់សង្គ្រាម តាមរយៈការចរចាក្នុងសន្និសីទអន្តរជាតិ ក្នុងក្របខ័ណ្ឌនៃសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ និង តាមសេចក្តីថ្លែងការណ៍របស់សន្និសីទអន្តរជាតិស្តីពីកម្ពុជា កាលពីខែ កក្កដា ១៩៨១ ។ ក៏ប៉ុន្តែ រ.ជ.រ.ប.ខ. ប្រកាន់ថា រាល់ការចរចាត្រូវជៀសវាងកុំឲ្យមានការ ទទួលស្គាល់របស់ដែលបានបង្កើតឡើង ដោយការឈ្លានពានរបស់វៀតណាម ។ និយាយរួមគោលជំហរទាំងខ្មែរក្រហម ទាំងរ.ជ.រ.ប.ខ. មិនមានការកែប្រែអ្វីឡើយ ។

នៅថ្ងៃទី ១៨ កុម្ភៈ ១៩៨៦ ក្រុមប្រទេសអាស៊ាន បានជួបជាមួយតំណាង ក្រុមចលនាតស៊ូមិនមែនកុម្មុយនីស្ត រ.ជ.រ.ប.ខ. និង ហ៊្វុន ស៊ិន ប៉ិច[211] ។ នៅក្នុង ជំនួបជាមួយក្រុមប្រទេសអាស៊ាននាពេលនោះ ទោះបីជាលោកឧត្តមសេនីយ សក់ ស៊ុតសាខន ត្រូវបានលោកតា សឺន សាន បញ្ឈប់ពីតំណែងអគ្គមេបញ្ជាការក.ជ.រ .ប.ខ.ទៅហើយយ៉ាងណាក៏ដោយ លោកឧត្តមសេនីយរូបនេះក៏ត្រូវបានអញ្ជើញឲ្យ ចូលរួមប្រជុំ និង ដើរតួនាទីជាមេដឹកនាំយោធានៃចលនាមិនមែនកុម្មុយនីស្ត រួមជា មួយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ។ ទាំងលោកឧត្តមសេនីយ សក់ ស៊ុតសាខន ទាំងព្រះអង្គម្ចាស់ រណឫទ្ធិ សុទ្ធតែបានថ្លែងពីការរីកចំរើនរបស់កងទ័ពនីមួយៗនៅ ក្នុងផ្ទៃប្រទេស ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន បាននិយាយពីកិច្ចសហ ការគ្នាល្អ នៅលើសមរភូមិរវាងកងទ័ពទាំងបីនៃរដ្ឋាភិបាលចម្រុះ ចំណែកឯព្រះអង្គ ម្ចាស់ រណឫទ្ធិ មានបន្ទូលពីការជួយទំនុកបំរុង និង សហការមួយចំនួនពីកងទ័ព រដ្ឋាភិបាលភ្នំពេញ ចំពោះកងទ័ពសីហនុនិយម ។ នៅពេលនោះ អ្នកតំណាងអា ស៊ានបានណែនាំឲ្យបង្កើនការឃោសនា និង សង្កត់ធ្ងន់លើផែនការនយោបាយ និង ការទូត ។ តាមរយៈជំនួបនេះ ក្រុមអាស៊ានបានបង្ហាញឲ្យឃើញយ៉ាងច្បាស់នូវការ

[211] ឯកសារ រ.ជ.រ.ប.ខ. Compte-rendu de la réunion entre les parties nationales du CGDK et les pays de l’Asean sur la question militaire, le 18 Février 1986.

គាំទ្រចំពោះលោកឧត្តមសេនីយ សក់ ស៊ុតសាខន ទោះជាមានការមិនពេញចិត្តពីលោកតា សឺន សាន យ៉ាងណាក៏ដោយ ។

## ផែនការសន្តិភាព ៨ ចំណុចរបស់ត្រីភាគី

ចាប់តាំងពីថ្ងៃទី ១៥ ដល់ ២១ មីនា ១៩៨៦ លោកតា សឺន សាន បានធ្វើដំណើរជាមួយលោក ខៀវ សំផន ពីទីក្រុងបាងកកទៅទីក្រុងប៉េកាំង ដើម្បីទៅគាល់សម្តេច សីហនុ ដើម្បីផ្លាស់ប្តូរមតិគ្នា ក្នុងការលើកឡើងនូវសំណើដំណោះស្រាយនយោបាយរបស់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ នៅថ្ងៃទី ១៧ មីនា ១៩៨៦ នៅទីក្រុងប៉េកាំង អ្នកដឹកនាំរដ្ឋាភិបាលចម្រុះត្រីភាគី បានព្រមព្រៀងគ្នាស្នើចេញផែនការសន្តិភាព ៨ ចំណុច[212] ដែលយោងទៅតាមសេចក្តីសម្រេចរបស់មហាសន្និបាតនៃអង្គការសហប្រជាជាតិ និង តាមសេចក្តីថ្លែងការណ៍របស់សន្និសីទអន្តរជាតិស្តីពីកម្ពុជា ឆ្នាំ ១៩៨១ ។ ចំណុចដែលគួរកត់សម្គាល់នោះគឺរដ្ឋាភិបាលចម្រុះត្រីភាគីមិនទាមទារឲ្យកងទ័ពវៀតណាមដកចេញទាំងអស់ ដូចពេលមុនៗទេ ។ ម្តងនេះមេដឹកនាំត្រីភាគី សុំឲ្យរដ្ឋាភិបាលក្រុងហាណូយធ្វើការចរចាផ្ទាល់ជាមួយរដ្ឋាភិបាលត្រីភាគី ដើម្បីពិភាក្សាអំពីដំណើរការនៃការដកកងទ័ពវៀតណាមជាពីរតំណាក់កាល ។ ក្រោយពីមានការព្រមព្រៀងស្តីពីការដកកងទ័ពចេញមក នឹងមានការឈប់បាញ់គ្នា ដើម្បីឲ្យវៀតណាមដកកងទ័ពតាមការព្រមព្រៀងនោះ ។ ការដកកងទ័ព និង ការឈប់បាញ់គ្នានេះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យផ្ទាល់របស់អ្នកសង្កេតការណ៍នៃអង្គការសហប្រជាជាតិ ។ ចំណុចសំខាន់ថ្មីមួយទៀតនោះគឺ រដ្ឋាភិបាលត្រីភាគីសុខចិត្តចរចាជាមួយរដ្ឋាភិបាលក្រុងភ្នំពេញ

---

[212] Khieu Samphan, Samdech Norodom Sihanouk, Son Sann, Coalition Government of Democratic Kampuchea's Proposal for A Political Settlement to the Problem of Kampuchea, Beijing, March 17, 1986.

របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលពីមុនមកគេតែងតែប្រកែកមិនព្រមចរចាជាមួយ ។ ក៏ប៉ុន្តែការចរចានេះ ត្រូវធ្វើឡើងបន្ទាប់ពីវៀតណាមដកកងទ័ពនៅតំណាក់កាលទី១ ដើម្បីរៀបបង្កើតរដ្ឋាភិបាលចម្រុះចតុភាគីរបស់ប្រទេសកម្ពុជាដោយមានសម្ដេច សីហនុ ជាប្រធាន និង លោកតា សឺន សាន ជារដ្ឋមន្ត្រីទី១ ។ រដ្ឋាភិបាលចម្រុះចតុភាគីនេះ នឹងធ្វើការបោះឆ្នោតក្រោមការត្រួតពិនិត្យរបស់ក្រុមអ្នកសង្កេតការណ៍របស់អង្គការសហប្រជាជាតិ ។ នៅក្នុងផែនការបង្កើតរដ្ឋាភិបាលមានគ្រោងតំណែងប្រធានផង និង រដ្ឋមន្ត្រីទី១ផង (ដោយសារមានប្រធានផងតួនាទីរដ្ឋមន្ត្រីទី១ មិនអាចជានាយករដ្ឋមន្ត្រីពេញសិទ្ធិដូចធម្មតាទេ) ។ ចំណុចដែលគួរឲ្យចាប់អារម្មណ៍នោះគឺ រដ្ឋាភិបាលចតុភាគីចាំបាច់ត្រូវតែមានភាគីខ្មែរក្រហម ដែលនៅក្នុងសំណើបែបបទរបស់អាស៊ានមិនបាននិយាយឲ្យចំទេ ។ម្យ៉ាងទៀតនៅក្នុងសំណើរបស់អាស៊ាននោះ ក៏មិនបាននិយាយពីតួនាទីរបស់លោកតា សឺន សាន នៅពេលអនាគត ដែលគេគ្រាន់តែលើកថារដ្ឋាភិបាលជាតិបណ្ដោះអាសន្នស្ថិតនៅក្រោមការដឹកនាំរបស់សម្ដេច សីហនុ ។ សំណើសន្តិភាព ៨ ចំណុចដែលចេញនៅទីក្រុងប៉េកាំងនេះ មានបំណងបញ្ជាក់បន្ថែមអំពីការគាំទ្ររបស់ដៃគូនៅក្នុងរដ្ឋាភិបាលចម្រុះ ចំពោះតួនាទីដឹកនាំអនាគតរបស់លោកតា សឺន សាន ដែលកំពុងទទួលការខូចខាត ដោយសារការប្រឆាំងពីក្រុមឧត្តមសេនីយ សក់ ស៊ុតសាខន ។ ដូច្នេះសំណើផែនការសន្តិភាព ៨ ចំណុចរបស់រដ្ឋាភិបាលចម្រុះត្រីភាគីនេះបានបង្ហាញនូវឯកភាពរបស់ខ្លួនចំពោះមុខពិភពលោក ។

## រំលឹកឡើងវិញបន្តិចអំពី ចិន និង វិបត្តិផ្ទៃក្នុង រ.ជ.រ.ប.ខ.

នៅទីក្រុងប៉េកាំង មេដឹកនាំរដ្ឋាភិបាលចម្រុះទាំងបីរូបគឺ សម្ដេច សីហនុ លោកតា សឺន សាន និង លោក ខៀវ សំផន បាននាំសំណើសន្តិភាព ៨

ចំណុចនេះ ទៅជូនថ្នាក់ដឹកនាំជាន់ខ្ពស់ចិន ។ នៅក្នុងជំនួបជាមួយលោក ហ៊ូ យ៉ៅបាង (Hu Yaobang)[213] អគ្គលេខានៃគណបក្សកុម្មុយនីស្តចិន លោកអគ្គលេខាចិនរូបនេះ បានលើកសរសើរសម្តេច សីហនុ និង ដៃគូរបស់ព្រះអង្គ ដែលបានរួបរួមគ្នាសហការគ្នាយ៉ាងល្អ រហូតដល់សម្រេចចេញបាននូវសំណើសន្តិភាព ៨ ចំណុច ដែលជាសំណើប្រវត្តិសាស្ត្រអាចនាំទៅដោះស្រាយជម្លោះកម្ពុជាតាមផ្លូវនយោបាយផង និង អាចជួយឲ្យមានប្រក្រតីភាពឡើងវិញនៃស្ថានភាពនៅតំបន់អាស៊ីភាគអគ្នេយ៍នេះផង ។ ក៏ប៉ុន្តែ លោកអគ្គលេខាបានបន្ថែមថា លក្ខខណ្ឌសម្រាប់ដំណោះស្រាយនៅមិនទាន់គ្រប់គ្រាន់ទេ ព្រោះបញ្ហាកម្ពុជាជាបញ្ហាអន្តរជាតិ ។ ដល់វេនលោកតា សឺន សាន មានមតិ លោកតាមិនបានលើកយកបញ្ហាសំណើសន្តិភាព ៨ ចំណុចមកធ្វើជាប្រធានបទសំខាន់នោះទេ តែលើកយកបញ្ហាផ្ទៃក្នុងរ.ជ.រ.ប.ខ. មកលាតត្រដាងទៅវិញ ។ លោកតាថ្លែងជាអាទិថាចាប់តាំងពីខែធ្នូ ឆ្នាំមុន បន្ទាប់ពីទស្សនកិច្ចប្រកបដោយជោគជ័យនៅប្រទេសចិនជាមិត្ត លោកតាប្រធានបានជួបប្រទះនូវបញ្ហាជម្លោះផ្ទៃក្នុងៗជួររ.ជ.រ.ប.ខ. ដែលធ្វើឲ្យខាតពេលវេលា និង អស់ថាមពលជាច្រើន ។

លោក ហ៊ូ យ៉ៅបាង បានឆ្លើយតបចំពោះរឿងរ៉ាវផ្ទៃក្នុងនេះថា៖បញ្ហាផ្ទៃក្នុងជាបញ្ហាដែលពិបាកនិយាយ ឬ ដែលពិបាកធ្វើអត្ថាធិប្បាយជាទីបំផុត ។ ក៏ប៉ុន្តែ អ្វីដែលសំខាន់ ដែលប្រទេសចិនអាចលើកឡើងនៅពេលនេះគឺ៖ ទី១ -ចិនទទួលស្គាល់ឯកឧត្តម សឺន សាន ជាអ្នកស្នេហាជាតិ និង ជាអ្នកតស៊ូស្រឡាញ់ជាតិ ទី២ -ចិនសម្គាល់ ឯកឧត្តម សឺន សាន ជាមិត្តចាស់ និង ជាមិត្តល្អម្នាក់របស់ប្រទេសចិន ។ ចំណុចពីរនេះ ចិនមិនដែលផ្លាស់ប្តូរឡើយ ។ សម្តេច សីហនុ ក៏បញ្ជាក់ជូនមេដឹកនាំចិនថែមទៀតថា គ្មានបញ្ហាអ្វីធំដុំក្នុងជួររដ្ឋាភិបាលចម្រុះទេ មានតែបញ្ហា

---

[213] Notes Recueillies (Confidentielles) sur l’entretien politique entre S.E Hu Yaobang, Secrétaire Général du PCC et le Gouvernement de Coalition du Kampuchea Démocratique, Beijing, le 18 Mars 1986.

តូចតាចតែប៉ុណ្ណោះ ។ ព្រះអង្គជានាមិនឲ្យមេដឹកនាំចិនព្រួយបារម្ភអ្វីចំពោះឯកភាព និង សាមគ្គីភាពរបស់ភាគីទាំងអស់នៅក្នុងរដ្ឋាភិបាលចម្រុះខ្មែរត្រីភាគីនេះឡើយ ។

ព្រឹកស្អែកឡើង លោកតា សឺន សាន និង គណៈប្រិតភូរ.ជ.រ.ប.ខ.បានជួបជាមួយលោកអនុរដ្ឋមន្ត្រីក្រសួងការបរទេស លីវ ស៊ូគីង (Liu Shuquing) ។ នៅក្នុងជំនួបនោះ លោកតាប្រធានបានចេញតវ៉ាត្រង់ៗថា ពួកយោធាថៃកំពុងយកបញ្ហាផ្ទៃក្នុង រ.ជ.រ.ប.ខ. មកធ្វើជាលេសដើម្បីត្រួតត្រាផ្ទាល់លើកងទ័ព រ.ជ.រ.ប.ខ[214] ។ លោកតា សឺន សាន ជំរាបលោកអនុរដ្ឋមន្ត្រីចិនថាដោយសំអាងថាទម្រាំរកដំណោះស្រាយទំនាស់ផ្ទៃក្នុងបាន ក្រុមយោធាថៃបានកោះប្រជុំមេបញ្ជាការ រ.ជ.រ.ប.ខ.ចំនួន ១០ នាក់ ណែនាំអ្នកទាំង ១០ នាក់នោះឲ្យបង្កើតជាគណៈកម្មការយោធាមួយហៅថា "គណៈកម្មការមេបញ្ជាការ ១០ នាក់" (The 10 Commander-Committee" ដើម្បីដឹកនាំបញ្ជាក.ជ.រ.ប.ខក្រោមការត្រួតពិនិត្យរបស់នាយទាហានថៃម្នាក់ឈ្មោះលោកសក្តិប្រាំ វិស្នុ ឬ វិស្ណុ[215] (Colonel Vishu) ។ លោកតាប្រធាន រ.ជ.រ.ប.ខ មានការព្រួយបារម្ភខ្លាចថា ការធ្វើរបៀបនេះអាចឲ្យយោធាថៃប្រើកងទ័ពរ.ជ.រ.ប.ខ ទៅបំពេញបេសកកម្មដទៃផ្សេង មិនត្រូវតាមគោលបំណងរបស់រដ្ឋាភិបាលចម្រុះត្រីភាគី ឬ ផ្ទុយពីស្មារតីនៃសេចក្តីថ្លែងការណ៍គួឡាឡាំពួ ។ លោកតាបន្ថែមទៀតថា មិនតែប៉ុណ្ណោះយោធាថៃឈប់បើកប្រាក់ជំនួយចិនផ្តល់ដល់ភាគីរបស់លោកតាទៀតផង ។ ជាចម្លើយតបវិញ លោកអនុរដ្ឋមន្ត្រីក្រសួងការបរទេសចិន បានសុំឲ្យលោកតា សឺន សាន ប្រញាប់ដោះស្រាយទំនាស់ផ្ទៃក្នុងឲ្យបានឆាប់រហ័ស ដោយសុំឲ្យធ្វើតាមមតិណែនាំរបស់លោក

---

[214] Notes d'entretien politique entre S.E. Son Sann, Premier Ministre du CGKD et S.E. Liu Shuqin, Vice Ministre A.E. de la RPC, Beijing, le 19 Mars 1986.

[215] ខ្មែរយើងខ្លះហៅ វិស្នុ ខ្លះហៅ វិស្ណុ ។ ឈ្មោះនេះជាឈ្មោះសម្ងាត់ទេ ឈ្មោះពិតប្រាកដ គឺ ស៊ូរ៉ាយុទ្ធ ជូឡានន្ត (Surayuth Chulanond) ។ នៅឆ្នាំ ២០០៦ លោក ស៊ូរ៉ាយុទ្ធ ជូឡានន្ត បានឡើងកាន់តំណែងជានាយករដ្ឋមន្ត្រីនៃប្រទេសថៃ បន្ទាប់ពីមានរដ្ឋប្រហារយោធាទំលាក់លោក តាក់ស៊ិន ពីអំណាច ។

ឧត្តមសេនីយ ឆាវលិត ដែលបានបែងចែកការទទួលខុសត្រូវរួចស្រេចហើយគឺលោកតា សឺន សាន ក្នុងឋានៈជានាយករដ្ឋមន្ត្រីទទួលខុសត្រូវខាងការទូត និងនយោបាយ ឯលោកឧត្តមសេនីយ សក់ ស៊ុតសាខន ទទួលខុសត្រូវជាមេបញ្ជាការកងទ័ព ។ តាមពិតទៅ ទាំងលោកតា សឺន សាន ទាំងលោកឧត្តមសេនីយ សក់ ស៊ុតសាខន សុទ្ធតែអះអាងថាទទួលយកតាមមតិណែនាំរបស់លោក ឆាវលិត ទាំងអស់គ្នា ។ ក៏ប៉ុន្តែអ្វីដែលមិនទាន់ចុះសម្រុងគ្នានោះគឺការគ្រប់គ្រងថវិការបស់កងទ័ព និង ការត្រួតត្រាជំរុំជនភៀសខ្លួន ។ លោកតា សឺន សាន ក្នុងឋានៈជាប្រធានចលនាយល់ថា លោកតាត្រូវតែមានការទទួលខុសត្រូវលើការចាយវាយទាំងអស់រាប់ទាំងចំណាយយោធាផង ។ ម្យ៉ាងទៀត លោកតាប្រធាន ក៏ត្រូវការអំណាច "ត្រួតត្រា" ជំរុំភៀសខ្លួនផង ព្រោះនៅទីនោះហើយ ដែលជាប្រភពនៃការគាំទ្រនយោបាយសម្រាប់ការដឹកនាំរបស់លោកតា ។ ដោយមានការគាំទ្រពីជនភៀសខ្លួននៅតាមជំរុំនេះហើយដែលលោកតា សឺន សាន អាចមានប្រសាសន៍ថាលោកតាបានទទួលការគាំទ្រពី "ប្រជារាស្ត្រខ្មែរ" ។ មែនទែនទៅ អំណាចត្រួតត្រាជំរុំនោះមានន័យត្រឹមតែអាចទទួលការគាំទ្រខាងផ្នែកនយោបាយតែប៉ុណ្ណោះ ព្រោះថាការគ្រប់គ្រងផ្ទាល់លើជំរុំស្ថិតនៅក្នុងដៃអាជ្ញាធរថៃ និង អង្គការសហប្រជាជាតិឯនោះទេ ។ ចំណែកឯលោកឧត្តមសេនីយ សក់ ស៊ុតសាខន ក៏ត្រូវការអំណាច "ត្រួតត្រា" ជំរុំជនភៀសខ្លួនដែរ ព្រោះនៅទីនោះហើយដែល លោកឧត្តមសេនីយអាចជ្រើសរើសយុទ្ធជនឲ្យចូលបំរើកងទ័ព ។ លើសពីនោះទៅទៀត ប្រធានជំរុំនីមួយៗអាចមានលទ្ធភាព ឆ្លៀតដកហូតយកជំនួយជាម្ហូបអាហារ ឬ សម្ភារៈខ្លះដែលនៅសល់ពីការចែកចាយដល់ជនភៀសខ្លួន យកទៅបំរើសកម្មភាពនយោបាយ ឬ យោធាតាមនិន្នាការរបស់គេម្នាក់ៗ ទោះជាពួកគេស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរថៃ និង អង្គការសហប្រជាជាតិក៏ដោយ ។

នៅសម័យនោះ ប្រទេសចិនផ្តល់ជំនួយបីប្រភេទដល់រ.ជ.រ.ប.ខ. ក្រៅពីជំនួយផ្នែកការទូតដល់រដ្ឋាភិបាលចម្រុះទាំងមូល ។ ជំនួយទាំងនោះមាន៖ -ជំនួយយោធាគឺ អាវុធ គ្រាប់រំសេវ និង សម្ភារៈយោធា -ជំនួយសម្ភារៈ និង ជំនួយការទូត ។ ជំនួយយោធា ត្រូវបានប្រគល់ទៅយោធាថៃសិន រួចទើបយោធាថៃប្រគល់មកឲ្យ រ.ជ.រ.ប.ខ. តាមសេចក្តីសុំរបស់ភាគីនេះ ។ ជំនួយសម្ភារៈមានជាអាទិ៍៖ ម្ហូបកំប៉ុង ចបជីក ចបកាប់ ប្រដាប់ប្រដារការិយាល័យ និង សំលៀកបំពាក់ជាដើម ។ ជំនួយនេះ ត្រូវផ្តល់ដល់ភាគីរ.ជ.រ.ប.ខ. ដោយមានការអនុញ្ញាតពីយោធាថៃ ។ ចំណែកជំនួយការទូតគឺ ជាថវិកាសម្ងាត់ ដែលស្ថានទូតចិនបើកផ្ទាល់ជូនលោកតា សឺន សាន សម្រាប់បំពេញបេសកកម្មការទូត ។ ថវិកាសម្ងាត់នេះ ចិនហាមមិនឲ្យប្រាប់អ្នកណាក្រៅពីមន្ត្រីស្ថានទូតចិននៅបាងកកទេគឺ ចិនមិនបានឲ្យថៃដឹងពីជំនួយនេះឡើយ ។ នៅឆ្នាំ ១៩៨៥-៨៦ ជំនួយសម្ភារៈចិនដល់រ.ជ.រ.ប.ខ.មានតម្លៃមួយលានយន់ ។ នៅក្នុងជំនួបជាមួយលោកអនុរដ្ឋមន្ត្រី លីវ ស៊ូគីង លោកតា សឺន សាន ស្នើសុំចិនយកជំនួយសម្ភារៈមួយលានយន់នោះមកជាថវិកា ដើម្បីជួយផ្គត់ផ្គង់ទ័ពពិសេសថ្មីមួយ ដែលលោកតាមានបំណងចង់បង្កើត និង ចង់ដាក់ឲ្យនៅក្រោមបញ្ជាលោកឧត្តមសេនីយ ថាច់ រ៉េង ។ ក៏ប៉ុន្តែភាគីចិនមិនយល់ព្រមតាមសំណើនេះ ទំនងជាចិនមិនចង់មានបញ្ហាវែងឆ្ងាយជាមួយក្រុមយោធាថៃ ដែលបានសម្រេចមិនឲ្យលោកតា សឺន សាន រវីរវល់ក្នុងកិច្ចការយោធា ។ ដូច្នេះគំរោងបង្កើតកងទ័ពពិសេសសំរាប់លោក ថាច់ រ៉េង ក៏ត្រូវធ្លាក់ទឹកមិនបានសម្រេចតាមបំណងលោកតាឡើយ ។ ចំណែកឯថវិកាសម្ងាត់សំរាប់ការងារទូត មានចំនួនជាសាច់ប្រាក់សុទ្ធ ២០០ ០០០ ដុល្លារក្នុងមួយឆ្នាំ ។ បើលោកតាត្រូវការពេលណា លោកតាអាចចាត់មន្ត្រីឲ្យទៅបើកផ្ទាល់ពីស្ថានទូតចិននៅបាងកក បានគ្រប់ពេលវេលា ។

# ជំនួយជាចំហររបស់អាមេរិកលើកដំបូង

ទំនាស់ផ្ទៃក្នុងរវាងលោកតា សឺន សាន និង ក្រុមឧត្តមសេនីយ សក់ ស៊ុតសាខន កើតឡើងនៅចំពេល ដែលសហរដ្ឋអាមេរិកកំពុងរៀបចំជួយផ្តល់ជំនួយជាចំហរលើកដំបូងដល់ចលនាមិនមែនកុម្មុយនីស្ត ចំនួនប្រហែលប្រាំលានដុល្លារ ស.រ.អា ក្នុងមួយឆ្នាំ ។ ជំនួយនោះ ជាជំនួយយោធាដែលមិនសម្លាប់មនុស្ស (Non-Lethal) បានន័យថាជំនួយយោធាដែលគ្មានអាវុធយុទ្ធភ័ណ្ឌ ឬ គ្រាប់រំសេវសម្រាប់សម្លាប់មនុស្ស ។ តាមពិតទៅ ទោះជាស.រ.អា នៅមិនទាន់អស់សុបិន្តអាក្រក់អំពីបរាជ័យរបស់ខ្លួននៅវៀតណាមនាទសវត្សរ៍ឆ្នាំ ១៩៧០ យ៉ាងណាក៏ដោយ ក៏ ស.រ.អា លបចេញយុទ្ធសាស្ត្រមួយ ដើម្បីជួយជំរុញចលនាមិនមែនកុម្មុយនីស្តឲ្យមានមុខជាចលនាគួរឲ្យទុកចិត្តបាន ដែលអាចឲ្យប្រជារាស្ត្រខ្មែរជ្រើសយកបានជាជំនួសក្រុមកុម្មុយនីស្ត ។ គំនិតសំខាន់គឺ ការបង្រួបបង្រួមចលនារបស់សម្តេចសីហនុ និង ចលនារបស់លោកតា សឺន សាន ឲ្យចូលគ្នាជាកងទ័ពអ្នកជាតិនិយមតែមួយ ក្រោមបញ្ជាការរួមតែមួយ ដែលមិនចំណុះខ្មែរក្រហម ។ ក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន ដែលហ៊ានចេញមុខប្រឆាំងលោកតា សឺន សាន ប្រហែលជាអាចយល់ជាមុននូវទំនោរនយោបាយរបស់ស.រ.អានេះ ។

បញ្ជាការរួមនៃកងទ័ពមិនមែនកុម្មុយនីស្តទាំងពីរ អាចជានិមិត្តរូបនៃការកកើតនូវកម្លាំងមួយថ្មី ដែលគ្មានទំនាក់ទំនងអ្វីជាមួយខ្មែរក្រហមឡើយ ។ អាជ្ញាធរយោធាថៃស្ថិតនៅពីក្រោយយ៉ាងរឹងមាំនៃបញ្ជាការរួមនេះ ។ ពួកឧត្តមសេនីយថៃទាំងនោះ គាំទ្រលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអគ្គមេបញ្ជាការនៃកងកម្លាំងប្រចាប់បញ្ចូលគ្នានេះ ដែលជួយផ្តល់ទម្ងន់ដល់លោកឧត្តមសេនីយខ្មែររូបនេះ ក្នុងការដណ្តើមអំណាចដឹកនាំពីលោកតា សឺន សាន ។ នៅពេលនោះ លោក

ឧត្តមសេនីយ សក់ ស៊ុតសាខន អះអាងថាពួកគាត់ជាអ្នកជំរុញឲ្យមានទំនាក់ទំនងជិតស្និទ្ធគ្នារវាងរ.ជ.រ.ប.ខ. និង ហ៊្វុន ស៊ិន ប៉ិច ផ្ទុយពីលោកតា សឺន សាន ដែលត្រូវបានចោទប្រកាន់ថា ជាអ្នកបង្កឧបសគ្គដល់កិច្ចសហប្រតិបត្តិការគ្នារវាងចលនាទាំងពីរនេះ ។ ក៏ប៉ុន្តែប្រសិនបើគេទុកថ្វាយសម្តេច សីហនុ ធ្វើការជ្រើសរើស តើលោក តា សឺន សាន ឬ លោកឧត្តមសេនីយ សក់ ស៊ុតសាខន ដើម្បីព្រះអង្គសហការជាមួយនោះ សម្តេចប្រាកដជាជ្រើសរើសយកលោកតា សឺន សាន មិនខានឡើយ ។ តាមគេហទំព័ររបស់ព្រះអង្គ ដែលគេប្រទះឃើញជាច្រើនឆ្នាំក្រោយមក សម្តេច សីហនុ[216] ទ្រង់មានព្រះសំណេរផ្ទាល់ព្រះហស្តព្រះអង្គស្តីពីទំនាស់ផ្ទៃក្នុងរ.ជ.រ.ប.ខ.នាសម័យនោះ មានន័យជាអាទិថាទំនាស់ផ្ទៃក្នុងរវាងក្រុម សឺន សាន ជាមួយក្រុម ដៀន ដែល-ហ្គាហ្វា ពាងម៉េត - សក់ ស៊ុតសាខន តាមការពិតមិនមែនកើតឡើងដោយសារមានអ្នកគាំទ្រ ឬ មានអ្នកប្រឆាំងចំពោះកិច្ចសហការជាមួយភាគី សីហនុ នោះទេ ។ ក្រុមហ្គាហ្វា ពាងម៉េត តាំងខ្លួនជាអ្នកចង់ឲ្យមានសហការជិតស្និទ្ធពិតប្រាកដរវាងរ.ជ.រ.ប.ខ. និង ហ៊្វុន ស៊ិន ប៉ិច ចំណែកឯក្រុម សឺន សាន ជាអ្នកប្រឆាំង ។ តាមពិត ក្រុម ហ្គាហ្វា ពាងម៉េត ដៀន ដែល ហ៊ីង គន្ធុន ជាក្រុមប្រឆាំង សីហនុ ខ្លាំងជាងក្រុម សឺន សាន ទៅទៀត ។ ក៏ប៉ុន្តែគេយកលេសនេះ ព្រោះវាស្រួល និង ផ្តល់ផលចំណេញដល់ក្រុមហ្គាហ្វា ព្រោះអ្នកគាំទ្ររបស់ពួកគេ ទាំងស.រ.អា ទាំងអាស៊ាន ជាពិសេស គេចង់ឲ្យមានកិច្ចសហការល្អរវាងភាគីមិនមែនកុម្មុយនីស្តទាំងពីរ ។

[216] Norodom Shanouk, Ce “rift” entre le clan de Son Sann et celui de Dien Del-Gaffar Peangmeth-Sak Sutsakhan...., a handwritten note (undated) www.norodomsihanouk.info

## ខ្ញុំប្រាប់មន្ត្រីអាមេរិកថា "បើមិនជួយ ក៏យើងនៅតែតស៊ូ"

តាមព្រះសំណេររបស់ព្រះអង្គនេះ សម្តេច សីហនុ ក៏ទ្រង់យល់ថាមេក្លោងមួយនៃការបះបោរប្រឆាំងលោកតា សឺន សាន គឺ លោក ហ្គាហ្វា ពាងម៉េត ដូចខ្ញុំធ្លាប់សសេរនៅវគ្គមុនៗរួចហើយ ។ សម្តេច សីហនុ ក៏ទ្រង់យល់ដែរថាក្រុមប្រឆាំងទាំងនោះ សុទ្ធតែជាមនុស្សនៃរបបសាធារណរដ្ឋដែលបានទម្លាក់ព្រះអង្គពីអំណាចកាលពីឆ្នាំ ១៩៧០ ។ ចំណែកឯក្រុមយោធាថៃ ក៏មានហេតុផលរបស់គេដែរក្នុងការគាំទ្រក្រុមលោកឧត្តមសេនីយ សក់ ស៊ុតសាខន ព្រោះថារាល់ជំនួយដែលត្រូវផ្តល់ដល់កងកម្លាំងថ្មីនេះ នឹងត្រូវផ្តល់តាមរយៈកងទ័ពថៃទាំងអស់ ។ ជំនួយគ្រប់បែបយ៉ាង ដែលផ្តល់ដល់កម្លាំងប្រដាប់អាវុធខ្មែរ ទាំងថ្មីទាំងចាស់ ត្រូវតែឆ្លងកាត់តាមប្រទេសថៃជាដាច់ខាត ។ គួរបញ្ជាក់ទៀតដែរថា ប្រសិនបើលោកតា សឺន សាន មានទំនាក់ទំនងល្អជាមួយសហរដ្ឋអាមេរិក នៅក្នុងកំរិតអ្នកសម្រេចគោលនយោបាយឯទីក្រុងវ៉ាស៊ិនតោន ក្រុមលោក សក់ ស៊ុតសាខន រក្សាបាននូវទំនាក់ទំនងល្អជាមួយស្ថានទូតអាមេរិកនៅបាងកក ។ នេះក៏ដោយសារការងារជាប្រចាំរបស់ហ្គាហ្វាដែរ ។ ចំណែករូបខ្ញុំ នាសម័យនោះ ខ្ញុំក៏មានទំនាក់ទំនងខ្លះៗដែរជាមួយស្ថានទូតអាមេរិកនោះ តែទំនាក់ទំនងរបស់ខ្ញុំបានត្រឹមកំរិតទាបគឺ ត្រឹមថ្នាក់លេខាទី ២ ឬ ទី ៣ ប៉ុណ្ណោះ ។ ក្នុងចំណោមក្រុមលេខានោះ មានមន្ត្រីម្នាក់ឈ្មោះម៉ាក់កកមិច (McCormick) ។ ជាញឹកញាប់ ខ្ញុំតែងសុំឲ្យលោក ម៉ាក់កកមិច ជួយបញ្ជូនសំណើសុំជំនួយស.រ.អា ទៅមន្ត្រីថ្នាក់លើរបស់គាត់ ។ ថ្ងៃមួយដោយធុញទ្រាន់ ចំពោះការមិនអើពើរបស់ស្ថានទូតអាមេរិកក្នុងការឆ្លើយតបមកពួកយើង ខ្ញុំក៏បានប្រាប់លោក ម៉ាក់កកមិច ថា យើងខ្ញុំត្រូវការជំនួយរបស់អស់លោក ក៏ប៉ុន្តែមានជំនួយ ឬ ឥតជំនួយ យើងខ្ញុំក៏ត្រូវតែបន្តការតស៊ូរំដោះជាតិ ព្រោះនោះជា

កាតព្វកិច្ចរបស់ពួកយើងជាខ្មែរ ។ ច្រើនខែក្រោយមក ខ្ញុំបានទទួលដំណឹងតាមមិត្តភក្តិនៅទីក្រុងវ៉ាស៊ិនតោនថា អ្វីដែលខ្ញុំនិយាយប្រាប់លោក ម៉ាក់កកមិច នៅបាងកកនោះ បានឮទៅដល់ក្រសួងការបរ ទេសអាមេរិក ។

# លោកតាបានស៊ីញ៉េលើក្រដាស តែលុយបានទៅអ្នកផ្សេង

ដោយអន្ទះអន្ទែងចង់ដឹងថា តើជំនួយស.រ.អា ដែលនឹងត្រូវផ្តល់ដល់ក្រុមខ្មែរមិនមែនកុម្មុយនីស្តនោះនឹងត្រូវផ្តល់តាមរយៈក្រុមណា? រ.ជ.រ.ប.ខ. (ខាងលោកតា សឺន សាន) បានផ្ញើអនុស្សារណៈមួយច្បាប់ទៅជូនលោក ហ្គាស្តុន សែគួរ (Gaston Sigur)[217] ឧបការីរដ្ឋមន្ត្រី (ឋានៈស្មើអនុរដ្ឋមន្ត្រី) ក្រសួងការបរទេសស.រ.អា ដើម្បីជំរាបថា រ.ជ.រ.ប.ខ. បានត្រៀមខ្លួននឹងបង្ហាញជូនមន្ត្រីអាមេរិកអំពីបែបបទនៃការប្រើប្រាស់ជំនួយនេះ នៅពេលណាដែលបានទទួលដំណឹងជាផ្លូវការអំពីការផ្តល់ជំនួយអាមេរិក ។ នៅក្នុងអនុស្សារណៈនោះ ពួកយើងបានគូសបញ្ជាក់អំពីមូលហេតុដែលអាមេរិកត្រូវជួយចលនាមិនមែនកុម្មុយនីស្តគឺ៖ ១. ដើម្បីឆ្លើយតបទៅនឹងប្រតិកម្មជាអវិជ្ជមានរបស់វៀតណាម ចំពោះសំណើសន្តិភាព ៨ ចំណុចរបស់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ២. ដើម្បីជារង្វាន់លើកទឹកចិត្តដល់រដ្ឋាភិបាលចម្រុះ ចំពោះការរីកចំរើនខាងយោធានៅលើសមរភូមិ និង នៅលើឆាកអន្តរជាតិ ។ ក៏ប៉ុន្តែតាមពិតទៅ ប្រសិនបើមានការជ្រៀតចូលជ្រៅទៅក្នុងប្រទេសនៃកងកម្លាំងប្រដាប់អាវុធមែន កងកម្លាំងប្រដាប់អាវុធនោះភាគច្រើនជាកម្លាំងខ្មែរក្រហម ដែលខ្លាំងជាងគេ នៅពេលដែលកងទ័ពមិនមែនកុម្មុយនីស្តមិន

---

[217] Khmer People's National Liberation Front, Memorandum presented to His Excellency Mr. Gaston Sigur, US Assistant Secretary of State for East Asia and Pacific Affairs, March 26, 1986.

អាចចេញឆ្ងាយពីទល់ដែនទេនោះ ។ នៅក្នុងអនុស្សារណៈនោះដែរ រ.ជ.រ.ប.ខ.បានសង្កត់ធ្ងន់ថា ពួកយើងត្រូវតែប្រើយុទ្ធសាស្ត្រសង្គ្រាមទ័ពព្រៃ ។ ជាសេចក្តីសន្និដ្ឋាន ពួកយើងអះអាងថាប្រសិនបើកងកម្លាំងមិនមែនកុម្មុយនីស្តនៅតែខ្សោយ ខ្មែរក្រហមនឹងទទួលជ័យជំនះនៅក្នុងសង្គ្រាម ហើយក្រុមមិនមែនកុម្មុយនីស្តនឹងត្រូវលោយបាត់ស្រមោលពីឆាកនយោបាយនៅកម្ពុជាមិនខានឡើយ ។ ទាំងនេះជាហេតុផលដែលរ.ជ.រ.ប.ខ. បង្ហាញដល់ក្រសួងការបរទេសអាមេរិក ដើម្បីទាក់ទាញឲ្យស.រ.អាផ្តល់ជំនួយយោធាដល់កងកម្លាំងនៃចលនាតស៊ូមិនមែនកុម្មុយនីស្ត ។

នៅទីបំផុត អាមេរិកក៏ផ្តល់ជំនួយយោធា ដែលមិនមែនសម្រាប់សម្លាប់មនុស្ស (Non-Lethal) នេះមែន ។ នៅពេលនោះ អ្នកតំណាងលោកតា សឺន សាន ត្រូវអាជ្ញាធរថៃហៅឲ្យទៅចុះហត្ថលេខាលើឯកសារទទួលទាំងឡាយ ។ ក៏ប៉ុន្តែ ពួកយើងបានត្រឹមតែចុះហត្ថលេខាទទួលលើក្រដាសតែប៉ុណ្ណោះ ឯថវិកាជាសាច់ប្រាក់ត្រូវធ្លាក់ទៅក្រុមផ្សេងទៅវិញ ។ មែនទែន ការបើកយកប្រាក់ត្រូវសម្រេចដោយក្រុមការងារ តាមមតិណែនាំរបស់លោកឧត្តមសេនីយ ឆាវលិត ។ ដូច្នេះ អ្នកទទួលជំនួយពិតប្រាកដគឺ មួយផ្នែកធំបានទៅក្រុមយោធារបស់រ.ជ.រ.ប.ខ. ដែលមានលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាមេដឹកនាំ និង មួយផ្នែកទៀតបានទៅខាង ហ៊្វុន ស៊ិន ប៉ិច តំណាងដោយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលជាព្រះរាជបុត្រ និង ជាព្រះរាជតំណាងសម្តេច សីហនុ ។ បើនិយាយឲ្យចំទៅ ជំនួយអាមេរិក ដែលគេហៅថាជំនួយសូឡានោះមិនដែលបានធ្លាក់ ដល់ដៃក្រុមលោកតា សឺន សាន សោះឡើយ ។ នៅឆ្នាំ ១៩៨៨ លោកតា សឺន សាន[218] បានផ្ញើលិខិតមួយច្បាប់ជូនលោក សូឡា ដើម្បីតវ៉ាថាមិនដែលបានឃើញស្រមោលជំនួយនោះម្តងណាឡើយ ។ លោកតាសរសេរថាការប្រើប្រាស់ជំនួយយោធាគ្មាន

[218] Son Sann, [Letter] to the Honourable Stephen J. Solarz, Chairman Sub-Committee on Asia Pacific Affairs, Congress of the United States, June 22, 1988.

គណនេយ្យភាពសម្រាប់ខ្ញុំ និង មិនបានឲ្យខ្ញុំដឹងឮអ្វីទាំងអស់ ។ រាល់ៗឆ្នាំ គេឲ្យខ្ញុំចុះហត្ថលេខាទទួលលើឯកសារ ដើម្បីគេយកទៅបើកប្រាក់ ។ តាមពិតទៅដោយសារតែយើងទទួលថវិកាផ្ទាល់ពីក្រុមយោធាថៃ យើងក៏មិនអាចដឹងឲ្យច្បាស់លាស់ថា ថវិកាប៉ុន្មានជាថវិការបស់ ស.រ.អា តើអាមេរិកឲ្យមកក្រុមយើងប៉ុន្មាន? ឲ្យទៅខាងក្រុមលោក សក់ ស៊ុតសាខន ប៉ុន្មាន និង តើក្រុមឧត្តមសេនីយថៃកាត់យកប៉ុន្មាន?នៅក្នុងលិខិតចុះថ្ងៃទី ២២ មិថុនា ១៩៨៨ នោះ លោកតា សឺន សាន ក៏តវ៉ាដែរថា នៅពេលដែលទាំងប្រធាន ទាំងបុគ្គលិករ.ជ.រ.ប.ខ. ធ្វើការអត់យកប្រាក់ខែ និង នៅពេលដែលទាហានធម្មតា ទទួលការឧបត្ថម្ភតិចជាង ៥ ដុល្លារក្នុងមួយថ្ងៃ នាយទាហានជាន់ខ្ពស់រាប់ទាំងការិយាល័យអគ្គមេបញ្ជាការ ក.ជ.រ.ប.ខ. ក្រោមការដឹកនាំរបស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន ផង នាំគ្នាបែងចែកប្រាក់ឧបត្ថម្ភប្រចាំខែក្នុងម្នាក់ៗពី ៨០០ ទៅ ៦០០០ ដុល្លារ ។

តាមការយល់ដឹងរបស់ពួកយើងៗទទួលពីទាហានថៃក្នុងមួយខែៗ នូវប្រាក់សុទ្ធចំនួនមួយលានបាត ឬ បួនម៉ឺនដុល្លារ ។ បន្ទាប់មក គេកាត់នៅត្រឹមប្រាំបីសែនបាត ឬ បីម៉ឺនពីរពាន់ដុល្លារនៅឆ្នាំ ១៩៨៥ ។ នៅឆ្នាំ ១៩៨៨ គេបន្ថយមកប្រាំសែនបាត ឬ ពីរម៉ឺនប្រាំពាន់ដុល្លារ រួចនៅទីបញ្ចប់ គេកាត់មកត្រឹមបួនសែនបួនម៉ឺនប្រាំបួនពាន់បាត ឬ មួយម៉ឺនប្រាំពីរពាន់ប្រាំបួនរយហុកសិបដុល្លារ ។ ពួកថៃនិយាយថាប្រាក់ដែលគេកាត់ពីក្រុម សឺន សាន គេយកទៅប្រគល់ឲ្យក្រុម សក់ ស៊ុតសាខន ។ អ្នកវិភាគព័ត៌មានបានប៉ាន់ប្រមាណថាជំនួយរបស់ ស.រ.អា សម្រាប់ចលនាមិនមែនកុម្មុយនីស្តមានប្រហែលពី ១២ ទៅ ១៨ លានដុល្លារក្នុងមួយឆ្នាំ ។

តាំងពីច្រើនឆ្នាំមកហើយ ដែលទីក្រុងវ៉ាស៊ិនតោនខិតខំរិះរកវិធីផ្តល់ជំនួយដល់ក្រុមអ្នកតស៊ូខ្មែរមិនមែនកុម្មុយនីស្ត ព្រោះសមាជិកសភា និង សមាជិកព្រឹទ្ធសភាអាមេរិកមួយចំនួន ជាពិសេសលោក សូឡា យល់ឃើញថាជំនួយនេះ អាច

ជួយជាការគាបសង្កត់បន្ថែមទៀតដល់វៀតណាម ឲ្យដកកងទ័ពចេញពីកម្ពុជា ។ ក៏ប៉ុន្តែ អ្នកនយោបាយអាមេរិកទាំងនោះ ក៏មិនចង់ឃើញការដកកងទ័ពវៀតណាមចេញទៅដោយត្រូវបានជំនួសវិញ ដោយការវិលត្រឡប់មកកាន់អំណាចវិញនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត ទេ ។ សមាជិកនៃព្រឹទ្ធសភាអាមេរិកមួយចំនួនយល់ថាការទុកឲ្យរដ្ឋាភិបាលក្រុងភ្នំពេញ ហេង សំរិន-ហ៊ុន សែន កាន់អំណាចនៅភ្នំពេញ គ្រាន់បើជាងការវិលត្រឡប់មកកាន់អំណាចរបស់បនប្រល័យពូជសាសន៍ ប៉ុល ពត ។ ដូច្នេះចាប់តាំងពីឆ្នាំ ១៩៨៦ មក ក៏កាន់តែមានអ្នកនយោបាយអាមេរិកច្រើនឡើងៗ ស្នើឲ្យរដ្ឋាភិបាលអាមេរិកចាប់ផ្ដើមគិតគូរធ្វើឲ្យមានភាពប្រសើរឡើងនូវទំនាក់ទំនងជាមួយប្រទេសវៀតណាម ។ និន្នាការរបស់អាមេរិកបែបនេះធ្វើឲ្យក្រុមខ្មែរមិនមែនកុម្មុយនីស្ត មានការបារម្ភកាន់តែខ្លាំងចំពោះការប្រែប្រួលគោលជំហរអាមេរិកក្នុងទំនាក់ទំនងជាមួយវៀតណាម ។

## អាមេរិកចង់ឲ្យមានទំនាក់ទំនងជាមួយវៀតណាម

នៅឆ្នាំ ១៩៨៧ មានការប៉ុនប៉ងធ្វើវិសោធនកម្មច្បាប់ស្ដីពីទំនាក់ទំនងអាមេរិក-វៀតណាម ស្នើឡើងដោយអ្នកតំណាងរាស្ត្រឈ្មោះ ពីទែរ កូសម៉ាយែរ (Peter Kostmayer) ដែលគេហៅថាវិសោធនកម្មកូសម៉ាយែរ ។ ជាទូទៅ អ្នកនយោបាយក្រុងវ៉ាស៊ិនតោនខ្លះ ចាប់ផ្ដើមគិតគូរកែលំអទំនាក់ទំនងសហរដ្ឋអាមេរិក-វៀតណាម ជាពិសេសគំនិតចេញពីមជ្ឈដ្ឋានសភាតំណាងរាស្ត្រ និង ព្រឹទ្ធសភា ក្នុងការបើកការិយាល័យបច្ចេកទេស និង ការផ្លាស់ប្ដូរទំនាក់ទំនងទ្វេភាគី អាមេរិក-វៀតណាម ។ គំនិតបែបនេះ ធ្វើឲ្យពួកយើងនៅក្នុងជួររ.ជ.រ.ប.ខ. មានការបារម្ភខ្លាចអាមេរិកផ្លាស់ប្ដូរគោលនយោបាយរបស់ខ្លួនចំពោះបញ្ហាកម្ពុជា ព្រោះថាសហរដ្ឋអាមេរិកធ្លាប់អះអាងថាដរាបណាវៀតណាមមិនដកកងទ័ពចេញពីកម្ពុជាទេ អាមេរិកមិនកែសំរួល

ឲ្យមានប្រក្រតីភាពឡើងវិញ ក្នុងទំនាក់ទំនងជាមួយវៀតណាមឡើយ ។ នៅថ្ងៃទី ១ ឧសភា ១៩៨៧ លោកតា សឺន សាន ផ្ញើលិខិតពីរច្បាប់ មួយច្បាប់ទៅជូនលោកប្រធានាធិបតី រ៉ូណាល់ រីហ្គាន (Ronald Reagan)[219] និង មួយច្បាប់ទៀតទៅជូនលោក ស្ទេហ្វាន់ សូឡា[220] ដើម្បីសំដែងនូវការព្រួយបារម្ភរបស់ក្រុមយើង ។ លោកតា សឺន សាន សរសេរថា សញ្ញាតូចតាចណាមួយ ចំពោះវៀតណាមអំពីបំណងកែលំអទំនាក់ទំនងជាមួយសហរដ្ឋអាមេរិក-វៀតណាម អាចចាត់ទុកជាជំហានដ៏សំខាន់ ព្រោះវៀតណាមអាចយល់ថា ក្រុងវ៉ាស៊ិនតោនមិនរឹងត្អឹងពេកទេគឺមិនទាមទារឲ្យវៀតណាមដកទ័ពចេញពីកម្ពុជាទៀតឡើយ ។ លោកតា សឺន សាន បានស្នើសុំឲ្យលោកប្រធានាធិបតីអាមេរិក រ៉ូណាល់ រីហ្គាន និង លោកតំណាងរាស្ត្រ សូឡា ប្រឆាំងនឹងគំនិតកែលំអទំនាក់ទំនងជាមួយវៀតណាម ក្នុងពេលដែលវៀតណាម កំពុងតែដាក់កងទ័ពឲ្យកាន់កាប់ទឹកដីកម្ពុជា ។

ចំពោះការព្រួយបារម្ភនេះលោក ហ្វ្រែង កាលលូស៊ី (Frank Carlucci) ទីប្រឹក្សាសន្តិសុខនៅសេតវិមាន[221] បានឆ្លើយក្នុងនាមលោកប្រធានាធិបតី រ៉ូណាល់ រីហ្គាន់ មានន័យជាអាទិថា ស.រ.អានៅតែចាប់អារម្មណ៍ចំពោះសោកនាដកម្មនៅកម្ពុជា និង ថាសហរដ្ឋអាមេរិកនឹងធ្វើប្រក្រតីភាពនៃទំនាក់ទំនងជាមួយវៀតណាម តែក្នុងបរិបទនៃដំណោះស្រាយមួយនៃបញ្ហាកម្ពុជា ដែលគេអាចទទួលបាន និង ដែលក្នុងនោះរួមមានទាំងការដកកងទ័ពវៀតណាមផង ។ លោក កាលលូស៊ី ជានាចំពោះ រ.ជ.រ.ប.ខ. ថា ស.រ.អា មិនផ្លាស់ប្តូរគោលជំហរនយោបាយដ៏សំខាន់នេះទេទាក់ទងនិងបញ្ហាកម្ពុជា ។ លោក កាលូស៊ី បានបន្ថែមទៀតថារដ្ឋាភិបាលលោកប្រធានាធិបតី រីហ្គាន់ នឹងប្រឆាំងការបញ្ជូនសញ្ញាណាមួយដល់ប្រទេសវៀតណាម

---

[219] Son Sann, [Letter] to His Excellency President Ronald Reagan, The White House, May 1, 1987.

[220] Son Sann, [Letter] to The Honourable Stephen J. Solarz, May 1, 1987.

[221] Frank C. Carlluci, [Letter] to Mr. Son Sann, President, Khmer People's National Liberation Front, June 15, 1987.

ដែលអាចនាំឲ្យមានការយល់ច្រឡំថាស.រ.អា លែងទាមទារឲ្យមានការដកកងទ័ពវៀតណាមពីកម្ពុជាទៀតទេ ។ ចំណែកឯលោកតំណាងរាស្ត្រ សូឡា ក៏បានឆ្លើយតបថាលោក ក៏មិនផ្លាស់ប្តូរជំហារនយោបាយរបស់លោកដែរទេ[222] ។ លោកនៅតែមានជំនឿថា ការដកកងទ័ពវៀតណាមពីកម្ពុជា នៅតែជាលក្ខខណ្ឌមុនដំបូងបង្អស់ (pre-condition) ក្នុងការធ្វើឲ្យមានប្រក្រតីភាពឡើងវិញនៅក្នុងទំនាក់ទំនងរវាងទីក្រុងវ៉ាស៊ិនតោន និង ក្រុងហាណូយ ។ លោក សូឡា ធានាថានឹងខឹតខំបន្តឲ្យស.រ.អា ផ្តល់ជំនួយដល់ចលនាមិនមែនកុម្មុយនីស្តតទៅទៀត ។ ក៏ប៉ុន្តែ លោក សូឡា ក៏សារភាពថា លោកមិនបិទទ្វារជិតទាំងអស់ក្នុងទំនាក់ទំនងជាមួយប្រទេសវៀតណាមនោះទេ ព្រោះថាស្ទើរតែគ្រប់ប្រទេសទាំងអស់នៃសមាគមអាស៊ានសុទ្ធតែមានស្ថានទូតប្រចាំនៅទីក្រុងហាណូយ ។ លោក សូឡា គាំទ្រទំនាក់ទំនងជាមួយវៀតណាមឲ្យមានត្រឹមកំរិត "ប្រជាជន" និង "ប្រជាជន" (People to People) ដូចជាការផ្លាស់ប្តូរទស្សនកិច្ចផ្នែកវប្បធម៌ ឬ ផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រទៅវិញទៅមកដែលលោក សូឡា ចាត់ទុកថាអាចជាច្រកទ្វារសម្រាប់និយាយគ្នា (a channel of communication) ។ តាមរយៈឥរិយាបថនេះ គេអាចមើលឃើញថា ស.រ.អា ក៏កំពុងគិតគូរដល់ដំណើរការប្រក្រតីភាពនៃទំនាក់ទំនងជាមួយប្រទេសវៀតណាម និង ដល់ការទប់ស្កាត់របបខ្មែរក្រហម មិនឲ្យវិលមកកាន់អំណាចវិញផងដែរ ។

[222] Stephen J. Solarz, [Letter] to Hon. Son Sann, President, Khmer People's National Liberation, Washington DC, June 3, 1987.

# នៅឡាហាវ៉ាន ហ៊ុន សែន - គាត ឈន់ លបទាក់ទងគ្នា

គួររំលឹកដែរថា បញ្ហាកម្ពុជាក៏មានផលប៉ះពាល់ដល់សមាជិកភាពរបស់ប្រទេសនេះនៅក្នុងចលនាមិនចូលបក្សសម្ព័ន្ធដែរ ។ ចលនាមិនចូលបក្សសម្ព័ន្ធបានត្រូវបង្កើតឡើងនៅដើមទសវត្សរ៍ឆ្នាំ ១៩៦០ ដែលនៅពេលនោះមានស្ថាបនិកសំខាន់ៗដូចជាលោកសេនាប្រមុខ ទីតូ នៃប្រទេសយូហ្គោស្លាវី លោកប្រធានាធិបតី ស៊ូកាណូ នៃប្រទេសឥណ្ឌូណេស៊ី លោកប្រធានាធិបតី ណាស់ស៊ែរ នៃប្រទេសអេហ្ស៊ីប លោកនាយករដ្ឋមន្ត្រី នេហរុ នៃប្រទេសឥណ្ឌា និង លោកប្រធានាធិបតី ណាក្រូម៉ាស នៃប្រទេសហ្គាណា ។ តាមពិតទៅ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ នោះប្រទេសកម្ពុជាយើងក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្តេច សីហនុ ជាព្រះប្រមុខរដ្ឋក៏បានដើរតួនាទីដ៏សកម្មនៅក្នុងចលនានោះរហូតដល់ឆ្នាំ ១៩៧០ គឺរហូតដល់ពេលប្រទេសយើងធ្លាក់ចូលក្នុងភ្នក់ភ្លើងសង្គ្រាម ។

ចលនាមិនចូលបក្សសម្ព័ន្ធ ប្រមូលផ្តុំប្រទេសមួយចំនួន ដែលសំដែងគោលជំហរនយោបាយមិនចូល ទាំងខាងប្លុកកុម្មុយនីស្តក្រោមការដឹកនាំរបស់សហភាពសូវៀត និង ទាំងខាងប្លុកលោកសេរីដែលមានសហរដ្ឋអាមេរិកជាមេក្លោង ។ គួរកត់សំគាល់ដែរថា ប្រទេសកុម្មុយនីស្តមួយចំនួនដូចជា ចិន វៀតណាម យូហ្គោស្លាវី និង គុយបាជាដើម ក៏ជាសមាជិកសំខាន់នៃចលនានេះដែរ[223] ។ នៅឆ្នាំ ១៩៧៩ ប្រទេសកម្ពុជាបានបញ្ជូនគណៈប្រតិភូពីរទៅចូលរួមសិន្និសីទកំពូលលើកទី ៦ នៃចលនាមិនចូលបក្សសម្ព័ន្ធ នៅទីក្រុងឡាហាវ៉ាននៃប្រទេសគុយបាគឺគណៈប្រតិភូមួយដឹកនាំដោយលោកប្រធាន ហេង សំរិន នៃរដ្ឋាភិបាលក្រុងភ្នំពេញ ដែលមាន

[223] គោលបំណងនៃប្រទេសសមាជិកមួយចំនួនធំនៃចលនាមិនចូលបក្សសម្ព័ន្ធគឺ មិនចូលរួមមិនកាន់ជើង ឬ គាំទ្រភាគីណាមួយក្នុងការប្រណាំងប្រជែងខាងសព្វាវុធរវាង ស.រ.អា និង សហភាពសូវៀត ។

លោករដ្ឋមន្ត្រីក្រសួងការបរទេស ហ៊ុន សែន អមដំណើរផង និង គណៈប្រតិភូមួយទៀតជាគណៈប្រតិភូខ្មែរក្រហមដឹកនាំដោយលោក ខៀវ សំផន ដោយមានលោក គាត ឈន់ ជាសមាជិកគណៈប្រតិភូមួយរូបដែរ ។ គណៈប្រតិភូទាំងពីរមិនត្រូវបានអនុញ្ញាតឲ្យចូលរួមប្រជុំទេ ដោយហេតុថាអង្គសន្និសីទ បានសម្រេចទុកអាសនៈកម្ពុជាឲ្យនៅទំនេររហូតដល់មានដំណោះស្រាយជាស្ថាពរលើជម្លោះកម្ពុជា ។ តែទោះជាមិនបានចូលប្រជុំយ៉ាងណាក៏ដោយ ក៏ពេលនោះជាឱកាសឲ្យលោករដ្ឋមន្ត្រីក្រសួងការបរទេស ហ៊ុន សែន ឆ្លៀតទាក់ទងជាសម្ងាត់ជាមួយលោក គាត ឈន់ ផងដែរ[224] ។ ប្រទេសកម្ពុជាយើងបានវិលទៅអង្គុយលើអាសនៈ ក្នុងចលនាមិនចូលបក្សសម្ព័ន្ធវិញ បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នាឆ្នាំ ១៩៩១[225] ។ នៅក្នុងរយៈពេលដែលពុំទាន់មានដំណោះស្រាយបញ្ហាកម្ពុជា ចលនាមិនចូលបក្សសម្ព័ន្ធនាសម័យប្រប្រជុំកំពូលលើកទី ៦ នៅទីក្រុងឡាហាវ៉ាននៃប្រទេសគុយបា និង នាសម័យប្រជុំកំពូលលើកទី ៧ នៅទីក្រុងញូវដែលីនៃប្រទេសឥណ្ឌា បានសម្រេចរក្សាទុកអាសនៈកម្ពុជាឲ្យនៅទំនេរ និង បានអំពាវនាវឲ្យមានការដកកងទ័ពបរទេសចេញពីតំបន់អាស៊ីភាគអគ្នេយ៍ និង ឲ្យបន្តរកដំណោះស្រាយនយោបាយតាមរយៈការចរចា ។ ចលនានេះបានបញ្ចូលបញ្ហាកម្ពុជាទៅក្នុងបញ្ហាតំបន់អាស៊ីភាគអគ្នេយ៍ និង ផ្តល់ការយល់ព្រមដល់ការប្រឹងប្រែងទាំងអស់ សំដៅទៅកសាងឲ្យបានឆាប់រហ័សនូវតំបន់មួយដែលមានសន្តិភាព សេរីភាព និង អព្យា

[224] ក្នុងបទសម្ភាសន៍របស់សម្តេចតេជោ ហ៊ុន សែន ជាមួយក្រុមស្រាវជ្រាវប្រវត្តិសាស្ត្រដឹកនាំដោយ ឯ.ឧ. អៀង មូលី និង ស៊ិន សំណាង កាលពីថ្ងៃ ១៦ មីនា ២០១០ សម្តេចតេជោបានឲ្យដឹងថាលោកបាបញ្ជូនលិខិតសម្ងាត់ជូនលោក គាត ឈន់ ។

[225] គណៈប្រតិភូកម្ពុជាដឹកនាំដោយសម្តេច សីហនុ ក្នុងឋានៈជាព្រះប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា (អេស អិន ស៊ី) បានទៅចូលរួមសន្និសីទកំពូលលើកទី១០ នៃចលនាមិនចូលបក្សសម្ព័ន្ធនេះ នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី ពីថ្ងៃទី ១-៦ ខែកញ្ញា ១៩៩២ ។ រូបខ្ញុំ (អៀង មូលី) ក៏បានចូលរួមជាសមាជិកនៃគណៈប្រតិភូកម្ពុជានេះដែរ ។

ក្រឹតភាព ។

នៅក្នុងលិខិតចុះថ្ងៃទី ២៦ មីនា ១៩៨៦ ទៅជូនអស់លោករដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសសមាជិកចលនាមិនចូលបក្សសម្ព័ន្ធ លោក ង្វៀង កូថាច់ រដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាម បានស្នើឲ្យចលនានេះបន្តទុកអាសនៈកម្ពុជានៅទំនេរតទៅទៀត សម្រាប់សម័យប្រជុំកំពូលលើកទី ៨ នាខែ កញ្ញា ១៩៨៦ នៅទីក្រុងហារ៉ារ៉េ (Harare) នៃប្រទេស ស៊ីមបាវ៉េ (Zimbawe) ដោយសំអាងថា ដើម្បីជៀសវាងការខ្វែងមតិគ្នានៅក្នុងចលនានេះ ។ លោក ង្វៀង កូថាច់ ក៏បានស្នើឲ្យសន្និសីទលើកទី ៨ បន្តប្រកាន់គោលជំហរដដែលដូចសម័យប្រជុំកំពូលមុនៗដែរ ចំពោះបញ្ហាកម្ពុជា និង តំបន់អាស៊ីភាគអគ្នេយ៍[226]។ នៅក្នុងលិខិតដដែលនោះ ប្រមុខការទូតវៀតណាម បានឲ្យដឹងថាក្រុមប្រទេសឥណ្ឌូចិនដែលមានប្រទេសវៀតណាមជាតំណាង និង ក្រុមប្រទេសអាស៊ានដែលមានប្រទេសឥណ្ឌូណេស៊ីជាតំណាង បានចាប់ផ្តើមចរចាគ្នារួចទៅហើយ រីឯការចរចាទ្វេភាគីក៏បានចាប់ផ្តើមដែរ រវាងវៀតណាមជាមួយម៉ាឡេស៊ី និង រវាងម៉ាឡេស៊ីជាមួយលាវ ។ តាមរយៈសកម្មភាពនេះ វៀតណាមព្យាយាមធ្វើឲ្យមានការចរចាគ្នាក្នុងលំដាប់តំបន់ ដែលក្នុងនោះការទាមទារណាមួយឲ្យដកកងទ័ពវៀតណាមពីកម្ពុជា ក៏ត្រូវភ្ជាប់ជាមួយការដកកងទ័ពបរទេសទាំងអស់ពីប្រទេសដទៃនៅក្នុងតំបន់អាស៊ីភាគអគ្នេយ៍ ដូចជាដកកងទ័ពអាមេរិកចេញពីប្រទេសហ្វីលីពីនដែរ ដើម្បីធ្វើតំបន់នេះឲ្យទៅជាតំបន់សន្តិភាព សេរីភាព និង អព្យាក្រឹត ។ ជាមួយនិងគោលជំហរជាសាធារណៈនេះ ដែលវៀតណាមបានភ្ជាប់បញ្ហាកម្ពុជាទៅនិងបញ្ហាតំបន់ និង បានព្យាយាមគេចចេញពីការចោទប្រកាន់ថាជាអ្នកឈ្លានពានកម្ពុជា មេដឹកនាំវៀតណាមក៏បានខឹតខំជំរុញឲ្យមានការជួបចរចាគ្នារវាងភាគីខ្មែរគឺ រដ្ឋាភិបាលចម្រុះត្រីភាគី និង រដ្ឋាភិបាលក្រុង

---

[226] Nguyen Co Thach, Vietnamese Foreign Minister, Letter to Foreign Ministers of Non-Aligned Countries, Hanoi, March 26, 1986.

ភ្នំពេញជាមុនសិន ។

## វៀតណាមស្នើសម្តេចរៀបចំឲ្យមានការចរចាជាពីរដំណាក់កាល

នៅវេលាម៉ោង ១០ កន្លះយប់ទី ២៤ តុលា ១៩៨៦ សម្តេច សីហនុ បានកោះហៅអស់លោកឯកអគ្គរដ្ឋទូតនៃរដ្ឋាភិបាលត្រីភាគីគឺ លោក អ៊ុម ស៊ីម តំណាង រ.ជ.រ.ប.ខ. អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន តំណាងហ្វ៊ុន ស៊ិន ប៉ិច លោក ជួន ប្រសិទ្ធិ តំណាងខ្មែរក្រហមប្រចាំនៅអង្គការសហប្រជាជាតិឲ្យទៅចូលគាល់ព្រះអង្គនៅថ្ងៃបន្ទាប់វេលាម៉ោង ១២ កន្លះ នៅសណ្ឋាគារ ហេមស្លី នៅទីក្រុងញ៉ូវយ៉ក ដើម្បីចូលរួមប្រជុំការងារ និង នាំព័ត៌មានទៅជូនថ្នាក់ដឹកនាំនៃភាគីរៀងៗខ្លួនៗ ។ ដោយមានវត្តមានលោក ខែក ស៊ីសូដា នៅអមព្រះអង្គផង សម្តេច សីហនុ ជំរាបអស់លោកទូតទាំងនោះថាកាលពីថ្ងៃទី ២៤ តុលា វេលា ម៉ោង ១១ កន្លះព្រឹក ព្រះអង្គបានប្រទានសវនាការឲ្យលោកឯកអគ្គរដ្ឋទូតអូទ្រីស កាល ហ្វីសស្ល័រ (Karl Fishcer) ចូលគាល់ដើម្បីពិភាក្សាការងារ ។ ក្នុងសវនាការនោះ លោកទូតអូទ្រីសបានទូលព្រះអង្គថា ប្រទេសវៀតណាមបានស្នើតាមរយៈប្រទេសអូទ្រីស សូមឲ្យមានការចរចាជាពីរដំណាក់កាលគឺៈ ដំណាក់កាលទី១ហៅថាដំណាក់កាលជាតិដែលសុំឲ្យសម្តេច រួមជាមួយអ្នកតំណាងរ.ជ.រ.ប.ខ.មួយរូប និង អ្នកតំណាងខ្មែរក្រហមមួយរូបលើកលែងតែ ប៉ុល ពត ចេញ ជួបចរចាជាមួយលោក ហេង សំរិន និង លោក ហ៊ុន សែន នៅទីក្រុងវីយែន ប្រទេសអូទ្រីស ។ ដំណាក់កាលទី២ ហៅថាដំណាក់កាល អន្តរជាតិ ដែលប្រទេសវៀតណាម ព្រមជាមួយមហាអំណាចឯទៀតនឹងចូលរួមប្រជុំជាមួយភាគីខ្មែរ ប្រសិនបើដំណាក់កាលទី១បានទទួលជោគជ័យ ដើម្បីធានាលើការព្រមព្រៀងរវាងភាគីខ្មែរទាំង

នោះ[227] ។ ចំពោះសំណើរបស់វៀតណាមនេះ សម្តេចបានមានព្រះបន្ទូលជំរាបលោកទូតអូទ្រីសថា ដោយព្រះអង្គស្គាល់ច្បាស់នូវគោលជំហររបស់ដៃគូរបស់ព្រះអង្គក្នុងជួររដ្ឋាភិបាលចម្រុះត្រីភាគី ជំនួបរវាងភាគីខ្មែរនៅទីក្រុងវីយែននោះមិនអាចធ្វើបានទេ ព្រោះខាងត្រីភាគីប្រកាន់យកការចរចាផ្ទាល់ជាមួយវៀតណាម ដោយគេសំអាងថា សង្គ្រាមបច្ចុប្បន្នជាសង្គ្រាមរវាងវៀតណាមដែលជាអ្នកឈ្លានពាន និង កម្ពុជាប្រជាធិបតេយ្យដែលជាអ្នករងគ្រោះ មិនមែនជាសង្គ្រាមស៊ីវិលរវាងខ្មែរ និង ខ្មែរនោះទេ ។ ក៏ប៉ុន្តែ ប្រសិនបើវៀតណាមសុខចិត្តចូលមកចរចាជាមួយរដ្ឋាភិបាលត្រីភាគី ភាគីខ្មែរម្ខាងទៀតនៅភ្នំពេញអាចចូលរួមក្នុងសមាសភាពនៃគណៈប្រតិភូរបស់វៀតណាម ។ សម្តេចជំរាបអស់លោកទូតខ្មែរត្រីភាគីថា នេះគ្រាន់តែជាការយល់ឃើញផ្ទាល់របស់ព្រះអង្គតែប៉ុណ្ណោះ ព្រោះព្រះអង្គជឿថា នៅពេលនេះ វៀតណាមមិនអាចទទួលយកតាមគោលជំហរត្រីភាគីបានឡើយ ទោះជាវៀតណាមកំពុងជួបបញ្ហាជាច្រើន និង កំពុងរកវិធីដោះស្រាយយ៉ាងណាក៏ដោយ ។ មុននិងបិទអង្គប្រជុំ សម្តេច សីហនុ បានស្នើឲ្យកងកម្លាំងត្រីភាគីបង្កើនសកម្មភាពយោធា ដើម្បីបង្ខំឲ្យវៀតណាមចូលមករកតុចរចា ។

នៅចំពោះមុខនៃការផ្តួចផ្តើមគំនិតការទូតជាបន្តបន្ទាប់ ពីសំណាក់ប្រទេសវៀតណាម និង ក្រុមប្រទេសឥណ្ឌូចិន ខ្មែរក្រហមដែលមានចិន និង ក្រុមយោធាថៃនៅពីក្រោយ បានខឹតខំបង្ហាញរូបភាពនៃឯកភាពស្អិតរមួតរវាងកងកម្លាំងត្រីភាគី ដោយជំរុញឲ្យមានការរួមប្រជុំអគ្គមេបញ្ជាការកងទ័ពនៃភាគីទាំងបី ។ នៅថ្ងៃទី ១៨ វិច្ឆិកា ១៩៨៦ ក្នុងឋានៈជាព្រះរាជតំណាងសម្តេច សីហនុ និង ជាអគ្គមេបញ្ជាការនៃកងទ័ពសីហនុនិយម ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ បានធ្វើជាអធិបតីនៃអង្គប្រជុំមួយដែលមានលោក សុន សេន ខាងខ្មែរក្រហម និង លោក សក់ ស៊ុតសាខន

[227] Um Sim, Propositions Vietnamiennes Pour Une Négociation En Deux Phases, Une Note Sur la Réunion de Travail, à l'hotel Helmsley, New York, le 24 octobre 1986.

ខាងក.ជ.រ.ប.ខ. ចូលរួម ហើយបានចេញសេចក្តីប្រកាសមួយ មានចំណុចជាអាទិ៖[228]-សំដែងការរីករាយចំពោះជ័យជំនះយោធាក្នុងរដូវវស្សាទី ៨ កន្លងទៅ -រីករាយ ចំពោះកិច្ចសហការកាន់តែល្អរវាងកងទ័ពទាំងបី -ឯកភាពសកម្មភាពយោធានៅរដូវប្រាំងទី ៩ -ខឹតខំពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការ និង សាមគ្គីភាពរវាងកងកម្លាំងទាំងបីភាគី ។ ចំណុចសំខាន់នៃអង្គប្រជុំនេះ ក្រៅពីបង្ហាញរូបភាពស្តីពីឯកភាព សាមគ្គីភាព និង កិច្ចសហប្រតិបត្តិការល្អនៃកម្លាំងត្រីភាគី វត្តមានរបស់លោក សក់ ស៊ុតសាខន ដែលកំពុងដណ្តើមតួនាទីដឹកនាំពីលោកតា សឺន សាន ជាសញ្ញាឲ្យដឹងថា ក្រុមយោធាថៃ និង ប្រទេសគាំទ្ររ.ជ.រ.ប.ខ. នៅតែទទួលស្គាល់លោកឧត្តមសេនីយរូបនេះជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ. ទោះជាលោកតាសឺន សាន សប្បាយចិត្ត ឬ មិនសប្បាយចិត្តក៏ដោយ ។ តាមពិតដូចខ្ញុំបានសរសេរនៅវគ្គមុនរួចហើយ នៅចុងឆ្នាំ ១៩៨៦ ក្រុមយោធាថៃបង្ខំឲ្យលោកតា សឺន សានធ្វើការជានាឡើងវិញជាមួយលោក សក់ ស៊ុតសាខន ។ ដូច្នេះហើយទើបនៅថ្ងៃទី ១១ មករា ១៩៨៧ លោកតា សឺន សាន បានចេញក្រឹត្យតែងតាំងលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ. ទោះជាលោកតាប្រធានចង់ដាក់លក្ខខណ្ឌយ៉ាងណាក៏ដោយ ។ តាមពិតទៅ លោក ឆាវលិត បានដាក់កំហឹតឲ្យភាគីលោកតា សឺន សាន និង ឧត្តមសេនីយ សក់ ស៊ុតសាខន បញ្ចប់ជម្លោះផ្ទៃក្នុងឲ្យបានជាស្ថាពរនៅដំណាច់ឆ្នាំ ១៩៨៦ នោះ[229]។ ក្នុងលិខិតចុះថ្ងៃទី ១៨ ធ្នូ ១៩៨៦ ផ្ញើជូនលោកតាប្រធានរ.ជ.រ.ប.ខ. លោក សក់ ស៊ុតសាខន បានបញ្ជាក់ថាអ្នកនាំពាក្យរបស់លោក ឆាវលិត បានព្រមានថាបើក្នុងពីរអាទិត្យទៀត មិនមានការស្រុះស្រួលគ្នាទេនោះ រ.ជ.រ.ប.ខ.នឹងត្រូវវិនាសសាបសូន្យមិន

[228] នរោត្តម រណឫទ្ធិ-សុន សេន-សក់ ស៊ុតសាខន, សេចក្តីប្រកាសព័ត៌មាន, ថ្ងៃទី ១៨ វិច្ឆិកា ១៩៨៦ ។
[229] សក់ ស៊ុតសាខន, [លិខិត] ជូនឯកឧត្តម សឺន សាន ប្រធានរ.ជ.រ.ប.ខ, ថ្ងៃទី ១៨ ធ្នូ ១៩៨៦ ។

ខានឡើយ ។

## សេអូសេស្គូ ទូលសម្តេចឲ្យខំរកដំណោះស្រាយនយោបាយ

នៅដើមឆ្នាំ ១៩៨៧ សម្តេច សីហនុ យាងទៅប្រទេសរូម៉ានីម្តងទៀត ។ នៅក្នុងជំនួបជាមួយលោកប្រធានាធិបតី សេអូសេស្គូ (Ceausescu) នៅថ្ងៃទី ១២ មករា ១៩៨៧ ក្នុងរយៈពេល ២ ម៉ោង នៅទីក្រុងប៊ុយការ៉េស សម្តេច សីហនុ និង លោកប្រធានាធិបតី បានផ្លាស់ប្តូរមតិគ្នាលើបញ្ហាកម្ពុជា ។ សម្តេចព្រះប្រធាននៃកម្ពុជាប្រជាធិបតេយ្យ បានរៀបរាប់សភាពការណ៍នៅលើសមរភូមិថាមានភាពអនុគ្រោះនៅគ្រប់ចំណុចដល់ចលនាតស៊ូ ក៏ប៉ុន្តែលោកប្រធានាធិបតីឆ្លើយតបវិញថា នៅលើឆាកអន្តរជាតិ សភាពការណ៍អនុគ្រោះដល់ការស្វែងរកដំណោះស្រាយនយោបាយ ដោយសន្តិវិធី និង ប្រកបដោយសមធម៌ ។ លោក សេអូសេស្គូ ទូលសម្តេចថា ប្រទេសវៀតណាមបានស្នើយកទីក្រុងប៊ុយការ៉េសជាទីកន្លែងជួបពិភាក្សាគ្នារវាង សីហនុ និង ហេង សំរិន ។ សម្តេច សីហនុ ឆ្លើយថាជំនួបបែបនេះមិនអាចធ្វើបានឡើយ ដោយហេតុថាដៃគូរបស់ព្រះអង្គក្នុងត្រីភាគីគឺ ខ្មែរក្រហម និង លោកតា សឺន សាន នឹងធ្វើការជំទាស់[230] ។ លោកប្រធានាធិបតីទូលសម្តេចទៀតថា ប្រទេសវៀតណាម នឹងមិនទទួលយកឡើយនូវការចោទប្រកាន់ថាជាអ្នកឈ្លានពានកម្ពុជា ។ លោកថ្វាយយោបល់ថាជាការសមហេតុសមផលណាស់ដែលត្រីភាគីត្រូវបង្កើតរដ្ឋាភិបាលចតុភាគីជាមួយភាគី ហេង សំរិន ដើម្បីធ្វើជារដ្ឋាភិបាលផ្សះផ្សាជាតិមួយ ។ លោក សេអូសេស្គូ ទូលទៀតថាគឺរដ្ឋាភិបាលផ្សះផ្សាជាតិនេះហើយ ដែលជាអ្នកស្នើសុំឲ្យប្រទេសវៀតណាមដកកងទ័ពរបស់គេចេញពី

---

[230] Norodom Sihanouk, mon compte-rendu succinct de mon entretien politique, d'une durée de 2 heures, avec Son Excellence Monsieur le Président Nicolae Ceausescu de la République Socialiste de Roumanie, Bucarest, Lundi 12 Janvier 1987.

កម្ពុជាជាពីរដំណាក់កាល ដូចសំណើរបស់រដ្ឋាភិបាលចម្រុះត្រីភាគីធ្លាប់បានស្នើយ៉ាងនោះដែរ ។ ប្រទេសវៀតណាមប្រាកដជានឹងដកកងទ័ពតាមសំណើមិនខានឡើយ ។

ទោះជាភ្លាមៗនោះ សម្តេច សីហនុ មិនទាន់ទទួលយកបាននូវសំណើជួបផ្ទាល់ជាមួយភាគីភ្នំពេញយ៉ាងណាក៏ដោយ ក៏ព្រឹត្តិការណ៍ជាបន្តបន្ទាប់បានបញ្ជាក់ថាព្រះអង្គមិនបានបោះបោលទាំងស្រុងនូវគំនឹតជួបចរចានេះទេ ។ ម្យ៉ាងទៀតគួរកត់សំគាល់ផងដែរថា សំណើរបស់លោកប្រធានាធិបតីរូម៉ានីនេះ បានធ្វើឲ្យខ្មែរក្រហមចាប់អារម្មណ៍យ៉ាងខ្លាំង ។ នៅថ្ងៃទី ១៨ មករា ១៩៨៧ លោក ខៀវ សំផន បានសរសេរសំបុត្រមួយច្បាប់ថ្វាយសម្តេច សីហនុ ក្នុងន័យចង់ចូលគាល់ដើម្បីពិភាក្សាអំពីសំណើរបស់លោក សេអូសេស្គូ ឬ ដើម្បីស្នើព្រះរាជយោបល់ថាតើគួរទៅជួបលោកប្រធានាធិបតីរូម៉ានីនេះ នៅទីក្រុងប៊ុយការ៉េសដែរឬទេ? នៅថ្ងៃទី ២៥ មករា ១៩៨៧ សម្តេច សីហនុ បានផ្ញើសារទូរលេខតបវិញ ដោយបានណែនាំទាំងលោក ខៀវ សំផន ទាំងលោកតា សឺន សាន ថាមិនចំបាច់ទៅរូម៉ានី ឬ មកគាល់ព្រះអង្គទេ ព្រោះថាព្រះអង្គបានដោះស្រាយជាមួយលោកប្រធានាធិបតីសេអូសេស្គូ រួចស្រេចបាច់អស់ហើយ តាមសំណូមពររបស់កម្ពុជាប្រជាធិបតេយ្យគឺគ្មានការចរចាផ្ទាល់ណាមួយ រវាងរដ្ឋាភិបាលចម្រុះត្រីភាគីជាមួយភាគីក្រុងភ្នំពេញឡើយ[231]។ នៅក្នុងសារទូរលេខនោះ សម្តេច សីហនុ ហាក់ដូចជាចង់ផ្តាំផ្ញើផ្ទាល់ឲ្យដៃគូពីរនាក់ទៀតរបស់ព្រះអង្គថា បើនៅតែប្រកាន់គោលជំហររឹងត្អឹងទៀតនោះ មិនចាំបាច់ខាតពេលវេលាខ្វាយខ្វល់អំពីដំណោះស្រាយរូម៉ានីនេះទេ ដោយព្រះអង្គទ្រង់ជ្រាបច្បាស់ថា ក្រុងហាណូយប្រាកដជាមិនព្រមអង្គុយចរចាផ្ទាល់ជាមួយរដ្ឋាភិបាលចម្រុះត្រីភាគី ដែលមានខ្មែរក្រហមជាឆ្អឹងខ្នងនោះឡើយ ។

---

[231] Norodom Sihanouk, Télégramme A Son Excellence Khieu Samphan, Vice Président du Kampuchea Démocratique, c/o S.E. Ambassadeur Chan Youran, Pekin, 25 janvier 1987.

ចំណែកខាង រ.ជ.រ.ប.ខ.វិញបន្ទាប់ពីបានបញ្ចប់ជំលោះផ្ទៃក្នុងរួចមក រ.ជ.រ.ប.ខ.ជាពិសេសលោកតា សឺន សាន បានផ្តើមគំនឹតនយោបាយថ្មីមួយភ្លាមគឺ គំនឹតបង្កើតតំបន់អង្គរជាតំបន់វប្បធម៌អន្តរជាតិគ្មានកងកំលាំងប្រដាប់អាវុធ ។ ក៏ប៉ុន្តែគួរបញ្ជាក់ថា ការជានាគ្នារវាងលោកតា សឺន សាន និង លោកឧត្តមសេនីយ សក់ ស៊ុតសាខន នាពេលនោះ គ្រាន់តែជាការជានាតាមរូបភាពក្រៅតែប៉ុណ្ណោះ មិនមែនជាការស្រុះស្រួលគ្នាពិតប្រាកដឡើយ ព្រោះភាគីនីមួយៗនៅតែបន្តរក្សាគោលជំហរដើមរបស់គេរៀងៗខ្លួនដដែល ។ លោកឧត្តមសេនីយ សក់ ស៊ុតសាខន នៅតែបន្តចាត់ចែងការងារខាងផ្នែកកងទ័ពតែម្នាក់ឯង ដោយមិនបានពិគ្រោះ ឬ ទទួលការព្រមព្រៀងជាមុនពីលោកតាប្រធាន ដូចមានចែងក្នុងឧបសម្ព័ន្ធនៃក្រឹត្យតែងតាំងអគ្គមេបញ្ជាការនោះឡើយ ។ ភស្តុតាងនៃចំណាត់ការជាអត្តនោម័តរបស់លោកឧត្តមសេនីយ សក់ ស៊ុតសាខន ភ្លាមៗនោះគឺ ការបំពាក់ឋានន្តរសេក្តិថ្នាក់ឧត្តមសេនីយ ជាពិសេសដល់នាយទាហានក.ជ.រ.ប.ខ. ដែលនាំឲ្យមានការដាស់តឿនក្រើនរំលឹកពីលោកតា សឺន សាន ផង[232] ។

# លោកតាចង់សុំឲ្យតំបន់អង្គរអព្យាក្រឹត

ដោយសំអាងទៅដល់ការប្រកាស អំពាវនាវរបស់លោកអតីតរដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសអូទ្រីស វីល្លីបាល ប៉ា កាលពីឆ្នាំ ១៩៨៤ ក្នុងឋានៈជាប្រធានសន្និសីទអន្តរជាតិស្តីពីកម្ពុជា ឬ អាយ ស៊ី ខេ លោកតា សឺន សាន បានចេញផ្សាយនូវអនុស្សារណៈមួយស្តីអំពីតំបន់វប្បធម៌អង្គរ ជាតំបន់គ្មានកំលាំងប្រដាប់អាវុធ ជាតំបន់អព្យាក្រឹត្យ ដើម្បីឲ្យអ្នកជំនាញការអន្តរជាតិមកជួយជួសជុល

[232] សឺន សាន ប្រធានរ.ជ.រ.ប.ខ. ផ្ញើជូនលោកឧត្តមសេនីយ សក់ ស៊ុតសាខន ថ្ងៃទី ២២ កុម្ភៈ ១៩៨៧ ។

កែលំអប្រាសាទអង្គរវត្ត និង ប្រាសាទអង្គរធំ[233] ។ ចំណុចសំខាន់នៃគំនិតនោះគឺ អង្គការយូណេស្កូ ជាអ្នកផ្តើមគំនិតស្នើឲ្យមានតំបន់វប្បធម៌អន្តរជាតិ ដោយមានការយល់ព្រមពីប្រទេសសមាជិក ជាពិសេសប្រទេសនៅអឺរ៉ុប រួមទាំងប្រទេសរូម៉ានី និង យូហ្គោស្លាវីផង ។ ចំណែកឯប្រទេសឥណ្ឌាដែលមានអ្នកជំនាញការនៅហ្នឹងកន្លែងស្រាប់ ក៏អាចជួយធ្វើឲ្យសម្រេចឡើងនូវគំនិតផ្តួចផ្តើមនេះ ។ អនុស្សារណៈនោះបញ្ជាក់ថា ក្រោយពេលដែលគំនិតនេះបានត្រូវទទួលយកទាំងអស់គ្នា ហើយតំបន់វប្បធម៌អង្គរត្រូវធ្វើអន្តរជាតូបនីយកម្ម ដោយអង្គការយូណេស្កូជាអ្នកធានាឧបត្ថម្ភគ្រប់យ៉ាង ។ ក្នុងន័យនេះ ទាំងព្រលានយន្តហោះ ទាំងទីក្រុងសៀមរាប ត្រូវបើកឲ្យអ្នកជំនាញការអន្តរជាតិចេញចូលដោយសេរី ព្រមទាំងត្រូវអនុញ្ញាតឲ្យមានការនាំចូលនូវសំភារៈ និង ស្បៀងទាំងឡាយមកក្នុងតំបន់វប្បធម៌ដែលអាចនឹងបើកឲ្យអ្នកទេសចរណ៍មកពីគ្រប់ភាគីចូលមកទស្សនាផង ។ ក៏ប៉ុន្តែអនុស្សារណៈនេះ ក៏បានដាក់លក្ខខណ្ឌថា រាល់ការចរចាបង្កើតតំបន់វប្បធម៌នេះ មិនត្រូវនាំឲ្យមានការទទួលស្គាល់រដ្ឋាភិបាលក្រុងភ្នំពេញ មុនពេលដែលមានការផ្សះផ្សាជាតិនោះឡើយ ។ ការលើកឡើងនូវគំនិតផ្តួចផ្តើមនេះ សំអាងថាបេតិកភណ្ឌវប្បធម៌អង្គរ ដែលត្រូវបានខូចខាតតាំងពីឆ្នាំ ១៩៧១ មកនោះ ត្រូវការជួសជុលឲ្យបានឆាប់រហ័ស និង មិនត្រូវស្ថិតនៅក្រោមការត្រួតត្រារបស់ភាគីមានជម្លោះណាមួយឡើយ ។ បើនិយាយឲ្យស្រួលស្តាប់តំបន់អង្គរ-សៀមរាប អាចត្រូវបានរំដោះចេញពីការកាន់កាប់របស់រដ្ឋាភិបាលភ្នំពេញ តាមរយៈអន្តរជាតូបនីយកម្មនៃតំបន់នេះ ។ ក្នុងលិខិតផ្ញើថ្វាយសម្តេច សីហនុ និង ជូនលោក ខៀវ សំផន លោក តា សឺន សាន បានរំលឹកថាថ្នាក់ដឹកនាំរដ្ឋាភិបាលចម្រុះធ្លាប់គាំទ្រឲ្យលោកតាក្នុងឋានៈជារដ្ឋមន្ត្រីទី១ សរសេរលិខិតគាំទ្រលោក វីល្លីបាល ប៉ា ដែលប្រកាសសុំ ឲ្យបង្កើតតំបន់វប្បធម៌នេះកាលពី

[233] The Office of the Prime Minister of the Coalition Government of Democratic Kampuchea, Memorandum on the conception of an Angkor cultural zone from all the presence of the armed forces, February 26, 1987.

ឆ្នាំ ១៩៨៤ ។ ក៏ប៉ុន្តែ លោក ខៀវ សំផន ហាក់ដូចជាមានក្តីបារម្ភយ៉ាងខ្លាំងចំពោះគំនឹតផ្តួចផ្តើមនេះ ។ នៅក្នុងចម្លើយផ្ញើជូនលោកតា សឺន សាន លោក ខៀវ សំផន បានលើកឡើងថា រដ្ឋាភិបាលចម្រុះធ្លាប់ បានពិភាក្សាបញ្ហានេះ នៅក្រោមព្រះអធិបតីភាពសម្តេច សីហនុ ហើយទាំងអស់គ្នាយល់ឃើញថា គ្រប់ជំហាននៃការគិតគូរ ត្រូវមានការប្រយ័ត្នប្រយែងខ្ពស់បំផុតគឺ មិនត្រូវនាំទៅឲ្យមានការទទួលស្គាល់របបក្រុងភ្នំពេញដោយអន្តរជាតិសោះឡើយ[234] ។ លោក ខៀវ សំផន សុំឲ្យផ្តល់ព័ត៌មានច្បាស់លាស់ថែមទៀត ដើម្បីពិចារណា ជាពិសេសខ្មែរក្រហមចង់ដឹងថា តើមានប្រទេសជាមិត្តណាខ្លះដែលលោកតា សឺន សាន អះអាងថាបានគ្រាំទ្រគំនិតនេះ? តាមពិតទៅ ខ្មែរក្រហមក៏មានបំណងដណ្តើមកាន់កាប់តំបន់នេះដែរដូច្នេះខ្មែរក្រហមគ្មានផលប្រយោជន៍អ្វី ក្នុងការប្រកាសតំបន់វប្បធម៌អន្តរជាតិនេះឡើយ ។ ចំណែកឯក្រុមលោកតា សឺន សាន គ្រាន់តែនឹកគិតថា សហគមន៍អន្តរជាតិប្រាកដជាអាចធ្វើការគាបសង្កត់ប្រទេសវៀតណាម និង រដ្ឋាភិបាលក្រុងភ្នំពេញ ដើម្បីយកតំបន់អង្គរ-សៀមរាប ជាតំបន់អន្តរជាតិដែលមិនត្រូវស្ថិតនៅក្រោមអំណាចភាគីណាមួយឡើយ ព្រោះថាប្រាសាទអង្គរ មានតម្លៃវប្បធម៌ធំធេងមហាសាល មិនអាចមានការប្រឆាំងជំទាស់ក្នុងការជួសជុលកែលំអឡើយ ។ បើពិនិត្យលើអនុស្សារណៈនោះ គេមិនទាន់ឃើញចំណុចលំអិត ដែលអាចយកមកអនុវត្តបានឡើយ ។ ដូច្នេះទើបនៅថ្ងៃទី ១៥ មិថុនា ១៩៨៧ ពីទីក្រុងប៉ារីសប្រទេសបារាំង លោកតា សឺន សាន បានចេញសេចក្តីថ្លែងការណ៍ បញ្ជាក់អំពីតំបន់វប្បធម៌នោះដូចតទៅ៖[235] ១- កងទ័ពបរទេស និង កម្លាំងប្រដាប់អាវុធដែលពាក់ព័ន្ធក្នុងជម្លោះ ត្រូវដកចេញក្នុងរង្វង់ ៥០ គ.ម ពីតំបន់សៀមរាប-អង្គរ ២-

[234] Khieu Samphan, Vice-Président du Kampuchea Démocratique chargé des Affaires Etrangères, à S.E. M. Son Sann, Premier Ministre du Gouvernement de Coalition du Kampuhea Démocratique, le 24 avril 1987.

[235] Son Sann, Déclaration de Son Excellence Son Sann, Premier Ministre du Governement de Coalition de Kampuchea Démocratique(GCKD) Président de Front National de Libération du Peuple Khmers (FNLPK), Paris, le 15 Juin 1987.

អនុញ្ញាតឲ្យតំណាងភាគីទាំងអស់មកជួបជុំគ្នាដោយសេរី ដើម្បីពិភាក្សាអំពីនីតិវិធីបច្ចេកទេសស្តីអំពីការជួសជុលកែលំអប្រាសាទអង្គរ ដោយមិននាំឲ្យទទួលស្គាល់តាមផ្លូវច្បាប់ (នូវរបបគ្រប់គ្រងទីក្រុងភ្នំពេញ) នោះឡើយ ដើម្បីនាំមកនូវជំនួយអន្តរជាតិដូចជាជំនួយពីអង្គការយូណេស្កូជាដើម ៣- អនុញ្ញាតឲ្យអ្នកបច្ចេកទេសខ្មែរ រួមជាមួយអ្នកបច្ចេកទេសអន្តរជាតិនៃអង្គការយូណេស្កូ ចេញចូលតំបន់នេះដោយមានការធានាសន្តិសុខអំពីអន្តរជាតិ ។

នៅថ្ងៃទី ៤ កក្កដា ១៩៨៧ លោក អាម៉ាឌូ ម៉ាតា ម៉ាក់បូវ (Amadou-Mahtar M'Bow) អគ្គនាយកអង្គការយូណេស្កូ បានផ្ញើលិខិតឆ្លើយតបចំពោះសំណើរបស់លោកតា សឺន សាន ថា[236] អង្គការយូណេស្កូបានយកចិត្តទុកដាក់ក្នុងបញ្ហាអភិរក្ស និង ការពារប្រាសាទអង្គរវត្ត ហើយលោកអគ្គនាយកក៏ធ្លាប់លើកយកបញ្ហានេះមកជជែកជាច្រើនដង នាសម័យប្រជុំរបស់ក្រុមប្រឹក្សាប្រតិបត្តិនៃអង្គការយូណេស្កូនេះដែរ ។ លោកអគ្គនាយកសន្យាថានឹងធ្វើគ្រប់យ៉ាងក្នុងអំណាចរបស់អង្គការយូណេស្កូ ដើម្បីឲ្យសំរេចគោលដៅនេះ ។ បន្ទាប់មក សំណើរបស់លោកតា សឺន សាន ក៏ស្ងាត់បាត់ឈឹងរហូតមក ។ គំនិតផ្តួចផ្តើមនយោបាយយកតំបន់អង្គរ-សៀមរាប ជាតំបន់វប្បធម៌អន្តរជាតិ ជាតំបន់អព្យាក្រឹត្យគ្មានកងទ័ព ឬ គ្មានកងប្រដាប់អាវុធនេះ មិនបានឈានទៅទទួលផ្លែផ្កាឡើយ ដោយខ្វះការគាំទ្រពីគ្រប់ភាគីដែលពាក់ព័ន្ធនៅក្នុងជម្លោះ ។ ភាគីភ្នំពេញដែលកំពុងស្វែងរកការទទួលស្គាល់ពីអន្តរជាតិ ប្រាកដជាមិនអាចទទួលយកគំនិតនេះទេ ព្រោះថ្នាក់ដឹកនាំទីក្រុងភ្នំពេញក៏អាចមើលឃើញនូវតម្លៃដ៏ធំធេងរបស់ប្រាសាទអង្គរ ហើយក៏អាចយកបញ្ហាពាក់ព័ន្ធតំបន់ប្រាសាទទាំងនេះ មកធ្វើជាកម្មវត្ថុមួយនៃការតស៊ូស្វែងរកការទទួលស្គាល់អន្តរជាតិបានដែរ ។ ដូច្នេះចំណុចដែលចង់គេចចេញពីការទទួលស្គាល់រដ្ឋាភិបាល

[236] Amadou-Mahtar M'Bow, Le Directeur général, UNESCO, (à) S. Exc. Monsieur Son Sann, Premier Ministre du Kampuchea Démocratique, Paris, le 4 juillet 1987.

ក្រុងភ្នំពេញ ជាចំណុចដែលនាំឲ្យបរាជ័យ ។ ក៏ប៉ុន្តែ ចំពោះលោកតា សឺន សាន យ៉ាងហោចណាស់ ក៏លោកតាចង់ឲ្យអន្តរជាតិមើលឃើញថា លោកតាជាអ្នកយកចិត្តទុកដាក់ក្នុងការថែរក្សាការពារប្រាសាទអង្គរជាងអ្នកដឹកនាំឯទៀត ។ ម្យ៉ាងទៀត លោកតាក៏ចង់បង្ហាញថា រ.ជ.រ.ប.ខ.ក៏ចង់ឲ្យមានការជួបចរចាគ្នារវាងភាគីខ្មែរដែរ ទោះជាគំនិតផ្តួចផ្តើមរបស់លោកតានោះ មិនមានលក្ខណៈប្រាកដនិយមក៏ដោយ ។

# ខ្ញុំទៅឃោសនាជាថ្មីនៅអឺរ៉ុប

សូមបញ្ជាក់ថា ក្នុងខែ កុម្ភៈ និង មីនា ១៩៨៧ នោះ រូបខ្ញុំបានត្រូវចាត់ឲ្យទៅបំពេញបេសកកម្មនៅទ្វីបអឺរ៉ុប ដើម្បីឃោសនារកការគាំទ្រពីសំណាក់ជនភៀសខ្លួនខ្មែរចំពោះរ.ជ.រ.ប.ខ. ជាពិសេសចំពោះលោកតា សឺន សាន ក្រោយពេលដែលមានការផ្សព្វផ្សាយថាជំលោះផ្ទៃក្នុងត្រូវបានបញ្ចប់ ។ បេសកកម្មរបស់ខ្ញុំនាពេលនោះមានគោលដៅពង្រឹងការគាំទ្ររបស់សមាជិកសមាជិការ.ជ.រ.ប.ខ. នៅប្រទេសបារាំង បែលហ្សិក ស្វ៊ីស និង អាឡឺម៉ង់ ។ ប្រធានបទសំខាន់គឺ ផ្តោតលើគុណសម្បត្តិដឹកនាំរបស់លោកតា សឺន សាន និង បញ្ជាក់ពីលក្ខខណ្ឌអត្តនោម័តរបស់លោកតា សឺន សាន ក្នុងការតែងតាំងលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ.ឡើងវិញ ។ តាមពិតទៅ សង្គ្រាមពាក្យសំដីរវាងក្រុមទាំងពីរនៅតែបន្តជានិច្ច ។ សកម្មភាពរបស់ខ្ញុំ គ្រាន់តែជាការឆ្លើយតបទៅនិងសកម្មភាពឃោសនារបស់ក្រុមលោក សក់ ស៊ុតសាខន ដែលមានលោក យ៉ែម ស៉ារុង លោកវេជ្ជបណ្ឌិត យូ គិមយាន និង លោក សំ សុខ ជាដើមជាសកម្មជន ។ សកម្មភាពឃោសនារបស់ខ្ញុំ បានធ្វើឲ្យការគាំទ្ររបស់ជនភៀសខ្លួន សមាជិក សមាជិការបស់រ.ជ.រ.ប.ខ. មានសន្ទុះ និង ភាពសកម្មឡើងវិញយ៉ាងខ្លាំងក្លា នាំឲ្យលោក

ប៉ុង គិមគន ប្រធានការិយាល័យផ្សាយព័ត៌មានរ.ជ.រ.ប.ខ.ប្រចាំទីក្រុងប៉ារីស មានមោទនភាពខ្ពស់ ។ នៅថ្ងៃទី ១៦ មីនា ១៩៨៧ លោក ប៉ុង គិមគន បានផ្ញើលិខិតមួយច្បាប់ជាភាសាបារាំងជូនលោកតាប្រធាន ដើម្បីរាយការណ៍លំអិតអំពីលទ្ធផលជាវិជ្ជមាននៃបេសកកម្មរបស់ខ្ញុំនោះ[237] ។

## ពួកយើងមិនដឹងថាសម្តេចយាងទៅព្យុងយ៉ាង ដើម្បីធ្វើអ្វីទេ ?

នៅថ្ងៃទី ១៦ មេសា ១៩៨៧ លោកប្រធានាធិបតី លី សៀននៀន និង លោកនាយករដ្ឋមន្ត្រី ហ្សាវ ហ្ស៊ីយ៉ាង នៃប្រទេសចិនបានផ្ញើសារអបអរសាទរចំពោះខួបកំណើតលើកទី១២ នៃកម្ពុជាប្រជាធិបតេយ្យថ្វាយសម្តេច សីហនុ ក្នុងឋានៈព្រះអង្គជាប្រធានកម្ពុជាប្រជាធិបតេយ្យ ដោយបញ្ជាក់សាជាថ្មីថារដ្ឋាភិបាល និង ប្រជាជនចិន នឹងបន្តផ្តល់ការគាំទ្រយ៉ាងរឹងមាំ ដល់ប្រជាជនកម្ពុជាក្នុងបុព្វហេតុដ៏ពិសិដ្ឋនៃការតស៊ូប្រឆាំងអំពើរំលោភឈ្លានពានរបស់វៀតណាម ដើម្បីការពារមាតុភូមិ[238]។ នៅថ្ងៃដដែលនោះ សម្តេច សីហនុ បានឆ្លើយតបវិញ ពីទីក្រុងព្យុងយ៉ាង ជាទីដែលព្រះអង្គគង់នៅ ដោយមានព្រះបន្ទូលជាអាទិថា ប្រទេសចិន និង កម្ពុជា ជាបងប្អូន ដែលកំពុងសាមគ្គីគ្នា និង នឹងបន្តសាមគ្គីគ្នាតទៅមុខជាយូរអង្វែង និង ជាយុទ្ធមិត្រដែលមិនអាចបំបែកចេញពីគ្នាបានឡើយ[239] ។

សូមបញ្ជាក់ថានៅឯទីក្រុងបាងកក ពួកយើងមិនបានដឹងថា សម្តេចយាង

---

[237] Pong Kim Koan, le Chef du Bureau d' Information du FNLPK, à Son Excellence le Président du FNLPK et Premier Ministre du GCKD, Paris, le 16 mars 1987.

[238] Li Xiannian, Président de la République Polpulaire de Chine, Zao Ziyang, Premier Ministre du Conseil d'Etat de la République Populaire de Chine, à Samdech Norodom Sihanouk, Président du Kampuchea Démocratique, Son Excellence Son Sann, Premier Ministre du Gouvernement de Coalition du Kampuchea Démocratique, Son Excellence Khieu Samphan, Vice-President du Kampuchea Démocratique, Beijing, le 16 avril 1987.

[239] Norodom Sihanouk, Président du Kampuchea Democratique, à Son Excellence Monsieur LI XIANNIAN, Président de la République Populaire de Chine, Son Excellence Monsieur Zao Ziyang, Premier Ministre du Conseil d' Etat de la République Populaire de Chine, Pyong Yang, le 16 Avril 1987.

ទៅទីក្រុងព្យុងយ៉ាងតាំងពីពេលណាទេ ។ ជាទម្លាប់របស់ព្រះអង្គដែលធ្លាប់ប្រកាន់ក្នុងកាលកន្លងមក ប្រសិនបើសម្តេច សីហនុ មានបំណងធ្វើសកម្មភាពនយោបាយអ្វីមួយ ដែលអាចឲ្យថ្នាក់ដឹកនាំចិនមិនពេញចិត្ត ព្រះអង្គតែងយាងចេញពីប្រទេសនេះទៅគង់នៅប្រទេសដទៃ ជាពិសេស នៅប្រទេសកូរ៉េខាងជើង ដែលព្រះអង្គមានមិត្តជិតស្និទ្ធម្នាក់គឺ លោកប្រធាន គិម អ៊ីល ស៊ុង ជាអ្នកគាំទ្រយ៉ាងពេញទំហឹង ។ មុននឹងយាងចេញពីទីក្រុងប៉េកាំង សម្តេច សីហនុ បានផ្ញើសារទូរលេខមួយច្បាប់ជូនលោកតា សឺន សាន ដើម្បីសុំបញ្ជីឈ្មោះសមាជិកគណៈប្រតិភូរ.ជ.រ.ប.ខ. ដែលត្រូវចូលរួមក្នុងប្រតិភូផ្លូវការនៃរដ្ឋាភិបាលចម្រុះត្រីភាគី សម្រាប់ទស្សនកិច្ចនៅប្រទេសចិន នាខែ សីហា ១៩៨៧ ខាងមុខ ។ នៅក្នុងសារទូរលេខនោះ សម្តេច សីហនុ បានស្នើឲ្យបញ្ចូលឈ្មោះសមាជិកខ្លះមកពីខាងភាគីលោកឧត្តមសេនីយ សក់ ស៊ុតសាខន កុំដាក់តែខាងលោកតា សឺន សាន ក្នុងបញ្ជីគណៈប្រតិភូនោះ ដើម្បីជា "ឧត្តមប្រយោជន៍នៃចលនាតស៊ូជាតិ"[240]។ ហេតុដូច្នោះហើយទើបលោកតា សឺន សាន បានបញ្ចូលឈ្មោះលោកឧត្តមសេនីយ សក់ ស៊ុតសាខន ជាសមាជិកទី៤ នៃគណៈប្រតិភូរ.ជ.រ.ប.ខ. បន្ទាប់ពីឈ្មោះលោកតា សឺន សាន លោក អ៊ឹម ឈូដេត និង លោក ប៊ុន សាយ សម្រាប់ទស្សនកិច្ចរបស់ថ្នាក់ដឹកនាំរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ នៅប្រទេសចិនក្នុងខែ សីហា ១៩៨៧[241] ។

---

[240] Norodom Sihanouk, Président du Kampuchea Démocratique, A S.E. Son Sann, Premier Ministre du CGDK, Beijing 11 Mars 1987.

[241] Son Sann, Prime Minister, Coalition Government Democratic Kampuchea, A Son Altesse Royale Samdech Preah Norodom Sihanouk, Président du Kampuchea Démocratique, le 27 avril 1987.

# ព្រះអង្គផ្អាកធ្វើប្រធានត្រីភាគី ព្រោះខ្មែរក្រហមរំលោភ

គួររំលឹកថា នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ នាទសវត្សរ៍ឆ្នាំ ១៩៨០ នោះ ខ្មែរក្រហមបានបង្កការរំលោភតាមផ្លូវអាវុធ ទៅលើដៃគូមិនមែនកុម្មុយនីស្ត របស់ខ្លួនជាញឹកញាប់ តាមផែនការដណ្ដើមឧត្ដមភាពនៅលើសមរភូមិរបស់ពួកគេ ។ ការរំលោភទាំងនោះរួមមានឃាតកម្មទៅលើយុទ្ធជននៃក.ជ.រ.ប.ខ.ផងដែរ ដូចជាក្នុងករណីឃាតកម្មលើរូបប្រធានកងអនុសេនាតូចក.ជ.រ.ប.ខ. ឈ្មោះ ព្រំ ចំរើន នៅស្រុកពួក ខេត្តសៀមរាប នៅថ្ងៃទី ១២ កុម្ភៈ ១៩៨៧ ដែលនាំឲ្យមានការតវ៉ាជាលាយលក្ខណ៍អក្សរពីភាគីយើង ។ នៅក្នុងលិខិតតវ៉ា លោកតា សឺន សាន ក្នុងនាមជារដ្ឋមន្ត្រីទី១ នៃរដ្ឋាភិបាលចម្រុះ និង ជាប្រធានរ.ជ.រ.ប.ខ.បានព្រមាន លោក ខៀវ សំផន ថាសកម្មភាពបែបនេះជាអំពើប្រព្រឹត្តិឡើងដោយចេតនា និង គិតទុកជាមុន ព្រមទាំងសុំឲ្យខ្មែរក្រហមបញ្ឈប់យ៉ាងឆាប់ ដើម្បីរក្សាយុទ្ធសាមគ្គីភាពក្នុងផ្ទៃកងកម្លាំងរដ្ឋាភិបាលចម្រុះ[242] ។ ក្រៅពីការរំលោភតាមផ្លូវអាវុធ ពួកខ្មែរក្រហម នៅឆ្លៀតឱកាសកេងយកចំណេញក្នុងការចូលរួមសន្និសីទ ឬ ប្រជុំអន្តរជាតិតែម្នាក់ឯង ដោយលាក់មិនឲ្យដៃគូពីរទៀតដឹង តាមរយៈការក្ដោបក្ដាប់កិច្ចការបរទេសដែលមានលោក ខៀវ សំផន ជាអ្នកទទួលខុសត្រូវក្នុងជួររដ្ឋាភិបាលចម្រុះ ។

នៅក្នុងលិខិតតវ៉ាលោករដ្ឋមន្ត្រីទី១ សឺន សាន សូមឲ្យខ្មែរក្រហមជួយពង្រឹងស្មារតីសហប្រត្តិការក្នុងរង្វង់រដ្ឋាភិបាលត្រីភាគី ឲ្យបានរឹងប៉ឹងឡើងវិញឲ្យសមស្របតាមគោលការណ៍រួមរបស់រដ្ឋាភិបាលនេះ[243] ។ ម្យ៉ាងទៀត ការរំលោភរបស់ពួកខ្មែរក្រហម ក៏កើតមានទៅលើកងកម្លាំងរបស់សម្ដេច សីហនុ ដែរ មិនមែន

---

[242] សឺន សាន ប្រធានរ.ជ.រ.ប.ខ និង ជារដ្ឋមន្ត្រីទី១ នៃរដ្ឋាភិបាលចំរុះកម្ពុជាប្រជាធិបតេយ្យ ជូនឯកឧត្តម ខៀវ សំផន អនុប្រធានកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុកកិច្ចការបរទេស, ថ្ងៃទី ១៦ ខែមិនា ១៩៨៧ ។

[243] សឺន សាន រដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ជូនឯកឧត្តម ខៀវ សំផន អនុប្រធាន ។

កើតមានតែចំពោះយុទ្ធជនរ.ជ.រ.ប.ខ.នោះឡើយ ។ ការរំលោភបំពានរបស់ខ្មែរក្រហមនេះ ក៏បានក្លាយជាមូលហេតុគ្រប់គ្រាន់សម្រាប់សម្តេច សីហនុ យកមកអាង ដើម្បីដកថយចេញពីខ្មែរក្រហម និង រកវិធីជួបចរចាផ្ទាល់ជាមួយភាគីក្រុងភ្នំពេញ ។ នៅថ្ងៃទី ៧ ឧសភា ១៩៨៧ ពីទីក្រុងព្យុងយ៉ាង សម្តេច សីហនុ ចេញសេចក្តីប្រកាស តាមបណ្តាញទីភ្នាក់ងារព័ត៌មានអន្តរជាតិថា ព្រះអង្គបានសំរេចព្រះទ័យ ព្យួរភារកិច្ចរបស់ព្រះអង្គជាប្រធានកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី ៧ ឧសភា ១៩៨៧ រហូតដល់ថ្ងៃទី ៧ ឧសភា ១៩៨៨ ដោយសំអាងថាពួកខ្មែរក្រហមបានវាយប្រហារទៅលើកងទ័ពរបស់ព្រះអង្គ[244] ។ បន្ទាប់មកទៀត សម្តេចបានគំរាមថានឹងបន្តផ្អាកការងារជាប្រធាននេះតទៅទៀត ក្នុងរយៈពេល ១២ ខែម្តងរហូតដល់ពួកខ្មែរក្រហមផ្លាស់ប្តូរនយោបាយរបស់ខ្លួន ឈប់វាយប្រហារមកលើកម្លាំងគាំទ្រព្រះអង្គ និង បញ្ឈប់រាល់អំពើរំលោភសិទ្ធិមនុស្សទាំងអស់នៅក្នុងជំរុំជនភៀសខ្លួនដែលពួកនេះត្រួតត្រា ។

ក្រុមរ.ជ.រ.ប.ខ.យើងនៅឯទីក្រុងបាងកក ដែលបានទទួលដំណឹងស្តីពីការសម្រេចព្រះទ័យរបស់សម្តេច សីហនុ តែតាមបណ្តាញសារព័ត៌មានអន្តរជាតិនោះមានការភ្ញាក់ផ្អើល និង មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះស្ថិរភាពនៃរដ្ឋាភិបាលចម្រុះ ។ នៅក្នុងសារផ្ញើថ្វាយព្រះអង្គ លោកតា សឺន សាន ទូលសម្តេច សីហនុ ថាលោកតានៅសង្ឃឹមថា ព័ត៌មាននោះមិនពិត និង បញ្ជាក់ជាថ្មីថា រ.ជ.រ.ប.ខ. នៅតែគាំទ្រព្រះអង្គយ៉ាងពេញទំហឹង ក្នុងព្រះឋានៈជាប្រធានកម្ពុជាប្រជាធិបតេយ្យដែលជាតួនាទីមានលក្ខណៈស្លាប់រស់សម្រាប់បុព្វហេតុនៃការតស៊ូរំដោះជាតិ[245]។

ជាមួយនោះ មេដឹកនាំ រ.ជ.រ.ប.ខ. ក្នុងឋានៈជារដ្ឋមន្ត្រីទី១ នៃរដ្ឋាភិបាល

---

កម្ពុជាប្រជាធិបតេយ្យ ទទួលបន្ទុកកិច្ចការបរទេស, ថ្ងៃទី ៧ ឧសភា ១៩៨៧ ។

[244] បានន័យថា ក្នុងរយៈពេល១២ខែនេះ ព្រះអង្គឈប់ប្រតិបត្តតួនាទីផ្លូវការជាប្រធានកម្ពុជាប្រជាធិបតេយ្យ ។

[245] Son Sann, A Son Altesse Royale Samdech Preah Norodom Sihanouk, Président du Kampuchea Démocratique, Pyong Yang, le 14 Mai 1987.

ចម្រុះ ក៏បានផ្ញើលិខិតមួយច្បាប់ទៀតទៅលោក ខៀវ សំផន ដើម្បីឲ្យខ្មែរក្រហមបញ្ចប់វិបត្តិនេះឲ្យបានឆាប់រហ័ស និង ឲ្យអង្វរករសម្តេច សីហនុ សុំកុំឲ្យព្រះអង្គសំរេចព្រះទ័យបែបនេះ ដែលអាចមានផលវិបាកដល់រដ្ឋាភិបាលចម្រុះ ជាពិសេសចំពោះសហប្រតិបត្តិការរវាងកងទ័ពទាំងបីនៃចលនាតស៊ូ ។ ជាមួយនោះ លោកតាសឺន សាន ក៏បានរំលឹកឡើងវិញថា ការប៉ះទង្គិចខាងផ្លូវអាវុធកើតមាន ទាំងចំពោះកងទ័ពសីហនុនិយម ទាំងចំពោះកងទ័ព រ.ជ.រ.ប.ខ. ជាពិសេស លោកតារំលឹកអំពីឃាតកម្មដែលរ.ជ.រ.ប.ខ.បានធ្វើការតវ៉ាទៅលោក ខៀវ សំផន តាមលិខិត ចុះថ្ងៃទី ១៩ មីនា ១៩៨៧ ដែលលោក ខៀវ សំផន បានសន្យាថានឹងធ្វើការស៊ើបអង្កេតតាមសំបុត្រចុះថ្ងៃទី ២១ មីនា ១៩៨៧ ក៏ប៉ុន្តែ រួចមកក៏នៅស្ងាត់ឈឹងរហូត[246] ។

## ខ្មែរក្រហមភ័យខ្លាចបាត់អាសនៈ

គួររំលឹកថា នៅឯទីក្រុងវ៉ាស៊ិនតោនឯនោះ ចលនាទាមទារឲ្យមានការកាត់ទោសពួក ប៉ុល ពត អំពីបទប្រល័យពូជសាសន៍ ក៏កាន់តែទទួលបាននូវការគាំទ្រពីមជ្ឈដ្ឋានអ្នកនយោបាយអាមេរិក ជាពិសេសក្នុងចំណោមសមាជិកសភាដែលកាន់តែធ្វើឲ្យក្រុមប្រទេសអាស៊ានព្រួយបារម្ភថែមទៀត ។ ពួកខ្មែរក្រហម មានការខ្វាយខ្វល់ជាខ្លាំងចំពោះឥរិយាបថរបស់សម្តេច សីហនុ នេះ ។ ពួកគេក៏សុំចូលគាល់ព្រះអង្គនៅទីកន្លែង និង ពេលវេលាណាក៏ដោយឲ្យតែព្រះអង្គអនុគ្រោះ ។ តាមសារព័ត៌មានចេញផ្សាយនៅទីក្រុងបាងកក លោក ខៀវ សំផន និង សុន សេន បានផ្ញើសារថ្វាយសម្តេច សុំឲ្យព្រះអង្គពិចារណាឡើងវិញ អំពីការសំរេចផ្អាកការងាររបស់ព្រះអង្គជាប្រធានកម្ពុជាប្រជាធិបតេយ្យនេះ ព្រោះថាខ្មែរក្រហមភ័យខ្លាចបាត់បង់អា

[246] សឺន សាន រដ្ឋមន្ត្រីទី១ ជូនចំពោះឯកឧត្តម ខៀវ សំផន, អនុប្រធានកម្ពុជាប្រជាធិបតេយ្យ ទទួលបន្ទុកកិច្ចការបរទេស, ថ្ងៃទី ១៤ ឧសភា ១៩៨៧ ។

សនៈរបស់រដ្ឋាភិបាលចម្រុះនៅអង្គការសហប្រជាជាតិ ។ ពួកគេសន្យាថាសុខចិត្ត ធ្វើការទូទាត់ជាថវិកាសងជម្ងឺចិត្តដល់គ្រួសារយុទ្ធជនរបស់សម្តេច ដែលបានបាត់បង់ជីវិត[247] ។ ជាមួយនោះ លោក ខៀវ សំផន ក៏ព្រលយពាក្យឲ្យដឹងថា គាត់មិនជឿថាសម្តេច សីហនុ សម្រេចដកថយនេះ ដោយសារសកម្មភាពអមិត្តរបស់ខ្មែរក្រហមនោះទេ ។ គំនឹតបែបនេះ ក៏ស្របតាមការវិភាគរបស់អ្នកសង្កេតការណ៍មួយចំនួន ដែលបកស្រាយថា ការសម្រេចព្រះទ័យរបស់សម្តេចគឺ ជាកលល្បិច ឬ យុទ្ធវិធីនយោបាយ ដើម្បីបង្ហាញនូវភាពទន់ភ្លន់ និង សេរីភាពរបស់ព្រះអង្គក្នុងការស្វែងរកលទ្ធភាពជួបចរចាផ្ទាល់ជាមួយក្រុងហាណូយ ឬ ក្រុងភ្នំពេញ[248]។ អ្នកការទូតមួយចំនួននៅទីក្រុងបាងកក បានបង្ហើបឲ្យកាសែតបាងកកប៉ុស្តចេញផ្សាយថ្ងៃទី ៥ មិថុនា ១៩៨៧ ថាកាលពីពីរសប្តាហ៍មុនវៀតណាមសុខចិត្តទទួលជួបចរចាជាមួយសម្តេច សីហនុ នាពេលមួយ នៅពេលព្រះអង្គយាងទៅដល់ប្រទេសបារាំង[249] ។ ក៏ប៉ុន្តែ នៅក្នុងទូរលេខផ្ញើទៅព្រះរាជបុត្រព្រះអង្គគឺ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ នៅទីក្រុងបាងកក សម្តេច សីហនុ ចោទថាមានតែក្រុមអ្នកបន្ទាបបន្ថោកព្រះអង្គទេ (détracteurs) ដែលអាចប្រឌិតរឿងថា ព្រះអង្គរិះគន់ខ្មែរក្រហមគ្រាន់តែជាលេសដើម្បីទៅចរចាផ្ទាល់ជាមួយវៀតណាម និង ជាមួយរដ្ឋាភិបាល ហេង សំរិន-ហ៊ុន សែន ។ សម្តេចបញ្ជាក់ទៀតថា ព្រះអង្គគ្មានទំនាក់ទំនងអ្វីទាំងអស់ជាមួយក្រុងហាណូយ ក្រុងភ្នំពេញ ឬ ក្រុងមូស្គូ ហើយព្រះអង្គក៏គ្មានបំណងបង្កើតទំនាក់ទំនងជាមួយក្រុងទាំងនោះទេ ។ ក៏ប៉ុន្តែ ព្រះអង្គមិនទាត់ចោលទាំងស្រុងនូវជំនួបណាមួយនាពេលខាងមុខឡើយ ដោយសម្តេច សីហនុ ថ្លែងថា "ប្រសិនបើនៅថ្ងៃណាមួយនាពេលខាងមុខខាងភាគីម្ខាងទៀត សុំមកគាល់ខ្ញុំៗនឹងមិនភ្លេចជំរាបសាជា

[247] The Nation, Khmer Rouge Appeal to Sihanouk, June 1, 1987, p. 5.

[248] Nayan Chanda, The Prince Makes Waves, Far Eastern Economic Review, Vol. 136, No 25, June 18, 1987, p. 48.

[249] Bangkok Post, Sihanouk denies he'll talk with Phnom Penh, June 5, 1987.

រណោជនឲ្យបានជ្រាបឡើយ" ។ ចំពោះការសុំចូលគាល់ពីសំណាក់លោក ខៀវ សំផន នោះ ព្រះអង្គបដិសេធមិនឲ្យចូលគាល់ព្រះអង្គទេ ដោយសំអាងថាព្រះអង្គកំពុងមានវិបត្តិខាងសតិអារម្មណ៍(វិបត្តិខាងផ្លូវចិត្ត) ដែលកាន់តែធ្ងន់ធ្ងរឡើងពី ១ ថ្ងៃ ទៅ ១ ថ្ងៃ ។

ជាការពិតណាស់ សម្តេច សីហនុ ប្រាកដជាមិនអាចធ្វើទំនាក់ទំនងផ្ទាល់ណាមួយជាមួយរដ្ឋាភិបាលក្រុងភ្នំពេញបានឡើយ ប្រសិនបើព្រះអង្គនៅតែបំពេញភារកិច្ចផ្លូវការជាប្រធានកម្ពុជាប្រជាធិបតេយ្យ ព្រោះថាទាំងចិនទាំងខ្មែរក្រហម និង ប្រទេសខ្លះនៃក្រុមអាស៊ានផង សុទ្ធតែប្រកាន់គោលជំហរឲ្យមានការជួបចរចាជាមួយវៀតណាមស្តីពីការដកកងទ័ពវៀតណាមជាមុនសិន មុននឹងនិយាយជាមួយអ្នកដឹកនាំក្រុងភ្នំពេញ ។ ចំពោះសម្តេច សីហនុ ការដកថយពីកម្ពុជាប្រជាធិបតេយ្យ និង ក្នុងព្រះឋានៈជាអតីតព្រះមហាក្សត្រ បានផ្តល់សេរីភាពដើម្បីឈានទៅបំរើនយោបាយផ្ទាល់របស់ព្រះអង្គ ។

## លោកតា សឺន សាន ទៅស្នាបស្ទង់នៅរូម៉ានី

នៅពេលជាមួយនោះ លោកតា សឺន សាន ក៏បានដឹកនាំគណៈប្រតិភូ រ.ជ.រ.ប.ខ. មួយទៅធ្វើទស្សនកិច្ចនៅប្រទេសរូម៉ានី ពីថ្ងៃទី ១៧ ទៅ ១៩ មិថុនា ១៩៨៧ ទោះបីជាសម្តេច សីហនុ បានទូន្មានរួចហើយថា មិនចាំបាច់ទៅជួបលោកប្រធានាធិបតី សេអូសេស្កូ នោះទេ ដូចខ្ញុំបានរៀបរាប់ពីខាងលើរួចហើយ ។ ក៏ប៉ុន្តែអ្នកដឹកនាំរ.ជ.រ.ប.ខ.សំអាងថា ទស្សនកិច្ចនោះមានគោលដៅទៅថ្លែងអំណរគុណដោយផ្ទាល់មាត់ចំពោះលោកប្រធានាធិបតី សេអូសេស្កូ ដែលបានខំប្រឹងប្រែងរកដំណោះស្រាយបញ្ហាកម្ពុជា និង ជាមួយនោះ ក៏សុំឲ្យប្រទេសរូម៉ានីជួយរកមធ្យោ

បាយគ្រប់យ៉ាង ដើម្បីបញ្ចប់ទុក្ខវេទនារបស់ប្រជារាស្ត្រខ្មែរ[250] ។ បេសកកម្មរបស់គណប្រតិភូយើងនាពេលនោះគ្រាន់បានតែត្រឹមផ្លាស់ប្តូរមតិគ្នាតែប៉ុណ្ណោះ ព្រោះថាលោកតា សឺន សាន ដើរតួនាទីជារដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលចម្រុះត្រីភាគី ដែលមានគោលជំហរនយោបាយទាមទារឲ្យមានការចរចាជាមួយវៀតណាម ស្តីពីការដកកងទ័ពពីកម្ពុជាជាមុនៗនឹងចរចាជាមួយរដ្ឋាភិបាលក្រុងភ្នំពេញ នៅពេលដែលមេដឹកនាំរូម៉ានីណែនាំឲ្យមានការផ្សះផ្សាជានាគ្នាជាមួយក្រុងភ្នំពេញសិននោះ ។ បេសកកម្មនៅប្រទេសរូម៉ានីនោះ ក៏ជាឱកាសមួយសម្រាប់រូបខ្ញុំបានចូលរួមជាសមាជិកប្រតិភូ ។ ប្រទេសរូម៉ានីជាប្រទេសកុម្មុយនីស្តដំបូងគេដែលខ្ញុំបានទៅដល់ ។ ក្រៅពីការងារនយោបាយដូចខ្ញុំបានលើកឡើងខាងលើ ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះកិច្ចការពិធីការ ។ មន្ត្រីពិធីការរូម៉ានីប្រកាន់ភាពហ្មត់ចត់ណាស់ទាំងពេលវេលាទាំងទីកន្លែង ត្រង់ណាត្រូវឈរត្រង់ណាត្រូវអង្គុយ ខាងមុខខាងក្រោយ ពេលលើកម្ហូបអាហារតើពេលណាដែលគេត្រូវដាក់ជូនភ្ញៀវឲ្យបានព្រមៗគ្នាជាដើម ឧទាហរណ៍ នៅពេលនាយករដ្ឋមន្ត្រីគេមកដល់ តើប្រធានគណៈប្រតិភូយើងត្រូវដើរទៅមុខប៉ុន្មានជំហាន នាយករដ្ឋមន្ត្រីគេឈានមកប៉ុន្មានជំហាន មុននឹងចាប់ដៃគ្នា។

នៅក្នុងគណៈប្រតិភូ រូបខ្ញុំត្រូវបានផ្តល់ឋានៈស្មើរដ្ឋមន្ត្រី ។ មនុស្សជំនិតរបស់លោកតា សឺន សាន ម្នាក់ដែលមានអាយុច្រើនជាងខ្ញុំ បានប្រាប់មន្ត្រីពិធីការរូម៉ានីថាគាត់ មានឋានៈស្មើទេសរដ្ឋមន្ត្រី ។ តាមប្រព័ន្ធបារាំង ទេសរដ្ឋមន្ត្រី (Ministre d'Etat) មានឋានៈខ្ពស់ជាងរដ្ឋមន្ត្រី ។ ពាក្យនេះគេបកប្រែជាភាសាអង់គ្លេសថា Senior Minister ។ ក៏ប៉ុន្តែបើគេបកប្រែពីភាសាបារាំង Ministre d'Etat ជាភាសាអង់គ្លេស តាមពាក្យមួយម៉ាត់ៗគេអាចបកថា Ministre ជា Minister រីឯ Etat ជា State ដូច្នេះ Ministre d'Etat បកប្រែជា State Minister

[250] Coalition Government of Democratic Kampuchea, Office of the Prime Minister, Communiqué de Presse, Bucarest le 17 Juin 1987.

ដែលតាមប្រព័ន្ធសហព័ន្ធ (Federal) មានឋានៈទាបជាងរដ្ឋមន្ត្រីទៅវិញ ។ មន្ត្រីពិធីការរូម៉ានី ប្រហែលជាគិតថាមនុស្សជំនិតរបស់លោកតា សឺន សាន នោះមានឋានៈត្រឹម State Minister តែប៉ុណ្ណោះ ទើបគេចាត់កន្លែងឲ្យគាត់អង្គុយបន្ទាប់ពីខ្ញុំ ធ្វើឲ្យគាត់មានការអាក់អន់ចិត្តជាខ្លាំង ។

## គំរោងជួបចរចាគ្នា តាមរូបភាពទីទៃៗ

គួររំលឹកថាតាំងពីឆ្នាំ ១៩៨៥ រៀងមក ទោះជាមានការប្រើកម្លាំងយោធាវាយប្រហារគ្នាទៅវិញទៅមកយ៉ាងខ្លាំងក្លាយ៉ាងណាក៏ដោយ ក៏គំនិតផ្តួចផ្តើមឲ្យមានការជួបចរចាគ្នារវាងគូបដិបក្ខកើតមានជាហូរហែដែរ ក្រោមរូបមន្តផ្សេងៗដូចជាចរចាជាក្រុមៗក្បែរៗគ្នា (Proximity talks) និង ជួបគ្នាក្នុងពេលជប់លៀងភេសជ្ជៈកុកតៃ (Cocktail Party) ។ នៅថ្ងៃទី ៧ ឧសភា ១៩៨៧ លោកតា សឺន សាន ក្នុងឋានៈជារដ្ឋមន្ត្រីទី១ នៃរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ បានចេញសេចក្តីប្រកាសមួយ អបអរសាទរចំពោះការផ្តួចផ្តើមគំនិតរបស់លោករដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ី ម៉ុកតា កាស៊ុម៉ាដម៉ាចា (Mochtar Kasumaadmaja) ដែលស្នើរៀបចំជប់លៀងភេសជ្ជៈកុកតៃមួយ នៅទីក្រុងហ្សាកាតា ។ តាមវិធីនេះ គូបដិបក្ខអាចជួបគ្នាបាន ព្រោះនេះគ្រាន់តែជាការជួបគ្នាក្រៅផ្លូវការតែប៉ុណ្ណោះ ។ បើមិនធ្វើតាមវិធីនេះទេ គូបដិបក្ខមិនងាយជួបនិយាយគ្នាបានឡើយ ដោយហេតុថាភាគីនីមួយៗមានគោលជំហរនយោបាយខុសគ្នាខ្លាំងពេក ។ នៅក្នុងសេចក្តីប្រកាសនោះ លោកតា សឺន សាន ថ្លែងថាយើងខ្ញុំរីករាយណាស់ ប្រសិនបើវៀតណាមទទួលយល់ព្រមចូលរួមដែរ ក្នុងន័យដែលលោកតាចង់បញ្ជាក់បន្ថែមថាជម្លោះនាពេលនោះជាជម្លោះរវាងកម្ពុជា និង វៀតណាម មិនមែនជាសង្គ្រាមស៊ីវិល

រវាងខ្មែរ និង ខ្មែរនោះទេ[251] ដែលជាគោលជំហរផ្ទុយទាំងស្រុងពីគោលជំហរវៀតណាម ។ ទោះជាគំនិតជប់លៀងកុកតែនេះ បានទទួលការគាំទ្រពីប្រទេសមួយចំនួនក៏ដោយ ក៏នៅទីបំផុតត្រូវទទួលបរាជ័យ ។ ដូច្នេះរ.ជ.រ.ប.ខ. និង លោកតាសឺន សាន គ្រាន់តែបង្ហាញរូបភាពខាងក្រៅថា មិនមែនមានតែសម្តេច សីហនុ ទេ ដែលចេះស្វែងរកដំណោះស្រាយជម្លោះតាមការចរចា លោកតាក៏ខំដែរ ។ តែលោកតាមិនហ៊ានឈានទៅរកការចរចាផ្ទាល់ជាមួយភាគីភ្នំពេញដូចសម្តេច សីហនុ នោះឡើយ ។

ដូចបានបញ្ជាក់រួចហើយក្នុងវគ្គមុនៗ ភាគីក្រុងភ្នំពេញប្រាកដជាទទួលផលប្រយោជន៍ច្រើនក្នុងការជួបចរចាផ្ទាល់ជាមួយសម្តច សីហនុ ដូច្នេះអ្នកដឹកនាំខ្មែរនៅភ្នំពេញ ជាពិសេសលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវតែបន្តបេសកកម្មនេះឲ្យបានសម្រេច ។ ផលប្រយោជន៍សំខាន់ជាងគេនោះគឺ ការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ឲ្យបានជាស្ថាពរ ។ ចំណែកសម្តេច សីហនុ ពិតជាទតឃើញឧបសគ្គធំៗក្នុងការស្វែងរកដំណោះស្រាយនយោបាយ ដើម្បីបញ្ចប់សង្គ្រាមនៅកម្ពុជា ក៏ប៉ុន្តែព្រះអង្គក៏ពិតជាបានប្តេជ្ញាថាដំណោះស្រាយបែបណាក៏ដោយ ក៏ត្រូវតែសាកល្បង ។ ម្យ៉ាងទៀតសម្តេច សីហនុ ក៏បានវាយតម្លៃច្បាស់អំពីធាតុពិតរបស់របបខ្មែរក្រហម ដែលព្រះអង្គអាចយល់ថាត្រូវតែរកវិធីគេចចេញពីពួកនេះ ។ ជាការពិតណាស់ ព្រះអង្គអាចផ្លាស់ប្តូរសម្ព័ន្ធភាពបាន ឲ្យតែអាចកសាងសន្តិភាព និងរំដោះកម្ពុជាពីខ្មែរក្រហមបាន ។ គំនិតគេចចេញពីខ្មែរក្រហមរបស់ព្រះអង្គនេះ ក៏ស៊ីសង្វាក់គ្នាជាមួយនយោបាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត របស់អ្នកដឹកនាំក្រុងភ្នំពេញ ដែលជាកត្តានាំឲ្យមានការស្វែងរកការជួបចរចាគ្នាដោយផ្ទាល់ក្នុងឋានៈជាខ្មែរដូចគ្នា ។

---

[251] Statement of H. E. Son Sann, Prime Minister of the Coalition Government of Democratic Kampuchea, May 8, 1987.

# មិត្តភាពរវាងលោក យ៉ាស្សែរ អារ៉ាហ្វាត់ និង សម្តេច សីហនុ

នៅទីក្រុងព្យុងយ៉ាង ឆ្ងាយពីភ្នែករបស់ចិន សម្តេច សីហនុ ប្រាកដជាមានភាពងាយស្រួលក្នុងការបំពេញការងារទូតមួយចំនួន ទៅតាមគោលជំហរនយោបាយផ្ទាល់របស់ព្រះអង្គ ។ ម្យ៉ាងទៀត នៅទីក្រុងព្យុងយ៉ាង សម្តេច សីហនុ ក៏មានអ្នកការទូតដែលព្រះអង្គអាចទុកព្រះទ័យ អាចធ្វើជាអ្នកនាំពាក្យ ឬ មេអណ្តើករវាងព្រះអង្គ និង ភាគីម្ខាងទៀតបានដោយប្រសិទ្ធភាព ។ អ្នកនាំពាក្យ ឬ មេអណ្តើកនោះគឺ លោកឯកអគ្គរដ្ឋទូតនៃអង្គការរំដោះប៉ាឡេស្ទីន ប្រចាំប្រទេសកូរ៉េខាងជើង ឈ្មោះ សាហ្វារីនី (Sapharini)[252] ។ ដោយសារនយោបាយគាំទ្រការតស៊ូប្រយុទ្ធរបស់ប្រជាជនប៉ាឡេស្ទីន តាំងពីសម័យដែលព្រះអង្គកាន់អំណាចជំនាន់សង្គមរាស្ត្រនិយមរៀងមក សម្តេច សីហនុ បានក្លាយជាមហាមិត្តម្នាក់របស់សពលោកប្រធាន យ៉ាស្សែរ អារ៉ាហ្វាត់ (Yasser Arafat) នៃអង្គការរំដោះប៉ាឡេស្ទីន ។ រូបខ្ញុំ (អៀង មូលី) ដែលមានកព្វសំណាងបានចូលរួមក្នុងគណៈប្រតិភូជាន់ខ្ពស់របស់កម្ពុជា នៅសន្និសីទកំពូលនៃចលនាប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូណេស៊ី នៅឆ្នាំ ១៩៩២ ដឹកនាំដោយសម្តេច សីហនុ ព្រះប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ អេស អិន ស៊ី បានឃើញផ្ទាល់ភ្នែកនូវមិត្តភាពដ៏ធំធេងរវាងរដ្ឋបុរសទាំងពីរ ។ នាពេលឈប់សម្រាកមួយ ចន្លោះអង្គប្រជុំនៃសន្និសីទ ក្នុងសាលដ៏ធំ ខ្ញុំឃើញលោកប្រធាន យ៉ាស្សែរ អារ៉ាហ្វាត់ ក្នុងឯកសណ្ឋានប៉ារ៉ា កាំភ្លើងខ្លីនៅនិងចង្កេះ ពាក់មួកជាមួយក្រមារដែលជានិមិត្តសញ្ញាអារ៉ាប់របស់គាត់ ដើរកាត់ហ្វូងប្រមុខរដ្ឋ និង ប្រមុខរដ្ឋាភិបាល តម្រង់មកអាសនៈកម្ពុជា ដើម្បីមកឱបរឹតថើប

[252] ហ៊ុន សែន, ១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩, ទំព័រ ១៦៨, គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ, រោងពុម្ព ណុប បូផាន់ ភ្នំពេញ ១៩៨៨ ។

សម្តេច សីហនុ យ៉ាងស្និទ្ធស្នាលបំផុត ។ យ៉ាងនេះហើយ ទើបនៅទីក្រុងព្យុងយ៉ាង មានលេចឮដំណឹងថាសម្តេច សីហនុ បានត្រៀមជួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅខែ មិថុនា ១៩៨៧ ក៏ប៉ុន្តែ បន្ទាប់ពីមានជំនួបរវាងលោកនាយករដ្ឋមន្ត្រីស្តីទីនៃប្រទេសចិន ជាមួយអ្នកម្នាង ម៉ូនិច គំរោងនោះត្រូវបានបោះបង់ចោលទៅវិញ ។

## ខ្មែរក្រហមរិះគន់សម្តេចថាធ្លាក់ក្នុងអន្ទាក់របស់វៀតណាម

កាលសម័យនោះ ពួកយើងនៅឯទីក្រុងបាងកក ពុំបានដឹងពីគំរោងជួបចរចាគ្នានោះទេ ។ ពួកយើងទទួលបានព័ត៌មាននេះ នៅពេលក្រោយៗទៀតតែប៉ុណ្ណោះ តាមរយៈបណ្តាញទីភ្នាក់ងារអន្តរជាតិ ។ ម្យ៉ាងទៀត ពួកយើងក៏ពុំមានឯកសារផ្លូវការពាក់ព័ន្ធនិងគំរោងជំនួបនេះដែរទេ ។ គួរបញ្ជាក់ថា នៅឯទីក្រុងប៉េកាំងឯនោះវិញ ទូតរបស់ខ្មែរក្រហមបានធ្វើសកម្មភាពលាងខួរក្បាល កែខួរ តាមស្ថានទូតនា ដើម្បីឲ្យមជ្ឈដ្ឋានទូតយល់ថាការសម្រេចព្រះទ័យរបស់សម្តេច សីហនុ ផ្អាកការងារជាប្រធានកម្ពុជាប្រជាធិបតេយ្យនោះ មិនមែនដោយសារអំពើខុសឆ្គងរបស់ពួកខ្មែរក្រហមនោះទេ តែគឺជាការគិតគូររកវិធីថ្មីផ្ទាល់របស់ព្រះអង្គឯណោះទេដែលខ្មែរក្រហមចោទថាព្រះអង្គកំពុងធ្លាក់ក្នុងអន្ទាក់របស់វៀតណាម (Accuser d'être tombé dans le piège des Vietnamiens) ។ សកម្មភាពការទូតរបស់ខ្មែរក្រហមនេះ បានធ្វើឲ្យអ្នកម្នាង ម៉ូនិច ព្រះជាយាសម្តេច សីហនុ មានការមិនពេញចិត្តជាខ្លាំង ព្រមទាំងបានព្រមានថា នឹងកាត់បន្ថយទំនាក់ទំនងជាមួយពួកនេះ មិនឲ្យដូចពីមុនទៀតទេនាពេលអនាគត[253] ។

ចំពោះសម្តេច សីហនុ វិញព្រះអង្គនៅតែបន្តបង្ហាញឲ្យឃើញរូបភាពថាព្រះ

---

[253] Monique Sihanouk, Chang Sou On, 22 Juillet 1987.

អង្គគង់នៅឆ្ងាយគឺ មិនសកម្មខ្លាំងក្លាទៀតទេ ជាមួយពួកខ្មែរក្រហម ក៏ប៉ុន្តែព្រះអង្គក៏គិតគូរ មិនធ្វើអ្វីឲ្យចិនអាក់អន់ចិត្តពេកដែរ ។ ពីទីក្រុងព្យុងយ៉ាង ព្រះអង្គណែនាំឲ្យលោក ចាន់ យូរ៉ាន់ ឯកអគ្គរដ្ឋទូតខ្មែរក្រហម ប្រចាំទីក្រុងប៉េកាំងអនុវត្តតាម នៅពេលព្រះអង្គយាងត្រឡប់ទៅប្រទេសចិនវិញនៅខែ សីហា ខាងមុខ ដើម្បីដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ធ្វើទស្សនកិច្ចផ្លូវការនៅប្រទេសចិនដូចតទៅ៖ -មិនផ្តល់កិច្ចសម្ភាសន៍ដល់អ្នកកាសែត វិទ្យុ ឬ ទូរទស្សន៍ណាមួយឡើយ -សុំការអនុញ្ញាតពីថ្នាក់ដឹកនាំចិន ដើម្បីកុំឲ្យព្រះអង្គផ្តល់កិច្ចសម្ភាសន៍ដល់អ្នកកាសែត វិទ្យុ ឬ ទូរទស្សន៍រាប់ទាំងកាសែត វិទ្យុ និង ទូរទស្សន៍ចិន ក្នុងនោះមានទីភ្នាក់ងារសីនហួរផង -សម្តេចមិនធ្វើជាអធិបតីនៃអង្គប្រជុំគណៈរដ្ឋមន្ត្រីត្រីភាគីឡើយ -នៅក្នុងឱកាសនៃការគង់ប្រថាប់នៅទីក្រុងប៉េកាំង សម្តេចអាចប្រទានសវនាការជាលក្ខណៈឯកជន និង ដោយគ្មានវត្តមានអ្នកកាសែត វិទ្យុ ឬទូរទស្សន៍ណាទាំងអស់ ចំពោះ ឯ. ឧ. ខៀវ សំផន និង សវនាការមួយទៀតជូន ចំពោះ ឯ. ឧ. សឺន សាន ប្រសិនបើអស់លោកណាមួយចង់សន្ទនានយោបាយជាមួយព្រះអង្គ -នៅទីបញ្ចប់នៃទស្សនកិច្ចរបស់គណៈប្រតិភូ សម្តេចមិនចូលរួមក្នុងសន្និសីទសារព័ត៌មានទេ តែព្រះអង្គអាចអានអត្ថបទនៃសេចក្តីថ្លែងការណ៍រួមរបស់សមាសភាពត្រីភាគី អត្ថបទដែលលោក ខៀវ សំផន និង ភាគីខ្មែរក្រហមជាអ្នកតាក់តែងជាភាសាខ្មែរ និង ដោយទទួលបានការឯកភាពពីលោកតា សឺន សាន[254]។

[254] Norodom Sihanouk, Note pour S.E. Chan Youran, Ambassadeur du Kampuchea Démocratique en R. P. de Chine, Pyongyang, le 11 Juillet 1987.

# ចិនថា មិនទាន់ដល់ពេលចរចាទេ

នៅថ្ងៃទី ១៤ កក្កដា ១៩៨៧ សម្តេច សីហនុ ជួបជាមួយអ្នកការទូតអូទ្រីស ដែលបានមកគាល់ព្រះអង្គនៅទីក្រុងព្យុងយ៉ាង ដើម្បីទូលថារដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានសុំឲ្យរដ្ឋាភិបាលអូទ្រីសជួយធ្វើអន្តរាគមន៍ចំពោះព្រះអង្គ ក្នុងបំណងឲ្យមានការជួបគ្នានៃភាគីខ្មែរទាំង ៤ គឺ៖ ហ៊្វុន ស៊ិនប៉ិច រ.ជ.រ.ប.ខ កម្ពុជាប្រជាធិបតេយ្យ ឬ ខ្មែរក្រហម និង សាធារណរដ្ឋប្រជាមានិតកម្ពុជា នៅទីក្រុងវីយែននៃប្រទេសអូទ្រីស តាមរូបមន្តជប់លៀងភេសជ្ជៈកុកតៃ ។ ចំពោះសំណើនេះ សម្តេច សីហនុ ឆ្លើយថាការជួបប្រជុំបែបនេះ មិនអាចធ្វើបានទេ ព្រោះពួកខ្មែរក្រហមប្រាកដជានឹងជំទាស់មិនខានឡើយ ។ ដូច្នេះ អ្នកចូលរួមប្រជុំនឹងមានតែពីរភាគីទេគឺ៖ ហ៊្វុនស៊ិនប៉ិច និង សាធារណរដ្ឋប្រជាមានិតកម្ពុជា ដោយសម្តេចចាត់ទុកថា រ.ជ.ប.ខ និង ខ្មែរក្រហមនឹងប្រកាន់យកគោលនយោបាយតែមួយគឺគ្មានការចរចាផ្ទាល់ជាមួយភាគីភ្នំពេញ បើគ្មានការចរចាជាមួយវៀតណាមជាមុនទេនោះ ។ តាមពិតទៅសម្តេច សីហនុ ជ្រាបច្បាស់ណាស់ថាលោកតា សឺន សាន មិនហ៊ានធ្វើអ្វីឲ្យចិនខឹងសម្បារនោះឡើយ ។ ក្នុងករណីដែលមានភាគីចូលរួមតែពីរបែបនេះ សម្តេច សីហនុ ណែនាំអ្នកការទូតអូទ្រីសនោះឲ្យរៀបចំជាសិក្ខាសាលាអន្តរជាតិវិញ តែព្រះអង្គបញ្ជាក់ថាបើសិក្ខាសាលានេះមិនបានរៀបចំឡើងដោយរដ្ឋាភិបាលអូទ្រីសទេ ព្រះអង្គក៏មិនចូលរួមដែរ ។ សម្តេចបានបញ្ជាក់ថារូបមន្តសិក្ខាសាលាមានភាពទន់ភ្លន់ ជាងរូបមន្តជប់លៀងភេសជ្ជៈកុកតៃ ព្រោះថាបើមានភាគីណាមិនចូលរួម ក៏មិនបង្កើតឧបសគ្គធ្វើឲ្យរាំងស្ទះដល់ការរួមប្រជុំសិក្ខាសាលាដែរ ។ ម្យ៉ាងទៀត ប្រសិនបើនៅក្នុងសិក្ខាសាលាមានតំណាងប្រទេសជាច្រើនចូលរួមដូចជាប្រទេសបារាំង រូម៉ានី ស៊ុយអែដ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី

អូទ្រីសជាដើម អ្វីដែលសិក្ខាសាលាស្នើសុំដល់ភាគីពាក់ព័ន្ធក្នុងជំលោះ អាចជាការគាបសង្កត់ខាងផ្លូវចិត្ត (ឬ ផ្នែកសីលធម៌) (pression morale) មួយដ៏ធំទៅលើភាគីពាក់ព័ន្ធទាំងនោះ ឲ្យបន្ទោបន្ទន់ឥរិយាបថរបស់ខ្លួនឈានទៅរកការសំរុះសំរួលគ្នា[255] ដែលគេកំពុងត្រូវការជាចាំបាច់បំផុតនាពេលនោះ ។

បើមើលតាមសកម្មភាពការទូតនៅត្រីមាសទី ៣ នៃឆ្នាំ ១៩៨៧ នោះគំនឹតផ្តួចផ្តើមឲ្យមានការជួបចរចាគ្នា ហាក់ដូចជាឈានទៅមុខជានិច្ច ។ ក៏ប៉ុន្តែប្រទេសមហាអំណាចដែលមានតួនាទីសំខាន់ ក្នុងបញ្ហាកម្ពុជាយល់ឃើញថាពេលវេលានៅមិនទាន់មកដល់នៅឡើយទេ ។ នៅខែ សីហា ១៩៨៧ លោករដ្ឋមន្ត្រីការបរទេសថៃ សិទ្ធី សាវេ៉តសីលា បានថ្លែងជាសាធារណៈថាលោកបានជួបមេដឹកនាំចិននៅឯប្រទេសចិន ហើយថានៅក្នុងជំនួបជាមួយលោក តេង ស៊ាវពីង នោះ មេដឹកនាំចិនរូបនេះបានណែនាំប្រទេសអាស៊ានថា វៀតណាមមិនទាន់កែប្រែគោលជំហរនៅឡើយទេ ដូច្នេះសកម្មភាពអ្វីដែលប្រញាប់ប្រញាល់ពេក អាចនាំឲ្យបញ្ហាកាន់តែស្មុគ្រស្មាញសាំញ៉ាំថែមទៀត[256] ។ តាមបណ្តាញព័ត៌មានអន្តរជាតិ លោក សិទ្ធី សាវេ៉តសីលា ចោទប្រកាន់វៀតណាមថា ជាអ្នកបំផ្លាញរូបមន្តជប់លៀងកុកតែរបស់អាស៊ានដែលគេថាបានព្រមព្រៀងគ្នាជាគោលការណ៍រួចហើយ ។ ក៏ប៉ុន្តែវៀតណាមបានបរិហារថាសំណើរបស់អាស៊ាននាពេលនោះ មានគោលដៅបង្ហាញរូបភាពឲ្យឃើញថាក្រុងហាណូយជាអ្នកឈ្លានពានកម្ពុជា[257] ។ ទាំងនេះហើយដែលធ្វើឲ្យកិច្ចការទូតនៅពេលនោះ មិនបានសម្រេចជោគជ័យ ។

ជាមួយគ្នានោះលោក សិទ្ធី សាវេ៉តសីលា បានថ្លែងថានៅក្នុងជំនួបជាមួយសម្តេច សីហនុ នៅទីក្រុងព្យុងយ៉ាង លោកបានទទួលដំណឹងដ៏រីករាយថា សម្តេច

---

[255] Norodom Sihanouk, Compte-rendu succinct de mon entretien politique avec Monsieur Wolfgang A. Entmayr, de la Représentation de l'Autriche en la R.P.D. de Coré, Palais Chhang Sou On, Mardi 14 Juillet 1987.
[256] Bangkok Post, Asean Told Not to Rush Peace Bid, August 26, 1987.
[257] The Nation, Phnom Penh Echoes Hanoi, Quoted Kuala Lumpur Times, August 26, 1987

នឹងយាងទៅទីក្រុងញូវយ៉កនៅខែ កញ្ញា ទោះជាព្រះអង្គមិនដឹកនាំគណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យនៅឯអង្គការសហប្រជាជាតិក៏ដោយ ព្រោះថាកិត្តិនាមរបស់ព្រះអង្គមានតម្លៃណាស់សម្រាប់បុព្វហេតុនៃរដ្ឋាភិបាលចម្រុះត្រីភាគី ។ នៅពេលព្រះអង្គយាងទៅដល់ក្រុងប៉េកាំងនៅចុងខែ សីហា សម្តេច សីហនុ មានបន្ទូលថាព្រះអង្គអាចឆ្លើយ "ទេ" បានចំពោះអ្វីៗដែលលោកខៀវ សំផន និង លោកតាសឺន សាន ស្នើឡើង តែព្រះអង្គមិនអាចប្រកែកបានទេ ចំពោះប្រទេសចិនដែលជាមហាមិត្តរបស់ព្រះអង្គ[258]។ តាមពិតទៅ ប្រទេសគាំទ្ររដ្ឋាភិបាលចម្រុះត្រីភាគី ជាពិសេស ក្រុមប្រទេសអាស៊ាន ដែលមានប្រទេសថៃជាអ្នកនាំមុខ ព្រមទាំងប្រទេសចិនផង មានការព្រួយបារម្ភចំពោះការគាំទ្រអាសនៈកម្ពុជាប្រជាធិបតេយ្យ ដែលអាចធ្លាក់ចុះ បើគ្មានវត្តមានរបស់សម្តេច សីហនុ ទេនោះ ។ ដូច្នេះដំណឹងដែលថាសម្តេច យាងទៅទីក្រុងញូវយ៉កពិតជាដំណឹងល្អ ចំពោះលោក សិទ្ធី សាវេតសីលា និង មិត្តភក្តិមែន ។

នៅខែ កញ្ញា ១៩៨៧ សម្តេចយាងទៅទីក្រុងញូវយ៉កដូចបានគ្រោងទុក តែព្រះអង្គមិនដឹកនាំគណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យ ចូលរួមមហាសន្និបាតនៃអង្គការសហប្រជាជាតិដូចឆ្នាំមុនៗទេ ។ នៅឆ្នាំ ១៩៨៧ នោះ រដ្ឋាភិបាលចម្រុះត្រីភាគី រៀបចំសុន្ទរកថារបស់សម្តេច ក្នុងឋានៈព្រះអង្គជាប្រធានកម្ពុជាប្រជាធិបតេយ្យ ដោយមានលោករដ្ឋមន្ត្រីទី១ សឺន សាន ជាអ្នកអានជំនួស នៅក្នុងអង្គប្រជុំនៃអង្គការសហប្រជាជាតិ ។ ជាមួយនិងដំណើរយាងទៅទីក្រុងញូវយ៉កក៏មានការផ្សព្វផ្សាយនៅទីក្រុងបាងកកថា សម្តេចនឹងមិនជួបចរចាជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ទេ ។ ក៏ប៉ុន្តែ បើគេពិនិត្យអត្ថបទកាសែតដែលផ្សាយដំណឹងនោះឲ្យច្បាស់ ក្រៅពីចំណងជើងធំៗនៅទំព័រទីមួយ គេអាចយល់បានថាសម្តេច សីហនុ

[258] The Nation, Sihanouk Arrives for China, August 30, 1987.

មិនបដិសេធទាំងស្រុងទេនូវលទ្ធភាពនៃការជួបគ្នា ព្រោះព្រះអង្គថ្លែងថាព្រះអង្គមិនជួបទេ លើកលែងតែក្នុងករណីមានការស្នើសុំពីមេដឹកនាំខ្មែរនៅក្រុងភ្នំពេញ[259] ។

# បង្ហាញរូបភាពថាសាមគ្គី នៅពេលដែលបែកបាក់

គួបផ្សំជាមួយយុទ្ធនាការផ្នែកការទូតនៅអង្គការសហប្រជាជាតិ តំណាងកងទ័ពត្រីភាគីបានបង្កើនកិច្ចប្រតិបត្តិការទំនាក់ទំនងសាធារណៈ ដោយរៀបចំអង្គប្រជុំមួយនៅទីក្រុងបាងកក ដើម្បីគាំទ្រជំហររបស់រដ្ឋាភិបាលចម្រុះក្រោមការដឹកនាំរបស់សម្តេច សីហនុ ។ អង្គប្រជុំត្រីភាគីនោះ មានគោលដៅបង្ហាញរូបភាពថា កងទ័ពនៃចលនាទាំងបីនៅតែបន្តរួបរួម និង សហការគ្នាល្អតទៅទៀត[260]។ ចូលរួមជាតំណាងខ្មែរក្រហមមានលោក សុន សេន ឯលោក ទួន ចាយ ជាតំណាងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ អគ្គបញ្ជាការកងទ័ពជាតិសីហនុនិយម ។ ខាង រ.ជ.រ.ប.ខ. គ្មានទាហានចូលរួមទេ មានតែរូបខ្ញុំ (អៀង មូលី) និង លោក សឺន ស៊ូប៊ែរ្ត៍ ជាតំណាងកងទ័ព ។ តាមពិត តាមគំរោងឯកសារ គេត្រៀមឈ្មោះលោក សក់ ស៊ុតសាខន ជាអ្នកចុះហត្ថលេខាលើសេចក្តីប្រកាសព័ត៌មាន ។ គួររំលឹកឡើងវិញថា ទោះបីជាមានការផ្សះផ្សាគ្នា និង ទោះបីជាលោកឧត្តមសេនីយ សក់ ស៊ុតសាខន ត្រូវបានតែងតាំងជាផ្លូវការជាអគ្គមេបញ្ជាការនៃកងទ័ពយ៉ាងណាក៏ដោយ ក៏រវាងលោកតា សឺន សាន និង ក្រុមយោធារបស់លោក សក់ ស៊ុតសាខន គ្មានការសំរុះសំរួលគ្នាដែរ ។ លោក សក់ ស៊ុតសាខន ក្នុងឋានៈជាអគ្គមេបញ្ជាការក.ជ.រ.ប.ខ. មិនបានពិគ្រោះជាមួយលោកតា សឺន សាន ទេ ចំពោះកិច្ចការធំៗមួយចំនួនដូចជាការតែងតាំងលោក ដៀន ដែល និង លោក ប៉ុក សំអាន ជាអគ្គមេបញ្ជា

[259] The Nation, Sihanouk Assures Bangkok: He Won’t Meet Hun Sen, September 1, 1987.
[260] សុន សេន, អៀង មូលី, សឺន ស៊ូប៊ែរ្ត៍, ឧត្តមសេនីយត្រី ទួន ចាយ, សេចក្តីប្រកាសព័ត៌មាន, ថ្ងៃទី ២៧ សីហា ១៩៨៧ ។

ការរង និង ជានាយអគ្គសេនាធិការជាដើម ដូចមានក្នុងលក្ខខណ្ឌដែលលោកតា សឺន សាន បានដាក់ចេញមុននឹងធ្វើការតែងតាំងលោក សក់ ស៊ុតសាខន នោះ ។ លោកតា សឺន សាន ធ្លាប់បានលើកយកករណីគ្មានការពិគ្រោះគ្នាក្នុងការតែងតាំងលោក ដៀន ដែល និង លោក ប៉ុក សំអាន នេះ ទៅជំរាបលោកឧត្តមសេនីយ សុជិន្ដា ក្រាប្រយង្គ ក្នុងជំនួបមួយកាលពីថ្ងៃទី ២៨ មេសា ១៩៨៧[261] ។ តាំងពីពេលនោះមក លោកតា សឺន សាន និង លោក សក់ ស៊ុតសាខន បំពេញភារកិច្ចដោយឡែកពីគ្នាគឺ ខាងនយោបាយម្ខាង និង ខាងយោធាម្ខាង ដោយគ្មានសហការគ្នាយ៉ាងជិតស្និទ្ធឡើយ។ ការបាក់បែកនេះចេះតែបន្តរហូតដល់មានការបង្កើតគណបក្សនយោបាយពីរផ្សេងគ្នាសម្រាប់ការបោះឆ្នោតសកលឆ្នាំ ១៩៩៣ ។

## ទីបំផុតសម្ដេចឪសុំឲ្យតាៗជួយឲ្យមានការជួបគ្នា

បន្ទាប់ពីការប៉ុនប៉ងជួបគ្នានៅទីក្រុងព្យុងយ៉ាង មិនបានសម្រេចនោះមក សម្ដេច សីហនុ បានសរសេរសំបុត្រមួយច្បាប់នៅថ្ងៃទី ១៨ កក្កដា ១៩៨៧ ទៅជូនឥស្សរជនខ្មែរ នៅប្រទេសបារាំងគឺ៖ ឯ. ឧ. ញឹក ជូឡុង ចៅសែនកុសល ឈុំ ហ៊ុយ កន្ធិល ឈាន វ៉ែ នង គិមនី ថុន អ៊ុក និង ឯ. ឧ. ឌួង សំអុល ដើម្បីជួយរៀបចំឲ្យមានការជួបគ្នារវាងភាគីខ្មែរ ដែលមានជម្លោះជាមួយគ្នា[262] ។ មកដល់ចំណុចនេះ ខ្ញុំនឹកដល់កាលសម័យសង្គមរាស្ត្រនិយមក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ កាលព្រះអង្គក្ដាប់អំណាចយ៉ាងណែននោះ សម្ដេច សីហនុ តែងលើកហេតុផលថាដោយសារមានសំណើពីបាតុកម្ម ឬ សមាជជាតិ ទើបព្រះអង្គសម្រេចធ្វើសកម្មភាព

---

[261] សេចក្ដីបកប្រែសង្ខេបនៃពាក្យសន្ទនារវាង ឯ.ឧ.ប្រធាន ជាមួយ ឧ. សុជិន្ដា ក្រាប្រយង្គ កាលពីថ្ងៃទី ២៨ មេសា ១៩៨៧ ។

[262] ហ៊ុន សែន, ១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩, op. cit, ទំព័រ ១៧១ ។

នយោបាយអ្វីមួយ ។ ដូច្នេះលើកនេះ ព្រះអង្គយោងទៅលើអន្តរាគមន៍របស់ឥស្សរជនទាំង ៧ នាក់ ជាហេតុផលបន្ថែម ដើម្បីឈានទៅជួបចរចាជាមួយមេដឹកនាំក្រុងភ្នំពេញ ។ ក្នុងចំណោមឥស្សរជនទាំង ៧ រូប មួយចំនួនគឺ លោកតា ហ៊ុយ កន្ធុល ឈាន វ៉ម នង គិមនី និង ថុន អ៊ុក សុទ្ធតែជាសមាជិកក្រុមប្រឹក្សាព្រឹទ្ធាចារ្យ (Conseil des Sages) របស់រ.ជ.រ.ប.ខ. ដែលធ្លាប់ប្រកាសជាសាធារណៈដកសេចក្តីទុកចិត្តពីលោកតាប្រធានរ.ជ.រ.ប.ខ.ម្តងរួចហើយ កាលពីឆ្នាំ ១៩៨៥ ។ វរជនចាស់ទុំទាំងនោះ ប្រហែលជាយល់ឃើញថា គោលជំហរទន់ភ្លន់របស់សម្តេចសីហនុ អាចមានប្រសិទ្ធភាពជាងគោលជំហរលោកតា សឺន សាន ។ ចាប់តាំងពីចុងឆ្នាំ ១៩៨៥ រហូតមក លោកតា ហ៊ុយ កន្ធុល និង ថុន អ៊ុក ក៏បានចូលរួមយ៉ាងសកម្មជាមួយលោកឧត្តមសនីយ សក់ ស៊ុតសាខន ដើម្បីប្រឆាំងនិងការដឹកនាំរបស់លោកតា សឺន សាន ក្នុងជួររ.ជ.រ.ប.ខ. ។ នៅថ្ងៃ ទី ៤ កញ្ញា ១៩៨៧ ឥស្សរជនទាំង ៧ នាក់សរសេរសំបុត្រជូនរដ្ឋាភិបាលក្រុងភ្នំពេញ ដោយអំពាវនាវឲ្យមានការជួបគ្នា[263] ។ ទាក់ទងនិងជំនួប ហ៊ុន សែន - សីហនុ នេះ មេដឹកនាំក្រុងភ្នំពេញបានផ្ញើលិខិតទៅថ្វាយសម្តេច នៅឯទីក្រុងប៉ារីសតាំងពីមុនពេលព្រះអង្គយាងចេញពីទីក្រុងព្យុងយ៉ាងឯនោះ តែលិខិតនោះមិនបានទៅដល់សម្តេចទេ នេះបើតាមការអះអាងរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ លោកបានបកស្រាយថា "ពួកអ្នកហែហម និង កងរក្សាព្រះអង្គ" គេបង្កើតលក្ខខណ្ឌច្រើនបែបច្រើនយ៉ាងរហូតហ៊ានសម្រេចនូវកិច្ចការជំនួសសម្តេច ។ យ៉ាងនេះហើយ ដើម្បីជានាឲ្យមានការទាក់ទងផ្ទាល់ជាមួយសម្តេច សីហនុ ថ្នាក់ដឹកនាំក្រុងភ្នំពេញបានសម្រេចវាយទូរលេខថ្វាយព្រះអង្គតាមរយៈព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ព្រះរាជបុត្រ និងជាតំណាងរបស់ព្រះអង្គប្រចាំនៅទីក្រុងបាងកក ។ ព្រះអង្គម្ចាស់ រណឫទ្ធិ បាននាំ

[263] ហ៊ុន សែន, ១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩, op. cit. ទំព័រ ១៧២ ។

យកសារទូលេខទៅថ្វាយសម្តេច សីហនុ ផ្ទាល់នៅប្រទេសបារាំងដែលភ្លាមៗនោះ ព្រះអង្គបានឆ្លើយតបទៅទីក្រុងភ្នំពេញវិញ ដោយថ្លែងអំណរគុណផង និង យល់ព្រមជួបគ្នាផង ។ សម្តេចទុកលទ្ធភាពឲ្យភាគីភ្នំពេញជាអ្នកជ្រើសរើសថ្ងៃខែជួបគ្នា[264] ឯទីកន្លែងព្រះអង្គបានជ្រើសយកប្រទេសបារាំង ដោយបានទទួលការលើកទឹកចិត្តពីរដ្ឋាភិបាលបារាំងរួចហើយ ។ ចំពោះមេដឹកនាំក្រុងភ្នំពេញ ការដែលសម្តេចសុខចិត្តជួបចរចាគ្នានៅប្រទេសបារាំងលើកនេះ អាចចាត់ទុកជាឱកាសមាស ដែលមិនត្រូវឲ្យបាត់បង់បានឡើយ ។ ក្រុងភ្នំពេញជ្រើសយកថ្ងៃទី ២ ធ្នូ ១៩៨៧ សម្រាប់ការចរចាគ្នា ។ ការជ្រើសយកថ្ងៃទី ២ ធ្នូ នេះមិនមែនជ្រើសយកដោយចៃដន្យនោះទេ តែក៏ជាការគិតគូរឲ្យចំអត្ថន័យប្រវត្តិសាស្ត្រនៃការផ្តួលរំលំប៉ុល ពត ព្រោះថាថ្ងៃទី ២ ធ្នូ ១៩៨៧ ជាខួបឆ្នាំទី ៩ នៃកំណើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៧៨ នៅក្នុងស្រុកស្នួល ខេត្តក្រចេះ ដើម្បីប្រមូលកម្លាំងវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ។

ផែនការជំនួប សីហនុ - ហ៊ុន សែន នៅប្រទេសបារាំង មិនបានធ្វើឲ្យក្រុម រ.ជ.រ.ប.ខ.ចាប់អារម្មណ៍ប៉ុន្មានទេ ព្រោះយល់ថាបើគ្មានការគាំទ្រពីចិន និង អាស៊ានទេ ជំនួបនោះប្រាកដជានឹងទទួលបរាជ័យមិនខានឡើយ ។ ផ្ទុយទៅវិញ មនុស្សជិតស្និទ្ធជាមួយសម្តេច សីហនុ សំដែងសុទិដ្ឋិនិយម និង អំណរសាទរចំពោះគំរោងជំនួបនេះ ។ លោកតា ញ៉ឹក ជូឡុង ក្នុងលិខិតថ្វាយព្រះពរព្រះអង្គនាឱកាសចំរើនព្រះជន្មគំរប់ ៦៥ ព្រះវស្សា បានសរសេរជាភាសាបារាំងក្នុងន័យជាអាទិថា អ្វីដែលសម្តេចបានធ្វើកន្លងមកបានទទួលលទ្ធផលជាផ្លែផ្កា គួរជាទីកក់ក្តៅ ។ លិខិតនោះ នៅទីបញ្ចប់បានសរសេរថាខ្មែរទាំងអស់ទាំងក្នុង ទាំងក្រៅ ផ្តោត

[264] ហ៊ុន សែន, ១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩, op. cit, ទំព័រ ១៧៣ ។

សេចក្ដីសង្ឃឹមតែមួយគត់ និង ចុងក្រោយបំផុតទៅលើអង្គសម្ដេចឪ ព្រះបិតាឯករាជ្យខ្មែរ[265] ។ ចំណែកព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិបានសរសេរលិខិតថ្វាយព្រះពរមួយច្បាប់ទៀតជាភាសាបារាំង ដែលខ្ញុំសុំដកស្រង់អត្ថន័យជាភាសាខ្មែរនូវវគ្គមួយនេះដូចតទៅៈ "ខួបលើកទី៦៥ នៃព្រះរាជពិធីចំរើនព្រះជន្មវស្សាព្រះវរបីតានេះ ជាផ្លូវបត់ដ៏សំខាន់ក្រៃលែង (le grand tournant) នៃបញ្ហាកម្ពុជា ហើយទាំងនេះ ក៏ដោយសារការប្រឹងប្រែងដ៏ត្រឹមត្រូវ និង ឥតឈប់ឈររបស់ព្រះវរបីតាដើម្បីរកដំណោះស្រាយមួយ ដែលនឹងប្រកបដោយកិត្តិយស ព្រមទាំងត្រឹមត្រូវបំផុតសម្រាប់ប្រទេសដ៏កំសត់របស់យើង[266]" ។ សុទិដ្ឋិនិយមនេះក៏ស៊ីសង្វាក់ជាមួយគោលនយោបាយរបស់រដ្ឋាភិបាលក្រុងភ្នំពេញ ដែលប្ដេជ្ញាទាក់ទាញសម្ដេចសីហនុ ឲ្យចេញពីសម័ន្ធភាពជាមួយខ្មែរក្រហម ឲ្យបានជោគជ័យតាមយុទ្ធសាស្ត្រផ្ដួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ទោះជាត្រូវថ្វាយតំណែងកំពូលណាមួយដូចជា ប្រមុខរដ្ឋជាដើមចំពោះព្រះអង្គ ។

## ជំនួប សីហនុ - ហ៊ុន សែន នៅ ហ្វែរ អង់តាកដឺន័រ

តាមឯកសារទទួលបាន យើងអាចវិភាគបានថា សម្ដេច សីហនុ ប្រើព្រះឋានៈរបស់ព្រះអង្គជាអតីតព្រះមហាក្សត្រ ដើម្បីជួបជាមួយរាស្ត្រម្នាក់របស់ព្រះអង្គ ចំណែកឯក្រុងភ្នំពេញយល់ថាជំនួប សីហនុ - ហ៊ុន សែន ជាជំនួបរវាងគូបដិបក្ខ ដែលនឹងជួបពិភាក្សាគ្នាដោយស្មើភាព ដើម្បីស្វែងរកដំណោះស្រាយបញ្ចប់ជម្លោះនៅកម្ពុជា[267] ។ ទោះជាមានការយល់ឃើញខុសគ្នា អំពីទម្រង់នៃការជួបគ្នាយ៉ាង

[265] Nhiek Tioulong, [A] Son Altesse Royale Samdech Norodom Sihanouk du Cambodge, Sucy-en-Brie, le 27 Octobre 1987.
[266] Norodom Ranariddh, [lettre] datée à Bangkok, le 23 octobre 1987.
[267] ហ៊ុន សែន, ១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩, op. cit, ទំព័រ ១៧៤-១៧៥ ។

ណាក៏ដោយ ក៏នៅទីបំផុត ជំនួបបានត្រូវរៀបចំឡើងនៅ ហ្វែរ អង់តាកដឺន័រ (Fères-en-Tardenois) នៅប្រទេសបារាំង នៅថ្ងៃទី ២ ធ្នូ ១៩៨៧ ប្រាកដមែន ។ សម្តេច សីហនុ បានសន្យាថា ព្រះអង្គមិនលាក់បាំងអ្វីទាំងអស់ រាល់ការពិភាក្សាដែលព្រះអង្គធ្វើជាមួយមេដឹកនាំក្រុងភ្នំពេញ ដោយព្រះអង្គនឹងផ្តល់ដល់ពួកយើងក្នុងជួរ.ជ.រ.ប.ខ.នូវខ្សែអាត់ថតសម្លេង(កាសែតថតចម្លង)នៃអង្គប្រជុំទាំងអស់ ។ ដូច្នេះរូបខ្ញុំដែលកំពុងស្នាក់នៅឯទីក្រុងបាងកក ក៏ត្រៀមរង់ចាំស្តាប់ខ្សែអាត់ថតសម្លេងនោះយ៉ាងយកចិត្តទុកដាក់ ។ ប៉ុន្មានថ្ងៃក្រោយមក ខ្ញុំក៏បានទទួលខ្សែអាត់ដូចសន្យា តាមរយៈក្រុមការងារវិទ្យុសម្លេងខ្មែរហៅ វី អូ ខេ ។ ខ្ញុំចំណាយពេល ជាច្រើនម៉ោងដើម្បីស្តាប់ការពិភាក្សាទាំងអស់ ដែលថតក្នុងខ្សែអាត់រាប់សិបកាសែត ។ សូមបញ្ជាក់ថានៅថ្ងៃចុងក្រោយនៃការពិភាក្សាគឺ ថ្ងៃទី ៤ ធ្នូ ភាគីទាំងពីរ មានការចេញផ្សាយនូវសេចក្តីថ្លែងការណ៍រួមមួយមាន ៤ ចំណុចគឺៈ ១-បញ្ហាកម្ពុជាទាមទារឲ្យមានដំណោះស្រាយនយោបាយមួយ មិនមែនដោយកម្លាំងយោធាទេ ២-បញ្ហាកម្ពុជា ត្រូវដោះស្រាយដោយជនកម្ពុជាខ្លួនឯងតាមរយៈការចរចា ៣-នាំមកវិញនូវសន្តិភាព ការកសាងប្រទេសឡើងវិញ និង ការបង្កើតប្រព័ន្ធនយោបាយឯករាជ្យប្រជាធិបតេយ្យ អធិបតេយ្យ អព្យាក្រឹត មិនចូលបក្សសម្ព័ន្ធ ៤-ការជួបគ្នាលើកក្រោយនឹងប្រព្រឹត្តទៅនៅខែ មករា ១៩៨៨ [268]។ ទាំងនេះអាចរាប់បានជាចំណុចវិជ្ជមាននៃជំនួប ។ ចំពោះសម្តេច សីហនុ ព្រះអង្គបានផ្សព្វផ្សាយឲ្យសាធារណៈជនជ្រាបនូវខ្លឹមសារនៃជំនួប សីហនុ - ហ៊ុន សែន នោះមានជាអាទិថាៈ ជំនួបរវាងព្រះអង្គជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នោះ ជាការចរចាពិតប្រាកដ ដើម្បីសាកល្បងដោះស្រាយបញ្ហាកម្ពុជា ។

---

[268] ឯក សំអុល, ជំនួយស្មារតីស្តីពីដំណើរការចរចា ដើម្បីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា, ថ្ងៃទី ២ ធ្នូ ២០០៩ ។

ជំនួបនេះបានទទួលការអបអរសាទរពីជនរួមជាតិខ្មែរ ទាំងក្នុង ទាំងក្រៅភាគច្រើនយ៉ាងធំធេង និង ទទួលបានការពេញចិត្តពីសហគមន៍អន្តរជាតិ លើកលែងតែក្រុមស្រឡាញ់សង្គ្រាមខ្មែរក្រហម និង ពួកប្រជាភិថុតិខ្មែរខៀវ (ត្រង់នេះព្រះអង្គសំដៅទៅរកពួកយើងរ.ជ.រ.ប.ខ. ឬ ពួកលោកតា សឺន សាន) និង រដ្ឋាភិបាលបរទេសខ្លះ ដែលគេមានផលប្រយោជន៍ក្នុងការបន្តជម្លោះនៅកម្ពុជា ។ ចំពោះសម្តេច សីហនុ ព្រះអង្គទទួលយកការជួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថាដូចជាការជួបជាមួយអ្នកតំណាងក្រុងហាណូយ ឬ ក្រុងមូស្គូ យ៉ាងដូច្នោះដែរ ។ ក៏ប៉ុន្តែសម្តេចសំដែងការអាក់អន់ព្រះទ័យចំពោះក្រុងហាណូយដែលមិនព្រមចាត់បេសកជន ឲ្យមកចរចាផ្ទាល់ជាមួយព្រះអង្គអំពីបញ្ហាកម្ពុជា - វៀតណាម ទោះបីជានៅក្នុងរង្វង់ចលនាតស៊ូខ្មែរ ព្រះអង្គជាមេដឹកនាំតែមួយគត់ ដែលជៀសវាងមិននិយាយតែពីសតែពាសដូចលោកតា សឺន សាន និង អ្នកឯទៀត ដែលថា "វៀតណាមឈ្លានពានកម្ពុជា" ហើយម្យ៉ាងទៀតមានតែសម្តេចមួយអង្គគត់ ដែលមិនបានទាមទារឲ្យមានតែការចរចាផ្ទាល់ជាដាច់ខាត រវាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ជាមួយរដ្ឋាភិបាលចម្រុះត្រីភាគីយ៉ាងណាក៏ដោយ[269] ។

គួររំលឹកថា សម្តេច សីហនុ បានហៅលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថាកញ្ជ្រោងស្ទាវជាភាសាបារាំងថា (jeune renard) នៅក្នុងកំណត់ជូនអ្នកកាសែតនាឱកាសសិក្ខាសាលាទូទាំងពិភពលោករបស់ ហ៊្វុន ស៊ិន ប៉ិច នៅថ្ងៃទី ២០ ធ្នូ ១៩៨៧ នៅប្រទេសបារាំង ។ សម្តេច សីហនុ ក៏លើកឡើងនូវចំណុចមួយចំនួនដែលព្រះអង្គចង់បានជាចម្លើយជាក់លាក់ពីមេដឹកនាំក្រុងភ្នំពេញ នៅពេលជួបគ្នាម្តងទៀត នៅខែ មករា ១៩៨៨ ដូចតទៅ៖ ក្នុងករណីដែលមានការបង្កើតរដ្ឋាភិបាលផ្សះផ្សារួបរួមជាតិចតុភាគី តើលោក ហ៊ុន សែន យល់ព្រមដាក់រដ្ឋាភិបាលផ្សះ

---

[269] Norodom Sihanouk, Note pour la Presse, Roissy-en-France, le 20 Décembre 1987.

ផ្សារួបរួមជាតិចតុភាគីខាងលើ ឲ្យស្ថិតនៅក្រោមអំណាចច្បាប់នៃរដ្ឋកម្ពុជាថ្មីមួយ ដែលមិនមែនសាធារណរដ្ឋប្រជាមានិតកម្ពុជានៃរបបក្រុងភ្នំពេញ និង មិនមែនកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហមគឺ ព្រះអង្គចង់បានរបបថ្មីមួយទៀត[270] ។ ជាការពិតណាស់ចំពោះសម្តេច សីហនុ ដែលធ្លាប់ទាមទារឯករាជ្យពីបារាំងក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ ព្រះអង្គប្រាកដជាមានការលំបាកក្នុងការធ្វើមាតុភូមិនិវត្តន៍ចូលប្រទេសវិញ នៅចំពោះមុខវត្តមាននៃកងទ័ពវៀតណាមនៅកម្ពុជា ទោះបីជាកងទ័ពនេះបានជួយរំដោះកម្ពុជាពី ប៉ុល ពត យ៉ាងណាក៏ដោយ ។ ម្យ៉ាងទៀតសម្តេច សីហនុ ក៏ប្រាកដជាពិបាកដកព្រះអង្គពីកម្ពុជាប្រជាធិបតេយ្យ ដែលកំពុងទទួលបាននូវការទទួលស្គាល់ពីអង្គការសហប្រជាជាតិ ប្រសិនបើគ្មានរូបមន្តផ្លូវច្បាប់ថ្មីដែលអាចទទួលយកបានដូចជាយ៉ាងហោចណាស់ ឈ្មោះប្រទេស ទង់ជាតិ ភ្លេងជាតិជាដើម ។

នៅក្នុងកំណត់ជូនអ្នកកាសែត នាឱកាសសិក្ខាសាលា ហ៊្វុន ស៊ិន ប៉ិច នោះសម្តេច សីហនុ បានសរសេរថា នៅពេលជួបគ្នាម្តងទៀតនៅខែ មករា ១៩៨៨ ប្រសិនបើលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនឆ្លើយឲ្យបានច្បាស់លាស់នូវចំណុចសំណួរខាងលើទេ ព្រះដាយាព្រះអង្គគឺ អ្នកម្នាង ម៉ូនិច អនុប្រធានទី២ នៃហ៊្វុនស៊ិន ប៉ិច នឹងប្រឆាំងមិនព្រមឲ្យព្រះអង្គចុះព្រះហស្តលេខាលើសេចក្តីប្រកាសរួមជាមួយមេដឹកនាំក្រុងភ្នំពេញដូចមុនទៀតឡើយ រីឯជំនួប សីហនុ - ហ៊ុន សែន លើកទី៣ ដែលគ្រោងនឹងធ្វើនៅទីក្រុងព្យុងយ៉ាង ប្រទេសកូរ៉េខាងជើងនាខែ មេសា ១៩៨៨ ក៏នឹងត្រូវលើកសិន[271] ។

---

[270] ដូចយោងខាងលើ ។

[271] ដូចយោងខាងលើ ។

# សម្តេចសុំឲ្យប្តូរឈ្មោះ ភ្លេងជាតិ និង ទង់ជាតិនៃប្រទេសខ្មែរ

ដើម្បីត្រៀមជួបជាមួយមេដឹកនាំក្រុងភ្នំពេញ សម្តេច សីហនុ បានចេញសេចក្តីប្រកាសមួយ ជាពិសេសសំដៅទៅរដ្ឋាភិបាលចម្រុះត្រីភាគី និង ប្រទេសគាំទ្រ ព្រមទាំងមិត្តភក្តិនៃរដ្ឋាភិបាលនេះថា ការឈប់សម្រាកអវត្តមានរបស់ព្រះអង្គពីតំណែងប្រធានកម្ពុជាប្រជាធិបតេយ្យ មិនកំណត់ត្រឹមថ្ងៃទី ៧ ឧសភា ១៩៨៨ នោះទេ ក៏ប៉ុន្តែនឹងបន្តរហូតដោយគ្មានកំណត់ដរាបណាខ្មែរក្រហម (ភាគីកម្ពុជាប្រជាធិបតេយ្យ និង ខ្មែរខៀវ (រ.ជ.រ.ប.ខ.) ដៃគូទាំងពីររបស់ព្រះអង្គក្នុងរដ្ឋាភិបាលចម្រុះត្រីភាគី - មិនព្រមផ្លាស់ប្តូរឈ្មោះ រដ្ឋ ភ្លេងជាតិ និង ទង់ជាតិខ្មែរ និង ដរាបណាក្រុមទាំងនោះគឺ ខ្មែរក្រហម និង ខ្មែរខៀវនៅតែរំលោភសិទ្ធិមនុស្សទៅលើប្រជាពលរដ្ឋតទៅទៀត ។ ត្រង់នេះសម្តេច សីហនុ ចុចចំចំណុចខ្សោយរបស់ខ្មែរក្រហមគឺ ការរំលោភសិទ្ធិមនុស្ស ។ ចំណែកឯចំពោះរ.ជ.រ.ប.ខ.វិញ សម្តេចវាយប្រហារពីរយ៉ាង៖ ទី១. ព្រះអង្គប្រើពាក្យខ្មែរខៀវដែលព្រះអង្គធ្លាប់តែប្រើចំពោះខ្មែរនិយមលោក សឺង ង៉ុកថាញ់ ស្តាំនិយមសាធារណរដ្ឋក្បត់ជាតិ បន្ថែមលើពាក្យប្រជាភិថុត- ទី២. ព្រះអង្គចោទថារំលោភសិទ្ធិមនុស្សដូចខ្មែរក្រហមដែរ ។ គួរកត់សំគាល់ថានាសម័យនោះអង្គការក្រៅរដ្ឋាភិបាលមួយចំនួន បានចោទប្រកាន់មេដឹកនាំជំរុំនងចាន់ និង រិទ្ធិសែនរបស់រ.ជ.រ.ប.ខ.ថា បានរំលោភសិទ្ធិមនុស្ស ក៏ប៉ុន្តែក៏ពុំមានន័យថាជំរុំជនភៀសខ្លួនខ្មែរឯទៀត បានរួចខ្លួនផុតពីការចោទប្រកាន់អំពីបទរំលោភសិទ្ធិមនុស្សនោះឡើយ រួមទាំងជំរុំរបស់ខ្មែរក្រហម និង ជំរុំដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកសីហនុនិយមផង ។ សម្តេច សីហនុ ក៏ធ្លាប់តវ៉ាដែរ ទៅសភាអឺរ៉ុប ដែលបានចោទប្រកាន់ក្រុមចលនាតស៊ូទាំងអស់រួមទាំងចលនារបស់ព្រះអង្គផងនោះថា មានការរំលោភសិទ្ធិមនុស្ស ដែលនាំឲ្យសម្តេចឆ្លើយបកទៅវិញថាជា

ការចោទប្រកាន់អយុត្តិធម៌ ព្រមទាំងសុំឲ្យសភាអឺរ៉ុបបញ្ជូនបេសកជន មកស៊ើបអង្កេតនៅជំរុំសាយប៊ី និង មូលដ្ឋានភ្នំស្រួចទៀតផង[272] ។

តាមពិតទៅ នៅតាមជំរុំជនភៀសខ្លួន មេដឹកនាំនយោបាយដែលមិនបានរស់នៅផ្ទាល់ក្នុងជំរុំ មិនអាចជានានូវសុក្រិតភាពនៃការគ្រប់គ្រងជំរុំបានទេ ព្រោះអំណាចពិតប្រាកដស្ថិតនៅក្នុងកណ្តាប់ដៃនៃក្រុមនាយទាហានថៃដែលត្រួតត្រាលើមេជំរុំខ្មែរទៀតផងឯនោះទេ ។ មេដឹកនាំនយោបាយមានច្រើនតែត្រឹមឥទ្ធិពលខាងផ្លូវចិត្ត ឬ ខាងផ្លូវសីលធម៌តែប៉ុណ្ណោះ ។ ដូច្នេះ ការវាយប្រហាររបស់ព្រះអង្គមកលើ រ.ជ.រ.ប.ខ. គ្រាន់តែជាការគាបសង្កត់ផ្នែកនយោបាយ ដែលសម្តេច សីហនុ មានការប៉ិនប្រសព្វក្នុងការយកមកប្រើប្រាស់ ប្រឆាំងគូប្រកួតប្រជែងរបស់ព្រះអង្គតែប៉ុណ្ណោះ ។

ជាមួយនឹងការប្រកាស បន្តផ្អាកការងារជាប្រធានកម្ពុជាប្រជាធិបតេយ្យ សម្តេច សីហនុ ក៏បានផ្សព្វផ្សាយនូវលក្ខខណ្ឌមួយទៀត ឲ្យដៃគូទាំងពីរនោះទទួលយកគឺ ការផ្លាស់ប្តូរ ឈ្មោះ ភ្លេងជាតិ និង ទង់ជាតិនៃប្រទេសកម្ពុជា ដោយព្រះអង្គឲ្យជ្រើសយកឈ្មោះ កម្ពុជាជាភាសាខ្មែរ Cambodge ជាភាសាបារាំង និង Cambodia ជាភាសាអង់គ្លេស ចំណែកទង់ជាតិឲ្យយកទង់ជាតិសម័យមុនសង្គ្រាមគឺ ទង់ពណ៌ខៀវ ក្រហម មានរូបប្រាសាទអង្គរវត្តកំពូលបីពណ៌សនៅចំកណ្តាលឯភ្លេងជាតិ ឲ្យយកបទនគររាជ ដែលកម្ពុជាធ្លាប់ប្រើចាប់ពីទសវត្សរ៍ឆ្នាំ ១៩៤០ ១៩៥០ ១៩៦០ ត្រង់វគ្គទី២ផ្តើមពីប្រាសាទសីលាកំបាំងកណ្តាលព្រៃតទៅ[273]...។

---

[272] Norodom Sihanouk, Télégramme, Au Parlement Européen, Strasbourg, France ផ្សាយក្នុង www.norodomsihanouk.info le 2 Septembre 2004.
[273] Norodom Sihanouk, Déclaration de Norodom Sihanouk du Cambodge, Paris, le 10 Décembre 1987.

# លោកតាមិនចូលរួមប្រជុំ តែលបសុំជួប ហ៊ុន សែន ស្ងាត់ៗ

ដើម្បីចង់បញ្ជាក់ថា រ.ជ.រ.ប.ខ មិនមែនជាឧបសគ្គ ឬ ប្រឆាំងចំពោះជំនួប សីហនុ-ហ៊ុន សែន នាខែ ធ្នូនោះ រ.ជ.រ.ប.ខ.បានចេញសេចក្តីប្រកាសព័ត៌មានមួយ ដើម្បីបំភ្លឺអត្ថបទរបស់ទីភ្នាក់ងារសារព័ត៌មានបារាំង ចេញផ្សាយតាមសារព័ត៌មាន បាងកកប៉ុស្ត (Bangkok Post) នៅថ្ងៃទី ៩ ធ្នូ ១៩៨៧ ។ សេចក្តីប្រកាសមានន័យជាអាទិថា៖ សម្តេច សីហនុ និង លោករដ្ឋមន្ត្រីទី១ សឺន សាន ធ្លាប់ជួបពិភាក្សាគ្នាជាច្រើនដងមកហើយ អំពីគំរោងជំនួបសម្តេច សីហនុ-ហ៊ុន សែន ទាំងនៅទីក្រុងប៉ារីស ទាំងនៅទីក្រុងញូវយ៉ក ក្នុងរាល់មហាសន្និបាតអង្គការសហប្រជាជាតិ - លោករដ្ឋមន្ត្រីទី១ សឺន សាន បានទូលសម្តេចថា គាំទ្ររាល់វិធានការណាដែលមានគោលដៅបញ្ចប់ទុក្ខវេទនារបស់ប្រជាពលរដ្ឋខ្មែរ ដូច្នេះសំដែងស្វាគមន៍ចំពោះការផ្តួចផ្តើមគំនិតរបស់ព្រះអង្គនាពេលនេះ និង នៅពេលខាងមុខ[274] ។ សេចក្តីប្រកាសព័ត៌មានបន្តទៀតថា៖ លោករដ្ឋមន្ត្រីទី១ សឺន សាន មិនដែលប្រកែកថា មិនចូលរួមក្នុងការផ្តួចផ្តើមគំនិតរកសន្តិភាព ដែលនាំឲ្យមានការដកកងទ័ពវៀតណាមចេញពីកម្ពុជា និង ឲ្យមានការបោះឆ្នោតទូទៅ និង ដោយសេរី ឆ្ពោះទៅរកការផ្សះផ្សាជាតិនោះទេ ។ សេចក្តីប្រកាសព័ត៌មានបានថែងថា តាមទម្លាប់រៀងមក លោករដ្ឋមន្ត្រីទី១ សឺន សាន នឹងធ្វើការពិគ្រោះជាមួយប្រជាពលរដ្ឋដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់រ.ជ.រ.ប.ខ.គឺជនភៀសខ្លួនខ្មែរនៅក្នុងជំរុំ និងជាមួយក្របខ័ណ្ឌរ.ជ.រ.ប.ខ. ឬ កម្មាភិបាល (បើនិយាយតាមភាសាអ្នកនៅក្នុងស្រុកនាសម័យនោះ) ។ ក៏ប៉ុន្តែ ចំពោះការចូលរួមក្នុងជំនួប សីហនុ-ហ៊ុន សែន លើកទី ២ នៅខែ មករា ជាបន្ទាប់នោះ សេចក្តីប្រកាសព័ត៌មានមិនបានថែងឲ្យ

[274] Office of the Prime Minister, Coalition Government of Democratic Kampuchea, Press Communique, December 9, 1987.

ច្បាស់ថា ប្រាកដជានឹងចូលរួមទេ ព្រោះសំអាងទៅលើភារកិច្ចជាច្រើនដែលលោករដ្ឋមន្ត្រីទី១ កំពុងជាប់ដៃបំពេញ ដែលមិនអនុញ្ញាតឲ្យសន្យាទទួលយកភារកិច្ចថ្មីទៀតនៅឡើយ[275] ។ ជំហររបស់លោកតា សឺន សាន នៅពេលនោះហាក់ដូចជានៅពាំត្រណោតណាស់ ព្រោះម្យ៉ាង មិនហ៊ានធ្វើសកម្មភាពអ្វីឲ្យឃ្លាតចេញពីគោលជំហរចិន និង ប្រទេសអាស៊ានខ្លះ ដែលមានប្រទេសថៃជាអ្នកនាំមុខ ។ គោលជំហរនោះ ទាមទារឲ្យមានការដកកងទ័ពវៀតណាម ឬ ឲ្យចរចាជាមួយវៀតណាមជាមុន និង ម្យ៉ាងទៀត ក៏មិនចង់ឃើញសម្ដេច សីហនុ នាំមុខជានិច្ចក្នុងការផ្ដួចផ្ដើមគំនិតចរចា ជាមួយក្រុងភ្នំពេញ ឬ ស្វែងរកសន្តិភាព ។ នៅក្នុងសេចក្ដីថ្លែងការណ៍មួយចុះថ្ងៃទី ២១ ធ្នូ ១៩៨៧ លោកតា សឺន សាន ថ្លែងថានឹងចូលរួមប្រជុំជាមួយភាគីខ្មែរ (ជំនួប សីហនុ-ហ៊ុន សែន) ក្នុងឋានៈឯកជន មិនមែនក្នុងឋានៈជារដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលចម្រុះទេ ប្រសិនបើវៀតណាមចូលរួមដែរ ។ សេចក្ដីថ្លែងការណ៍បញ្ជាក់ថា ប្រសិនបើមានហេតុផលណាមួយ មិនអាចឲ្យវៀតណាមចូលរួមប្រជុំជាមួយភាគីខ្មែរភ្លាមៗទេនោះ លោករដ្ឋមន្ត្រីទី១ សឺន សាន សុំឲ្យវៀតណាមចេញសេចក្ដីថ្លែងការណ៍ជាឧឡារិកមួយ (តាមរយៈលិខិតផ្ញើជូនលោកអគ្គលេខាអង្គការសហប្រជាជាតិ ជាពិសេសជូនទៅប្រទេសមហាអំណាចទាំង៥ ដែលជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខឲ្យបានមុនពេលភាគីខ្មែរប្រជុំ ដោយសន្យាថានឹងដកកងទ័ពរបស់ខ្លួនទាំងអស់ពីកម្ពុជាយ៉ាងឆាប់ជាទីបំផុតបន្ទាប់ពីការប្រជុំខ្មែរចតុភាគី[276]។ បើនិយាយឲ្យខ្លី លោកតា សឺន សាន ចង់ចូលរួមប្រជុំជាមួយសម្ដេច សីហនុ ដែរ ប្រសិនបើវៀតណាមសន្យាដកកងទ័ពចេញពី

---

[275] ដូចយោងខាងលើ ។

[276] Son Sann, Statement of H E Son Sann Prime Minister of the Coalition Government of Democratic Kampuchea and President of the Khmer People’s National Liberation Front, December 21, 1987.

កម្ពុជា ជាលាយលក្ខណ៍អក្សរនៅចំពោះមុខអង្គការសហប្រជាជាតិ ជាពិសេសចំពោះមុខប្រទេសមហាយក្សទាំង៥នៃក្រុមប្រឹក្សាសន្តិសុខ ។

ចំពោះការដកកងទ័ពវៀតណាមនេះ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជានៅក្រុងភ្នំពេញបានឲ្យដឹងថា វៀតណាមបានដកកងទ័ព ចំនួន ២០ ០០០ នាក់រួចហើយ កាលពីខែ វិច្ឆិកា ១៩៨៧ កន្លងទៅ ហើយនឹងបន្តដកតទៅទៀត ក៏ប៉ុន្តែចំណុចសំខាន់នោះគឺ ក្រុងភ្នំពេញបានចងភ្ជាប់ការបញ្ឈប់ជំនួយយោធាដល់គ្រប់ភាគីក្នុងជំលោះ ជាមួយនិងការដកកងទ័ពវៀតណាមទាំងអស់ពីកម្ពុជា ដូចមានចែងក្នុងសេចក្តីអំពាវនាវកាលពីថ្ងៃទី ៨ តុលា ១៩៨៧ មាន ៥ ចំណុច[277] ។ យ៉ាងណាក៏ដោយ ទោះជាតាមរូបភាពក្រៅ លោកតា សឺន សាន បានបង្ហាញគោលជំហរតឹងតែងក្នុងការចរចាមិនខុសពីគោលជំហរខ្មែរក្រហមទេនោះ ក៏លោកតាលបចាត់ឲ្យមនុស្សជំនិតរបស់គាត់គឺ លោកឧត្តមសេនីយ ថាច់ រ៉េង ទាក់ទងជាសម្ងាត់ជាមួយក្រុងភ្នំពេញដែរ ដោយពុំបានឲ្យពួកយើងដែលកំពុងស្នាក់នៅទីក្រុងបាងកកបានដឹងសោះឡើយ ។ ក្នុងឯកសារដែលលោកតាចុះហត្ថលេខាដើម្បីឲ្យលោក ថាច់ រ៉េង ប្រើជារបៀបសារតាំង ហើយដែលពួកយើងរកឃើញច្រើនឆ្នាំក្រោយមកទៀតនោះ លោកតា សឺន សាន បានចេញសេចក្តីសម្រេចលេខពិសេសមួយ ចុះថ្ងៃទី ២៣ ធ្នូ ១៩៨៧ ចាត់តាំងលោកឧត្តមសេនីយ ថាច់ រ៉េង ជាអ្នកតំណាងផ្ទាល់របស់ប្រធានរ.ជ.រ.ប.ខ. ដើម្បីស្វែងរកដំណោះស្រាយ ទាក់ទងការដកកងទ័ពវៀតណាម និង ការផ្សះផ្សាជាតិ[278]។ ខ្ញុំយល់ថា ចំណាត់ការដ៏សម្ងាត់របស់លោកតាប្រធាន រ.ជ.រ.ប.ខ.នេះ ប្រហែលជាធ្វើតាមមតិរបស់លោក ថាច់ រ៉េង ខ្លួនឯងតែម្តង ព្រោះលោក ថាច់ រ៉េង មានទំនាក់ទំនងជាមួយក្រុមស៊ើបការសម្ងាត់របស់បារាំង ដែល

---

[277] ឯក សំអុល, ជំនួយស្មារតីស្តីពីដំណើរការចរចា ដើម្បីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា, op. cit ។

[278] Son Sann, Front National de Libération du Peuple Khmer, Décision No 87/SPECIAL/FNL, le 23 Décembre 1987.

អាចផ្តល់គំនិត ឲ្យរ.ជ.រ.ប.ខ.ទាក់ទងផ្ទាល់ជាមួយក្រុងភ្នំពេញ ដើម្បីចរចាគ្នា ។ ក៏ប៉ុន្តែបេសកកម្មរបស់លោក ថាច់ រ៉េង នោះមិនបានទទួលជោគជ័យទេដោយសារលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនព្រមទទួលឲ្យជួប ។ តាមជំនួយស្មារតីផ្ញើជូនលោកតា សឺន សាន លោកឧត្តមសេនីយ ថាច់ រ៉េង បង្ហាញហេតុផលថាបានជាលោក ហ៊ុន សែន មិនឲ្យជួបនោះ ព្រោះលោក ហ៊ុន សែន បានទទួលសំបុត្រមួយច្បាប់ពីអ្នកប្រឆាំងលោកតា សឺន សាន ម្នាក់នៅប្រទេសបារាំង ដែលជាក្រុមលោក សក់ ស៊ុតសាខន ។ សំបុត្រនោះរាយការណ៍យ៉ាងអាក្រក់អំពី រ.ជ.រ.ប.ខ. និង ជាពិសេស អំពីតួបុគ្គលរបស់ ឯ.ឧ. សឺន សាន ដែលនាំឲ្យលោក ហ៊ុន សែន សម្រេចមិនទទួលជួបជាមួយអ្នកតំណាងរបស់ប្រធាន រ.ជ.រ.ប.ខ. ។ បើតាមជំនួយស្មារតីនោះ លោក ថាច់ រ៉េង រាយការណ៍ថា លោក ហ៊ុន សែន ប្តេជ្ញាថានឹងធ្វើអ្វីៗទាំងអស់ដើម្បីទាក់ទាញសម្តេច សីហនុ ឲ្យមកសហការជាមួយក្រុងភ្នំពេញ ហើយថា លោក ហ៊ុន សែន នៅពេលនោះបដិសេធ ឯ.ឧ. សឺន សាន ចោល តែក៏បានឲ្យដឹងថា បើលោក សឺន សាន ចង់មកចូលរួម ឲ្យចូលទៅរួមប្រជុំក្នុងជំនួប សីហនុ-ហ៊ុន សែន លើកទី២ នៅពេលជាបន្តបន្ទាប់នោះទៅ ។ ជំនួយស្មារតីបានរាយការណ៍ទៀតថា នៅក្នុងប្រទេសមានការទាមទារតាមរយៈខិត្តបណ្ណជាច្រើនឲ្យសម្តេច សីហនុ យាងចូលកម្ពុជាឲ្យបានឆាប់ ហើយថាឯក្នុងប្រទេសនោះ គេមិនឮសម្លេងរបស់រ.ជ.រ.ប.ខ.ទាល់តែសោះ ។ នៅទីបញ្ចប់ លោក ថាច់ រ៉េង មានមតិថាត្រូវតែបន្តការតស៊ូតទៅទៀត ក៏ប៉ុន្តែបញ្ហានៅត្រង់ថាតើប្រទេសអាស៊ាន ចិន និងសហរដ្ឋអាមេរិកផ្តល់លទ្ធភាពជូនលោកប្រធានរ.ជ.រ.ប.ខ.ត្រឹមកំរឹតណា[279]?

គួររំលឹកថា បន្ទាប់បានជួបចរចាជាមួយសម្តេច សីហនុ ពីថ្ងៃទី ២ ទៅ ៤ ធ្នូ ១៩៨៧ រួចមក លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសរសេរសំបុត្រមួយច្បាប់ទៅ

[279] Thach Reng, Memorandum, (date illisible) Février 1988 ?

ជូនឥស្សរជន ៧ រូប ដែលបានជួយផ្តើមគំនិតជួយឲ្យមានការជួបគ្នាគឺៈ ឯ. ឧ. ញឹក ជូឡុង ចៅសែនកុសល ឈុំ ហ៊ុយ កន្ទុល ឈាន វ៉ម នង គិមនី ថុន អ៊ុក និង ឯ. ឧ. ឌួង សំអុល ដើម្បីថ្លែងអំណរគុណផង និង ដើម្បីអំពាវនាវឲ្យឥស្សរជនចាស់ទុំទាំងនោះ ជួយបន្តប្រឹងប្រែងខឹតខំអញ្ជើញភាគីឯទៀតមានលោកតា សឺន សាន និង លោក ខៀវ សំផន ឲ្យមកចូលរួមប្រជុំនៅលើកក្រោយៗទៀត[280]។ ដូចនេះ ជាដំបូងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានបំណងចង់ឲ្យមានការជួបចរចាជាមួយភាគីខ្មែរទាំងអស់ ក៏ប៉ុន្តែលោកក៏ត្រូវមានការប្រយ័ត្នប្រយែងកុំឲ្យមានការបកស្រាយបន្ថយសារសំខាន់នៃជំនួប សីហនុ - ហ៊ុន សែន ដែលទើបសម្រេចរួបរាងហើយនោះ ។ គេអាចវិភាគបានថាការដែលលោក ហ៊ុន សែន សម្រេចមិនទទួលជួបអ្នកតំណាងប្រធានរ.ជ.រ.ប.ខ.មានហេតុផលពីរយ៉ាង៖ ម្យ៉ាង បើទទួលឲ្យជួបហាក់ដូចជាទុកឲ្យលោកតា សឺន សាន កេងចំណេញខ្លាំងពេក ព្រោះលោកតា និង រ.ជ.រ.ប.ខ.តែងតែ និង នៅតែចាត់ទុករបបភ្នំពេញជារបបខុសច្បាប់ ជាកញ្ជះយួន ឬ អាយ៉ងយួន ។ កេងយកចំណេញ នៅត្រង់លោកតាអាចជួបផង និង អាចជេរផង ។ ដូច្នេះមិនត្រូវលបជួបជាសំងាត់ទេ ។ ម្យ៉ាងទៀត បើជួបលោកតា សឺន សាន សម្តេច សីហនុ អាចយល់ថាតួអង្គរបស់ព្រះអង្គមិនមានប្រយោជន៍អ្វីប៉ុន្មានឡើយ សម្រាប់ក្រុងភ្នំពេញ ។ នៅលើចំណុចនេះ សម្តេច សីហនុ បានលើកឡើងកាលពីថ្ងៃទី ១១ ធ្នូ ១៩៨៧ ក្នុងជំនួបជាមួយបណ្តាទូតនៃក្រុមប្រទេសអាស៊ាន នៅហ្វែរ អង់តាកដឺន័រ (Fères-en-Tardenois) ប្រទេសបារាំងថា ហ៊ុន សែន ត្រូវការ សឺន សាន និង ខៀវ សំផនជាងត្រូវការ សីហនុ[281] ។

---

[280] ហ៊ុន សែន, ១០ ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩, op. cit.ទំព័រ ១៨០ ។

[281] ដូចយោងខាងលើ ។

លោកតា សឺន សាន និង មនុស្សស្និទ្ធរបស់លោកតា បានលាក់បាំងការប៉ុនប៉ងទាក់ទងជាសម្ងាត់ជាមួយមេដឹកនាំក្រុងភ្នំពេញយ៉ាងជិតបំផុត ។ ពួកយើងក្មេងៗដែលពេលនោះកំពុងស្នាក់នៅឯទីក្រុងបាងកក ជឿប្រាកដក្នុងចិត្តថាគ្មានការប៉ុនប៉ងទាក់ទងជាសម្ងាត់ណាមួយឡើយ ។ ពួកយើងជឿថាលោកតា សឺន សាន មិនមែនជាមនុស្សនិយាយផ្សេងធ្វើផ្សេងនោះទេ ។ ម្យ៉ាងទៀត ពួកយើងក៏មិនបានដឹងថាលោកតា សឺន សាន បានចេញសេចក្តីសម្រេចតែងតាំងលោក ថាច់ រ៉េង តាមផ្លូវការជាតំណាង ឲ្យទៅទាក់ទងជាសម្ងាត់ជាមួយមេដឹកនាំក្រុងភ្នំពេញសោះទេ ។ ការសម្ងាត់របស់លោកតា សឺន សាន បានត្រូវបែកធ្លាយនៅពេលសម្តេចសីហនុ ជួបចរចាជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន លើកទី ២ នៅ សាំងហ្សេកម៉ាំង អង់ឡេយ (Saint-Germain-en-Laye) នៅថ្ងៃទី ២០ និង ២១ មករា ១៩៨៨ ព្រោះនៅពេលនោះ លោក ហ៊ុន សែន បានទូលសម្តេចអំពីការប៉ុនប៉ងទាក់ទងជាសម្ងាត់របស់លោកតា សឺន សាន តាមរយៈលោក ថាច់ រ៉េង ។ សម្តេចសីហនុ បានផ្សព្វផ្សាយព័ត៌មាននេះយ៉ាងទូលំទូលាយ នៅពេលព្រះអង្គរាយការណ៍អំពីជំនួបលើកទី២ ជាមួយលោក ហ៊ុន សែន នៅក្នុងរបាយការណ៍របស់ព្រះអង្គត្រង់ទំព័រទី៧ ភាគទី២ ។

គួរបញ្ជាក់ថា នៅថ្ងៃទី ១៩ មករា ១៩៨៨ គឺ មុនជំនួប សីហនុ-ហ៊ុន សែន លើកទី២ មួយថ្ងៃ លោកតា សឺន សាន បានចូលគាល់សម្តេច សីហនុ ដើម្បីបញ្ជាក់គោលជំហរដដែលៗសាជាថ្មីថាលោកតានឹងចូលរួមប្រជុំជាមួយ ប្រសិនបើមានអ្នកតំណាងប្រទេសវៀតណាមមានវត្តមានចូលរួមប្រជុំ ឬ ប្រសិនបើវៀតណាមផ្ញើលិខិតទៅលោកអគ្គលេខាអង្គការសហប្រជាជាតិ ដោយសន្យាថានឹងដកកងទ័ពទាំងអស់របស់ខ្លួនចេញពីប្រទេសកម្ពុជាក្រោយអង្គប្រជុំនោះ[282] ។ សេចក្តីប្រកាសព័ត៌

[282] Office of the Prime Minister, Coalition Government of Democratic Kampuchea, Communiqué de Presse, Paris, le 19 Janvier 1988.

មានរបស់ការិយាល័យលោករដ្ឋមន្ត្រីទី១ សឺន សាន នៅទីក្រុងប៉ារីសទាក់ទងនឹងការចូលគាល់នេះ មិនបាននិយាយដល់ការប៉ុនប៉ងជួបចរចាជាមួយលោក ហ៊ុន សែន ជាសម្ងាត់នោះទេ ។ ក៏ប៉ុន្តែ នៅថ្ងៃ ទី ២៣ មករា ១៩៨៨ បន្ទាប់ពីសម្តេចសីហនុ បានផ្សព្វផ្សាយព័ត៌មានស្តីពីការប៉ុនប៉ងទាក់ទងជាសម្ងាត់របស់លោកតា សឺន សាន នោះភ្លាម ការិយាល័យរ.ជ.រ.បខ.ប្រចាំនៅទីក្រុងប៉ារីសជាទីដែលលោកតា សឺន សាន កំពុងស្នាក់នៅ បានចេញសេចក្តីប្រកាសមួយទៀត បដិសេធយ៉ាងដាច់អហង្ការនូវព័ត៌មាន ដែលថាលោកតា សឺន សាន ប៉ុនប៉ងស្វែងរកការចរចាជាសម្ងាត់ជាមួយលោក ហ៊ុន សែន ដោយបកស្រាយថាជាព័ត៌មានមិនពិតប្រឌិតដោយលោក ហ៊ុន សែន តែប៉ុណ្ណោះ ។ សេចក្តីប្រកាសព័ត៌មាននោះ បន្តទៀតថាក្នុងឋានៈជារដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលស្របច្បាប់ ដែលទទួលស្គាល់ដោយអង្គការសហប្រជាជាតិ ឯ. ឧ. សឺន សាន មិនដែលមានគំនិតជួបនរណាមួយនៃរបបខុសច្បាប់នៅភ្នំពេញសោះឡើយ[283] ។ ជាមួយគ្នានេះ ពួកយើងដែលនៅប្រចាំការឯទីក្រុងបាងកកក៏ជួយបន្ទរបន្ថែម បដិសេធព័ត៌មានស្តីពីការប៉ុនប៉ងជួបសម្ងាត់របស់លោកតា សឺន សាន ថាជាព័ត៌មានមិនពិត ព្រោះព័ត៌មាននោះត្រូវបានផ្សព្វផ្សាយតាមបណ្តាញសារព័ត៌មានអន្តរជាតិ[284] ។ ជាងនេះទៅ ទៀត រូបខ្ញុំ (អៀង មូលី) ក្នុងឋានៈជាជំនួយការ (ឧបការី) នៃប្រធានរ.ជ.រ.ប.ខ.បានផ្ញើលិខិតមួយច្បាប់ទៅបណ្ណាធិការរបស់សាព័ត៌មានបាងកកប៉ុស្ត៍ បំភ្លឺអត្ថបទមួយ របស់លោក ហ្សាក់ បេកាអ៊ែរ (Jacques Bekaert) ដែលសរសេរថា "លោក ប្រធានរ.ជ.រ.ប.ខ. សឺន សាន បានប៉ុនប៉ងដោយខ្លួនឯង ដើម្បីជួបជាសម្ងាត់ជា មួយលោក ហ៊ុន សែន" និងថា "ការប៉ុនប៉ងនេះនាំឲ្យក្រុមប្រទេសអាស៊ានរិះគន់យ៉ាងខ្លាំង"[285] ។ នៅក្នុង

[283] Le Bureau d'Information du FNLPK à Paris, Communiqué, Paris, le 23 Janvier 1988.
[284] Khmer People's National Liberation Front, Press Release, January 26, 1988.
[285] Ieng Mouly, Letter to the Editor, Bangkok Post, Bangkok, January 29, 1988.

លិខិតរបស់ខ្ញុំៗបដិសេធព័ត៌មាននោះទាំងស្រុងថាជាព័ត៌មានគ្មានមូលដ្ឋាន ព្រោះខ្ញុំជឿច្បាស់ថាលោកតា សឺន សាន មិនមានផែនការជួប លោក ហ៊ុន សែន នោះទេ បើគ្មានវត្តមានរបស់អ្នកតំណាងវៀតណាមនៅក្នុងអង្គប្រជុំ ដូចដែលលោកតាធ្លាប់ប្រកាសញឹកញាប់មកហើយ តាមបន្ទាត់នយោបាយរបស់រដ្ឋាភិបាលត្រីភាគី ។ ម្យ៉ាងទៀតខ្ញុំសរសេរបែបនោះ ក៏ដោយសារតែខ្ញុំពុំបានដឹងពីកិច្ចការសម្ងាត់ ដែលលោកតា សឺន សាន បានចាត់ចែងនៅឯទីក្រុងប៉ារីសជា មួយលោក ថាច់ រ៉េង និងក្រុមគ្រួសាររបស់លោកតាយ៉ាងស្ងាត់ជាទីបំផុត ។

# ជំនួបលើកទី២ នៅ សាំង ហ្សែកម៉ាំង អង់ ឡេយ

នៅជំនួប សីហនុ-ហ៊ុន សែន លើកទី២ អ្វីដែលព្រះអង្គចង់បានជាចម្លើយពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺការដកកងទ័ពវៀតណាម និង ការបង្កើតរបបរដ្ឋមួយថ្មី ដែលមិនមែនជាសាធារណរដ្ឋប្រជាមានិតកម្ពុជា និង ក៏មិនមែនជារដ្ឋកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហមដែរ ។ សម្តេច សីហនុ ធ្លាប់ដាក់ជាលក្ខខណ្ឌចំពោះលោក ខៀវ សំផន និង លោកតា សឺន សានឲ្យផ្លាស់ប្តូរឈ្មោះ ទង់ជាតិ និងភ្លេងជាតិរបស់ខ្មែរក្រហមចេញ ដោយឲ្យយកឈ្មោះកម្ពុជាជាភាសាខ្មែរ ឲ្យយកទង់ជាតិខ្មែរសម័យមុនសង្គ្រាមគឺទង់ ពណ៌ខៀវ ក្រហម និង រូបប្រាសាទអង្គរពណ៌សកំពូលបីនៅចំកណ្តាល រីឯភ្លេងជាតិឲ្យយកបទនគររាជត្រង់វគ្គទី ២ បើចង់ឲ្យព្រះអង្គបន្តសហការតទៅទៀត ។ ជាមួយនោះសម្តេច សីហនុ ក៏ចង់ឲ្យលោក ហ៊ុន សែន ទទួលយកសំណើនេះរបស់ព្រះអង្គដែរ ។ នៅត្រង់ចំណុចនេះ លោក ខៀវ សំផន ក្នុងនាមខ្មែរក្រហម បានផ្ញើសំបុត្រមួយច្បាប់មកលោកតា សឺន សាន ដើម្បីកុំឲ្យបោះបង់ចោលនូវរដ្ឋកម្ពុជាប្រជាធិបតេយ្យ ដែលមានលក្ខណៈស្របច្បាប់ដោយបានការទទួលស្គាល់ពីអង្គការសហប្រជាជាតិ ។ លោក ខៀវ សំផន បាន

សរសេរថា "យើងចាំបាច់ឈរឲ្យរឹងមាំលើឋានៈនៃរដ្ឋកម្ពុជាប្រជាធិបតេយ្យជារដ្ឋស្របច្បាប់តែមួយគត់នៃកម្ពុជា" ។ តែអ្វីដែលគួរឲ្យអស់សំណើចនោះ នៅត្រង់មេខ្មែរក្រហមរូបនេះអះអាងថា "រដ្ឋកម្ពុជាប្រជាធិបតេយ្យប្រសូតចេញមកពីសភាដែលជ្រើសរើសឡើងតាមការបោះឆ្នោតសកល សេរី ផ្ទាល់ និង ស្ងាត់ នាខែ កុម្ភៈ ១៩៧៦" (លោក ខៀវ សំផន មិនបានដាក់ឲ្យច្បាស់លាស់ទេថា តើខ្មែរក្រហមបោះឆ្នោតនៅថ្ងៃណានាខែ កុម្ភៈ ១៩៧៦នោះ) ។ នៅពេលនោះ ខ្មែរក្រហមនៅចចេសមិនទាន់ទទួលយកសំណើរបស់សម្តេច សីហនុ នៅឡើយទេ ។ ចំណែកឯ រ.ជ.រ.ប.ខ.មិនមានបញ្ហាអ្វីទេ ក្នុងការទទួលតាមសំណើរបស់ព្រះអង្គ ។ គួររំលឹកថានៅក្នុងជំនួបលើកទី២ នៅ សាំង ហ្សែកម៉ាំង អង់ ឡេយនោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានទូលសួរសម្តេច សីហនុ ថាតើការបង្កើតរបបថ្មីនោះស្ថិតនៅលើមូលដ្ឋានច្បាប់អ្វី? ព្រោះថាលោកនាយករដ្ឋមន្ត្រីជឿថាមានតែសាធារណរដ្ឋប្រជាមានិតកម្ពុជាទេ ដែលជាកម្លាំងយ៉ាងរឹងមាំដើម្បីវាយកំទេចរបបប្រល័យពូជសាសន៍ ប៉ុលពត កុំឲ្យវិលមកកាប់សម្លាប់ប្រជាជនទៀតបាន ។ កាលពីជំនួបលើកមុន នៅខែ ធ្នូ កន្លងទៅលោក ហ៊ុន សែន ធ្លាប់ស្នើសម្តេច សីហនុ ឲ្យភាគីទាំងពីរសហការគ្នាដើម្បីដោះស្រាយបញ្ហាកម្ពុជាគឺ សម្តេចវិលត្រឡប់មកដឹកនាំសាធារណរដ្ឋប្រជាមានិតកម្ពុជា ចំណែកឯកម្លាំងរបស់ព្រះអង្គ នឹងមានតួនាទីដ៏សំខាន់ក្នុងការកសាងប្រទេស[286] ។ តាមពិតទៅ មេដឹកនាំក្រុងភ្នំពេញមានយុទ្ធសាស្ត្រ និង យុទ្ធវិធីច្បាស់លាស់ក្នុងការចរចាគឺ៖ ១-រក្សាឲ្យបាននូវសមិទ្ធផលសង្គម ដែលកើតចេញពីថ្ងៃ ៧ មករា ១៩៧៩ និង ២-វាយកំទេចឲ្យអស់នូវរបបប្រល័យពូជសាសន៍ទាំងកម្លាំងយោធា ទាំងអង្គការចាត់តាំងនយោបាយ ។ នៅជំនួបលើកទី ២ នាខែ មករា ១៩៨៨ នេះដែរ លោក ហ៊ុន សែន ក៏បានស្ទង់ស្ទាបមតិសម្តេច សីហនុ

---

[286] កែវ បាភ្នំ, សម្តេច ហ៊ុន សែន និង ពាក្យសន្យាជាប្រវត្តិសាស្ត្រ, ឯកសារជំនួយស្មារតី op. cit. ទំព័រ ៧៧ ។

ថាតើព្រះអង្គយល់យ៉ាងណា ប្រសិនបើមានជំនួប ហ៊ុន សែន-សឺន សាន ដោយសារតែលោកតា សឺន សាន បានសុំជួបជាសម្ងាត់? តាមការវាយតម្លៃរបស់មេដឹកនាំក្រុងភ្នំពេញ សម្តេចមិនចង់ទុកឲ្យលោកតា សឺន សាន ចូលរួមក្នុងការចរចា ហ៊ុន សែន - សីហនុ ទេគឺ ព្រះអង្គមិនចង់ឲ្យភាគី សឺន សាន ជួបភាគីភ្នំពេញ ទេ[287] ។ គួររំលឹកថា នៅពេលដែលសម្តេច សីហនុ ផ្សព្វផ្សាយដំណឹងអំពីលោកតា សឺន សាន ចង់ជួបជាសម្ងាត់ជាមួយភាគីភ្នំពេញនោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានឲ្យអ្នកកាសែតដឹងពីលិខិតសិទ្ធិប្រទានដែលលោកតា សឺន សាន ផ្តល់ឲ្យលោកឧត្តមសេនីយ ថាច់ រ៉េង ទាក់ទងជាមួយភាគីភ្នំពេញ ។ លោក ហ៊ុន សែន ធ្វើយ៉ាងនេះ ដើម្បីទប់ទល់ជាមួយលោកតា សឺន សាន ផង និង ដើម្បីជាជំនួយគាំទ្រសម្តេច សីហនុ ផង ។ សកម្មភាពនយោបាយរបស់លោក ហ៊ុន សែន បែបនេះ បានធានាចំពោះសម្តេច សីហនុ នូវសារៈសំខាន់នៃសហការរវាងភាគីទាំងពីរ ដែលត្រូវតែដើរទៅមុខជានិច្ច ទោះបីជាភាគីពីរទៀតមិនចូលរួមក៏ដោយ ។ម្យ៉ាងទៀត ការលាតត្រដាងការសម្ងាត់ស្តីពីសំណើសុំជួបពីសំណាក់លោកតា សឺន សាន ជាការបញ្ជាក់ថ្វាយសម្តេច សីហនុ ថាទោះបីជាដៃគូរបស់ព្រះអង្គក្នុងជួររដ្ឋាភិបាលចម្រុះប្រកាស មិនជួបចរចាជាមួយក្រុងភ្នំពេញយ៉ាងណាក៏ដោយ ក៏គង់មានអ្នកខ្លះមកលបសុំជួបដោយស្ងាត់ៗដែរ ។

នៅថ្ងៃទី ២០ កុម្ភៈ ១៩៨៨ ពីទីក្រុងប៉េកាំង សម្តេច សីហនុ ផ្ញើសារជូនជនរួមជាតិខ្មែរ ដែលអានដោយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ជាព្រះរាជបុត្រ និងជាតំណាងព្រះអង្គប្រចាំនៅទីក្រុងបាងកក ដើម្បីពន្យល់ពីដំណើរការនៃការចរចាកន្លងមកជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ សម្តេច សីហនុ ទាញហេតុផលថា ដោយសារលោក ហ៊ុន សែន មិនព្រមរំលាយរបបសាធារណរដ្ឋប្រជាមានិត

[287] កែវ បាត្នំ, មានយោងដូចខាងលើ ទំព័រ ១០៨ ។

កម្ពុជា ជាមួយនិងការបដិសេធមិនព្រមរំលាយរបបកម្ពុជាប្រជាធិបតេយ្យ ព្រះអង្គមិនទាន់អាចយាងចូលមកក្នុងប្រទេសបាននៅឡើយទេ ។ នៅក្នុងសាររបស់ព្រះអង្គនោះ សម្ដេច សីហនុ វាយប្រហារភាគីឯទៀតថាមិនបានគិតពីផលប្រយោជន៍ជាតិ គិតតែប្រយោជន៍រៀងៗខ្លួន ដោយហៅឈ្មោះភាគីទាំងនោះជាភាគីខ្មែរវៀតមិញ ខ្មែរក្រហម និង ខ្មែរខៀវ (ខ្មែរខៀវគឺពួក សឺន សាន - សក់ ស៊ុតសាខន សាធារណរដ្ឋនិយម) ។ ក៏ប៉ុន្តែលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើសេចក្តីសន្និដ្ឋានបែបសុទិដ្ឋិនិយមលើជំនួប សីហនុ - ហ៊ុន សែន លើកទី២ នៅប្រទេសបារាំងថា ការចរចាលើកទី ២ នេះ ពិតមែនតែបានបញ្ចប់ដោយគ្មានចេញសេចក្តីប្រកាសរួម ប៉ុន្តែភាគីទាំងពីរសុទ្ធតែចាត់ទុកថាជាជំហានរីកចំរើនមួយថ្មីទៀតក្នុងការឆ្ពោះទៅរកការដោះស្រាយពិតប្រាកដនូវបញ្ហាកម្ពុជា ។ មិនតែប៉ុណ្ណោះ ភាគីទាំងពីរបានព្រមព្រៀងថានឹងជួបគ្នាជាបន្តបន្ទាប់ទៀត ។

ខ្ញុំសូមស្លេះទុកមួយអន្លើសិន នូវដំណើរបត់បែនទៅរកសន្តិភាពនៅ កម្ពុជាត្រឹមភាគទីមួយនេះ ក៏ប៉ុន្តែនឹងបន្តនៅភាគទីពីរក្នុងសៀវភៅមួយទៀត ។ នៅក្នុងដំណើរសន្តិភាពនេះ ជំនួប សីហនុ-ហ៊ុន សែន ជាចំណុចគន្លឹះមួយនៃដំណោះស្រាយបញ្ហាកម្ពុជា នៅពេលដែលបញ្ហានេះត្រូវបានបំបែកជាពីរទិដ្ឋភាពគឺ ទិដ្ឋភាពជាតិ និង ទិដ្ឋភាពអន្តរជាតិ ។ នៅក្នុងទិដ្ឋភាពជាតិ លោកនាយករដ្ឋមន្ត្រីហ៊ុន សែន សង្កត់ធ្ងន់លើការផ្សះផ្សាបង្រួបបង្រួមជាតិ ដោយមានមូលដ្ឋានលើការវាយផ្ដួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត រួមទាំងកម្លាំងយោធា និង អង្គការចាត់តាំងនយោបាយផង ។ ភាគីណាដែលប្រឆាំងនិងគោលការណ៍បែបនេះ ប្រាកដជានឹងត្រូវទទួលការចោទប្រកាន់ពីសំណាក់ប្រជាជនកម្ពុជាថា ចូលដៃជាមួយ ប៉ុល ពត មិនខានឡើយ ។ ជំនួប សីហនុ-ហ៊ុន សែន បានទម្លុះភាពទាល់ច្រកមួយព្រោះនោះជាការចាប់ផ្ដើមនៃការផ្សះផ្សាជាតិ ដែលជាកត្តាចម្បងបំផុតនៃការ

កសាងសន្តិភាព និង ការរស់រានមានជីវិតរបស់កម្ពុជាយើង ។ ការដែលសម្តេច សីហនុ ជួបចរចាជាមួយមេដឹកនាំក្រុងភ្នំពេញ ក៏បានន័យថាព្រះអង្គទទួលស្គាល់ សមិទ្ធផលសង្គម ដែលកើតឡើងដោយសារថ្ងៃទី ៧ មករា ១៩៧៩ រួចទៅហើយ ។ ជំនួបនេះ ក៏បង្ហាញឲ្យឃើញថាខ្មែរខ្លួនឯង ក៏ខំស្វែងរកដំណោះស្រាយ បញ្ហារបស់ខ្មែរដែរ ទោះជាបញ្ហានោះរបូតផុតពីដៃខ្មែរយ៉ាងណាក៏ដោយ ។ ទាំងនេះក៏ជាសម្ពាធនយោបាយទៅលើតួអង្គទាំងអស់នៅក្នុងជម្លោះកម្ពុជា ឲ្យសិក្សាឡើងវិញនូវយុទ្ធសាស្ត្ររៀងៗខ្លួន ។ ជំនួប សីហនុ-ហ៊ុន សែន មិនអាចកើតមានបានឡើយ ប្រសិនបើគ្មានសេចក្តីប្តេជ្ញាចិត្តយ៉ាងដាច់ខាតពីតួអង្គដ៏សំខាន់ ២ អង្គ នៃប្រវត្តិសាស្ត្រសម័យទំនើបរបស់កម្ពុជា ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងភាពអង់អាច បានដឹកនាំការប្រយុទ្ធយ៉ាងមុតស្រួច តម្រង់ទៅគោលដៅមួយដោយគ្មានងាករេគឺ ការផ្តួលរំលំរបបប្រល័យពូជសាសន៍ឲ្យបានជោគជ័យ ទោះជាត្រូវធ្វើពលីកម្មអ្វីក៏ដោយ ។ សម្តេចព្រះ នរោត្តម សីហនុ ដែលរាល់សកម្មភាពរបស់ព្រះអង្គ សុទ្ធតែត្រូវបានផ្សារភ្ជាប់ជាមួយនឹងព្រឹត្តិការណ៍របស់ប្រជាជាតិខ្មែរទាំងអស់នោះ បានប្តេជ្ញាថាអ្វីៗអាចធ្វើបានទាំងអស់ ឲ្យតែអាចបញ្ចប់ទុក្ខវេទនារបស់កូនចៅ ប្រជារាស្ត្ររបស់ព្រះអង្គបាន ទោះជាត្រូវប្រឈមជាមួយឧបសគ្គអ្វីក៏ដោយ ។

# សេចក្តីសន្និដ្ឋាន

នៅក្នុងប្រទេសនីមួយៗ វាសនារបស់ពលរដ្ឋ តែងត្រូវបានផ្សារភ្ជាប់ទៅនឹងវាសនារបស់ជាតិ ឯវាសនាជាតិក៏អាស្រ័យលើគុណភាព ឬ ទេពកោសល្យដឹកនាំរបស់អ្នកដឹកនាំ និង របៀបរបបគ្រប់គ្រងនៃប្រទេសជាតិនោះ ។ ប្រទេសកម្ពុជាយើងពីឆ្នាំ ១៩៦០ ទៅ ១៩៧០ ស្ថិតនៅក្នុងបរិបទភូមិសាស្ត្រនយោបាយមួយដែលមហាអំណាចប្រើកម្លាំងរៀងៗខ្លួន ដើម្បីដណ្តើមឥទ្ធិពលលើប្រទេសតូចតាច ។ ប្លុកម្ខាងធ្វើសង្គ្រាមក្នុងនាមមនោគមវិជ្ជាកុម្មុយនីស្ត ដើម្បីរំដោះមនុស្សជាតិចេញពីអាណានិគមនិយម មូលធននិយម ក្នុងន័យកសាងសង្គមអន្តរជាតិមួយដែលជឿនលឿន ស្អាតស្អំ និង ស្មើភាពគ្នា ។ ប្លុកមួយទៀត ធ្វើសង្គ្រាម ដើម្បីការពារសិទ្ធិ សេរីភាព និង សេចក្តីថ្លៃថ្នូររបស់មនុស្ស ។ កម្ពុជាយើង នាសម័យនោះជ្រើសយកផ្លូវកណ្តាល ដោយប្រកាន់យកមាគ៌ានៃអព្យាក្រឹតភាព ដែលជាធម្មតាមិនត្រូវមានការលំអៀងទៅខាងប្លុកណាមួយឡើយ ។ បន្ថែមលើនោះ ទ្រឹស្តីព្រះពុទ្ធសាសនាក៏ត្រូវបានយកមកបូកផ្សំ បង្កើតមនោគមវិជ្ជាជាតិមួយ ដែលមានឈ្មោះថា "សង្គមនិយមព្រះពុទ្ធសាសនា" ។ នយោបាយអព្យាក្រឹត្យនោះ បាននាំមកនូវសន្តិភាពក្នុងមួយរយៈពេល ក៏ប៉ុន្តែនៅទីបំផុតក៏មិនអាចបញ្ចៀសភ្លើងសង្គ្រាមមិនឲ្យឆាបឆេះកម្ពុជាបានឡើយ ។ អស់ជិតបីទសវត្សរ៍ ប្រទេសយើងក៏ទទួលរងនូវមហាវិនាសកម្ម ដែលនាំឲ្យខ្មែររាប់លាននាក់បានបាត់បង់ជីវិត ។

មនុស្សដែលបានឆ្លងកាត់សង្គ្រាម ដែលនៅសេសសល់ពីសង្គ្រាម ភាគច្រើនប្រាកដជាអាចវាយតម្លៃបានថា តើសន្តិភាពមានន័យពិតៗយ៉ាងណា? និងមានតម្លៃកម្រិតណា? ជាពិសេស សន្តិភាពក្នុងសេរីភាព ។ គេពិតជាទទួលស្គាល់ថាសន្តិភាពដែលនាំមកនូវសេរីភាព និង សេចក្តីថ្លៃថ្នូររបស់មនុស្សមានតម្លៃមហា

សាលដែលគ្មាននរណាអាចកាត់ថ្លៃបានឡើយ ។ គឺសន្តិភាពក្នុងសេរីភាពនេះហើយ ដែលខ្មែរយើងម្នាក់ៗប៉ងប្រាថ្នាចង់បាន ។

ក្នុងចំណោមអ្នករស់រានមានជីវិត រួចផុតពីសម័យសង្គ្រាម អ្នកខ្លះប្រើបញ្ញា ឬ ការឈ្លាសវៃ ចេះរៀនសូត្រពីពេលវេលា ទឹកដីទីកន្លែង ដើម្បីរស់ ។ អ្នកខ្លះទៀតរស់បាន ដោយពឹងផ្អែកលើទេវតា ជឿលើព្រេងសំណាងពីជាតិមុន បណ្តោយជីវិតតាមព្រហ្មលិខិត គឺស្រេចលើអ្វីៗដែលទេវតាចារទុកទាំងអស់ ។ អ្នកទាំងនោះសុទ្ធតែបានទទួលនូវបទពិសោធន៍រៀងៗខ្លួន ដែលគួរតែបន្សល់ទុកឲ្យអនុជនជាន់ក្រោយបានយល់ដឹង ។

អ្វីដែលយើងអាចយល់ដឹងបាន តាមរយៈព្រឹត្តិការណ៍នយោបាយកន្លងមកនោះគឺ៖

-អព្យាក្រឹតភាពនៃកម្ពុជាពីឆ្នាំ ១៩៥៧ ទៅ ១៩៧០ អាចទទួលជោគជ័យបញ្ចៀសសង្គ្រាមបាន ប្រសិនបើកម្ពុជាមានឯកភាព និង សាមគ្គីភាពពិតប្រាកដ និង ប្រសិនបើប្រទេសជិតខាងស្ថិតនៅក្នុងសន្តិភាពដូចយើងដែរ ។ ម្យ៉ាង នៅក្នុងផ្នែកនយោបាយផ្ទៃក្នុង យើងពុំមានឯកភាព និង សាមគ្គីភាពពិតប្រាកដឡើយ ។ តាមពិត ចលនាសង្គមរាស្រ្តនិយមមានគោលដៅបង្រួបបង្រួមជាតិ ក៏ប៉ុន្តែ អ្នកនយោបាយខ្មែរត្រូវបានបែងចែកជា៖ ខ្មែរក្រហម ខ្មែរខៀវ និង ខ្មែរស៊ីជម្ពូជាដើម ។ ម្យ៉ាងទៀត ទោះជាយើងប្រកាសថាយើងប្រកាន់នយោបាយអព្យាក្រឹត្យឥតលំអៀងយ៉ាងណាក៏ដោយ ក៏សហរដ្ឋអាមេរិក នៅតែចោទប្រកាន់ និង រករឿងប្រទេសកម្ពុជាថាជាជម្រករបស់កងទ័ពវៀតកុង ដែលកំពុងតែធ្វើសង្គ្រាមរំដោះជាតិ ប្រឆាំងអាមេរិកនៅប្រទេសវៀតណាមនាសម័យនោះ ។ ដូច្នេះ សង្គ្រាមនៅវៀតណាមក៏រីករាលដាលមកដល់កម្ពុជា ។

-ប្រទេសចិនដើរតួនាទីដ៏សំខាន់នៅក្នុងសង្គ្រាមឥណ្ឌូចិន និង ជាប់ជំពាក់

យ៉ាងខ្លាំង នៅក្នុងជម្លោះកម្ពុជា ។ ប្រទេសចិនបានផ្តល់ការគាំទ្រឥតសំចៃដល់សម្តេចព្រះ នរោត្តម សីហនុ នៅគ្រប់កាលៈទេសៈទាំងអស់ ដែលគ្មានប្រទេសមហាអំណាចណាធ្វើដូចឡើយ ។ ក៏ប៉ុន្តែជាមួយនោះ ប្រទេសចិនក៏ជាសម្ព័ន្ធមិត្រយ៉ាងជិតស្និទ្ធបំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត ។ ទាំងអស់នោះក៏ដើម្បីផលប្រយោជន៍របស់ចិន ក្នុងការទប់ស្កាត់ឥទ្ធិពលរបស់មហាអំណាចឯទៀតនៅក្នុងតំបន់ដែរ ។

-ក្នុងមួយព្រះជន្មរបស់ព្រះអង្គ សម្តេចព្រះ នរោត្តម សីហនុ បានដើរតួនាទីជាប្រវត្តិសាស្ត្រ និង បានផ្សារភ្ជាប់វាសនាផ្ទាល់របស់ព្រះអង្គ ទៅនឹងវាសនារបស់ប្រជាជាតិខ្មែរទាំងមូល ។ កាលណាគេនិយាយអំពីប្រទេសកម្ពុជាក្រោយសង្គ្រាមលោកលើកទី២ គេមិនអាចបំភ្លេច មិននិយាយបានឡើយ អំពីសម្តេចព្រះ នរោត្តម សីហនុ ។ ព្រះអង្គ ឡើងគ្រងរាជសម្បត្តិក្នុងយុវវ័យ នៅក្នុងសម័យអាណាព្យាបាលបារាំង ។ បន្ទាប់មក ព្រះអង្គដឹកនាំព្រះរាជបូជនីយកិច្ចទាមទារ និង ទទួលបាននូវឯករាជ្យពីបារាំង ។ ព្រះអង្គផ្ទេររាជសម្បត្តិទៅព្រះវររាជបិតា ដែលគេមិនដែលឃើញសោះនៅក្នុងលោក ដើម្បីយាងចូលប្រឡូកក្នុងឆាកនយោបាយ ។ នៅក្នុងសម័យសាធារណរដ្ឋខ្មែរ ព្រះអង្គទទួលរងនូវការប្រមាថ និង បន្ទាបបន្ថោកជាអតិបរមា ។ ព្រះអង្គបានគង់នៅក្នុងរបប ប៉ុល ពត ដែលកាប់សម្លាប់ព្រះញាតិវង្សរបស់ព្រះអង្គ ព្រមទាំងបានវាយប្រហាររបបគ្រប់គ្រងរដ្ឋសម័យសង្គមរាស្ត្រនិយមថាជារបបសក្តិភូមិ ។ ដោយសារការវាយផ្តួលរំលំរបប ប៉ុល ពត ដោយកងទ័ពវៀតណាម និង កងទ័ពនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ព្រះអង្គក៏នៅគង់ព្រះជន្មដែលក្រោយមកនាំឲ្យព្រះអង្គ អាចរំដោះព្រះកាយពីការឃុំគ្រងរបស់ខ្មែរក្រហមទៀតផង ។ ព្រះអង្គមានទេពកោសល្យក្នុងការថែរក្សានូវសេចក្តីស្រឡាញ់ និង ស្វាមីភក្តិពីប្រជារាស្ត្រតូចតាច អ្នកស្រែចំការខ្មែរចំពោះព្រះអង្គជានិច្ច ។ ព្រះ

ករុណាព្រះមហាវីរក្សត្រ សម្តេចតារបស់យើងបានបង្ហាញពីសមត្ថភាពខ្ពស់ក្នុងការការពារអាយុជីវិតនយោបាយរបស់ព្រះអង្គបាន គ្រប់កាលសម័យ ទោះជាត្រូវជួបនូវមហាឧបសគ្គបែបណាក៏ដោយ ។ ព្រះអង្គអាចរក្សាព្រះជន្ម និង អាចចេញមកដើរតួនាទីដឹកនាំនយោបាយនៅកម្ពុជាជាថ្មីទៀតបាន រហូតសម្រេចនូវកិច្ចព្រមព្រៀងសន្តិភាពមួយ ដែលគ្មានអ្នកនយោបាយខ្មែរណាធ្វើដូចបានឡើយ ។

-របបសាធារណរដ្ឋរបស់លោក លន់ នល់ ដែលកើតចេញពីព្រឹត្តិការណ៍ ១៨ មីនា ១៩៧០ បានយកសន្ទុះទឹកចិត្តជាតិនិយមប្រឆាំងវៀតណាមរបស់ខ្មែរ ជាពិសេស ខ្មែរអ្នកនៅទីក្រុង និង បញ្ញវន្តមួយចំនួន ដើម្បីទាញយកលក្ខណៈស្របច្បាប់ និង ការគាំទ្រពីប្រជាពលរដ្ឋខ្មែរ ។ ក៏ប៉ុន្តែ អសមត្ថភាពក្នុងការដឹកនាំ និង អំពើពុករលួយដែលស៊ីរូងសង្គមជាតិទាំងមូលនៅសម័យសាធារណរដ្ឋ បានធ្វើឲ្យរបបនេះធ្លាក់ខ្លួនទន់ខ្សោយជាទីបំផុត ដែលត្រូវពឹងផ្អែកទាំងស្រុងតែទៅលើជំនួយរបស់អាមេរិកតែប៉ុណ្ណោះ ។ របបបែបនេះ មិនអាចរស់រានមានជីវិតបានឡើយ បើទោះជាទទួលជំនួយទំហំធំកម្រិតណាក៏ដោយ ។

-របបខ្មែរក្រហម ប៉ុល ពត បានឆ្លៀតយកចំណេញពីការទម្លាក់សម្តេចព្រះនរោត្តម សីហនុ ចេញពីអំណាចរបស់ក្រុមលោក លន់ នល់ នៅឆ្នាំ ១៩៧០ ដើម្បីយកព្រះនាមព្រះអង្គមកប្រើ ក្នុងការបង្កើតកម្លាំងរណសិរ្សរួបរួមជាតិមួយ ឆ្ពោះទៅដណ្តើមអំណាច ។ ខាងផ្នែកកងទ័ព ជាដំបូង ពួក ប៉ុល ពត ឆ្លៀតប្រើកងទ័ពវៀតណាមកុម្មុយនីស្ត ជាកម្លាំងស្រួច ក្នុងការវាយកំទេចកងទ័ពសាធារណរដ្ឋខ្មែរ បន្ទាប់មក ពួកគេក៏ច្បាំងជាមួយកងទ័ពវៀតណាមវិញម្តង ។ ប៉ុល ពត បានយកការភូតភរកុហកបោកប្រាស់ ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ និង ការកាប់សម្លាប់មនុស្សដោយឥតរើសមុខ និង ដោយគ្មានការជំនុំជំរះ ជាមធ្យោបាយក្នុងការក្តោបក្តាប់អំណាចរបស់ខ្លួន ។ របៀបគ្រប់គ្រងបែបនេះ ក៏ក្លាយទៅជាអំពើប្រល័យ

ពូជសាសន៍ និង បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិមួយ ដែលគ្មាននរណាអាចលើកលែងទោសឲ្យបានឡើយ ។ ចលនាតស៊ូរើបំរះប្រឆាំង ប៉ុល ពត ក៏លេចចេញឡើងតាមរូបភាពផ្សេងៗ ជាចលនាផ្ទៃក្នុងក៏មាន ជាចលនាតស៊ូនៅតាមទល់ដែន ខ្មែរ-ថៃ ក៏មាន ។ ប៉ុន្តែ ដោយសារការរៀបចំរបស់ ប៉ុល ពត ឲ្យមហាជនរស់នៅជាសមូហភាពតាមរបៀបបាយរួម ធ្វើការរួម ការផ្គត់ផ្គង់កស្តុភារដល់រាល់ចលនាតស៊ូរើបំរះផ្ទៃក្នុង ពិតជាមានការលំបាកខ្លាំងណាស់ ។ ដូច្នេះ បើគ្មានអន្តរាគមន៍ពីកម្លាំងខាងក្រៅឲ្យទាន់ពេលវេលាទេ ការផ្តួលរំលំរបប ប៉ុល ពត នឹងត្រូវប្រើពេលវេលាយូរ ដែលអាចឲ្យក្រុម ប៉ុល ពត អាចបន្តកាប់សម្លាប់ខ្មែរច្រើនហ្មឺន ច្រើនសែននាក់ទៀត ទោះជាពួកនេះត្រូវប្រជាពលរដ្ឋទូទាំងប្រទេស ស្អប់ខ្ពើមជាទីបំផុតយ៉ាងណាក៏ដោយ ។ ដោយសារគ្មានការគាំទ្រពីប្រជាពលរដ្ឋ របប ប៉ុល ពត រស់បានតែ ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃប៉ុណ្ណោះគឺ មានអាយុខ្លីជាងរបបសាធារណរដ្ឋ លន់ នល់ ទៅទៀត ។

-កងទ័ពវៀតណាម ដែលធ្លាប់កៀកស្មាប្រយុទ្ធរួមគ្នាជាមួយខ្មែរក្រហម នៅគ្រាដំបូង ក្នុងសង្គ្រាមប្រឆាំងរបបលោក លន់ នល់ នៅទីបំផុត ក៏បានត្រឡប់មកជួយវាយផ្តួលរំលំរបប ប៉ុល ពត វិញ ដោយទទួលជោគជ័យ នៅថ្ងៃទី ៧ មករា ១៩៧៩ ។ ក៏ប៉ុន្តែ វត្តមាននៃកងទ័ពវៀតណាមនៅកម្ពុជា ក៏ត្រូវទទួលការចោទប្រកាន់ថា ជាអំពើឈ្លានពានកម្ពុជាហើយចំណុចនេះ ក៏ក្លាយជាហេតុផលនៃការកកើតចលនាអ្នកជាតិនិយមប្រឆាំងវៀតណាម ពីសំណាក់ជនជាតិខ្មែរមួយចំនួនជាពិសេស ពីជនជាតិខ្មែរនៅក្រៅប្រទេស ។ ទាំងនេះ ក៏ដោយសារប្រជាពលរដ្ឋខ្មែរជាទូទៅ តែងតែមើលឃើញនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួនថា រាល់អន្តរាគមន៍របស់កងទ័ពនៃប្រទេសជិតខាងនៅកម្ពុជា ជាអំពើឈ្លានពានដើម្បីត្របាក់លេបយកទឹកដីកម្ពុជា ។ ជាមួយនោះ ពួកខ្មែរក្រហមក៏ឆ្លៀតកេងយកចំណេញពីសន្ទុះទឹកចិត្ត

ជាតិនិយមនេះ ហើយទទួលបានការចូលរួមបង្កើតរណសិរ្សប្រឆាំងវៀតណាមមួយ ក្នុងរូបភាពជារដ្ឋាភិបាលចម្រុះត្រីភាគី ពីសម្តេចព្រះ នរោត្តម សីហនុ និង លោកអតីតរដ្ឋមន្ត្រីទី១ សឺន សាន ។ ក៏ប៉ុន្តែមហាសោកនាដកម្មដែលប្រជាពលរដ្ឋខ្មែរទទួលរងក្នុងរបបប្រល័យពូជសាសន៍ បាននាំឲ្យមានការផ្តន្ទាទោសរបបខ្មែរក្រហមកាន់តែខ្លាំងឡើង និង កាន់តែមានលក្ខណៈសកលឡើង ។ និន្នាការនេះ ក៏សមស្របជាមួយគោលនយោបាយវាយកំទេចខ្មែរក្រហមប្រល័យពូជសាសន៍ ទាំងអង្គការចាត់តាំងនយោបាយ ទាំងអង្គការចាត់តាំងយោធា ដឹកនាំដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលប្រកាន់យកយ៉ាងខ្ជាប់ខ្ជួន និង នាំមុខអនុវត្តបានដោយប្រសិទ្ធភាព ។

-នៅក្នុងសម័យកាលប្រទេសជាតិធ្លាក់ក្នុងក្តីមហន្តរាយ ក៏លេចចេញនូវអ្នកដឹកនាំខ្មែរវ័យក្មេងមួយរូប ដែលមានជាតិកំណើតចេញពីត្រកូលកសិករខ្មែរសុទ្ធសាធ និង ដែលបានប្តេជ្ញាចិត្តវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ឲ្យបានសម្រេច ដើម្បីរំដោះប្រជាពលរដ្ឋខ្មែរចេញពីទាសភាព ទោះជាត្រូវស្វែងរកជំនួយពីកងទ័ពបរទេសឲ្យមកជួយក៏ដោយ ។ លោកនាយករដ្ឋមន្ត្រីវ័យក្មេង ហ៊ុន សែន បានប្រើយុទ្ធសាស្ត្រផ្តួលរំលំរបបប្រល័យពូជសាសន៍ប្រកបដោយជោគជ័យ ដើម្បីវាយបកទៅគ្រប់ការឡោមព័ទ្ធសេដ្ឋកិច្ច និង នយោបាយ រហូតបានក្លាយជាដៃគូមិនអាចខ្វះបានមួយ នៅរាល់ការចរចាស្វែងរកសន្តិភាពនៅកម្ពុជា ។ ឈានចេញពីការប្រមាថមើលងាយរបស់ក្រុមបដិបក្ខថាជាអាយ៉ងរបស់វៀតណាម លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានឡើងអង្គុយស្មើមុខនៅតុចរចាជាមួយសម្តេចព្រះ នរោត្តម សីហនុ ។ ជំនួប សីហនុ - ហ៊ុន សែន លើកទីមួយ នៅ ហ្វែរ អង់តាក ជឺន័រ បានទំលាយភាពទាល់ច្រក និង បើកទ្វារឲ្យ ខ្មែរ និង ខ្មែរ អាចនិយាយគ្នាដោយផ្ទាល់

បាន ។ នេះជាជំហានមួយដ៏សំខាន់ ឆ្ពោះទៅរកដំណោះស្រាយសន្តិភាពសម្រាប់ប្រជាជនខ្មែរ និង សម្រាប់ប្រទេសកម្ពុជា ។

-តាមចរន្តនៃប្រវត្តិសាស្ត្រ ជីវិតរបស់ខ្ញុំក៏ប្រព្រឹត្តទៅ ដូចប្រជាពលរដ្ឋខ្មែរឯទៀតដែរ ដោយទទួលផលល្អនៃសន្តិភាព និង ទទួលផលប៉ះពាល់អាក្រក់នៃសង្គ្រាម ។ មួយរយៈ ខ្ញុំបានក្លាយជាជនភៀសខ្លួន ឃ្លាតឆ្ងាយពីស្រុកទេស រស់នៅម្នាក់ឯង ក្នុងសង្គមនៃប្រទេសសេរីមួយ ដែលអាចជួយមនុស្សឧស្សាហ៍ព្យាយាមដែលចេះខំប្រឹងប្រែងក្នុងជីវិតឲ្យទទួលជោគជ័យបាន ។ ក៏ប៉ុន្តែក្នុងឋានៈជាខ្មែរគ្មាននរណាអាចផ្តាច់ខ្លួន មិនឈឺឆ្អាល មិនញាប់ញ័រ ឬ មិនសោកសង្រេងចំពោះទុក្ខវេទនា ចំពោះការឈឺចាប់របស់ប្រជាពលរដ្ឋខ្មែរនៅក្នុងប្រទេសខ្មែរនោះឡើយ ។ ជីវិតនយោបាយរបស់ខ្ញុំ ហាក់ដូចជាចាប់ផ្តើមឡើង ដោយការផ្សងព្រេង ក៏ប៉ុន្តែខ្សែបន្ទាត់នៃជីវិតនយោបាយនេះ ប្រាកដជាដើរតាមគន្លងនៃសេចក្តីស្នេហាជាតិ ស្រឡាញ់ទឹកដីភូមិស្រុក និង ជនរួមជាតិខ្មែរពិតៗ ។ រាល់ជោគជ័យ សុទ្ធតែបានមកដោយការប្រឹងប្រែង ប្រើអស់កម្លាំងកាយចិត្ត មិនមែនបានមកដោយស្រួលៗនោះឡើយ ។